សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ភាំង សេងហៃ**

ណែនាំដោយ

លោក **សៅ ស៊ីវុត្ថា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ភាំង សេងហៃ**

ណែនាំដោយ
លោក **សៅ ស៊ីវន្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# **សេចក្ដីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ភាំង សេងហៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

## **សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ**

លោកឪពុក **យិន សុផុន** និងអ្នកម្ដាយ **ប៊ុត ចាន់នី** ដែលលោកទាំងពីរបានចិញ្ចឹមបីបាច់ថែរក្សារូបខ្ញុំបាទរហូតមកតាំងពីចាប់កំណើតមករហូតដល់បច្ចុប្បន្ននេះ លោកទាំងពីរបានទូន្មាន ប្រៀនប្រដៅអប់រំឱ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ មិនតែប៉ុណ្ណោះលោកទាំងពីរបានលះបង់ទាំងកម្លាំងកាយចិត្ត ខិតខំរកប្រាក់កាសមកផ្គត់ផ្គង់ជីវភាពគ្រួសារ និងការសិក្សារបស់កូនៗគ្រប់គ្នា ទើបខ្ញុំបាទអាចមានថ្ងៃនេះ។

អគុណសន្តិភាពដែលជាម្លប់ដល់ខ្ញុំបាទ ព្រមទាំងប្រជាពលរដ្ឋគ្រប់រូបអាចប្រកបមុខរបរ រស់នៅដោយសុខសាន្ត និងប្រកបដោយគតិអភិវឌ្ឍន៍សង្គមជាតិ ជាសមិទ្ធផលស្ថិតក្រោមករាជរដ្ឋាភិបាលដឹកនាំ ដោយគំនិតឈ្លាសវៃរបស់ **សម្ដេចអគ្គមហាសេនាធិបតីតេជោ ហ៊ុនសែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំយុវជននិង កីឡា ក្នុងការបង្កើតនូវប្រព័ន្ធអប់រំប្រកបដោយប្រសិទ្ធិភាព ឱ្យរូបខ្ញុំបាទ និងសិស្សានុសិស្សដទៃទៀតគ្រប់រូបមានឱកាសបានសិក្សារៀនសូត្រ ទទួលបានការអប់រំតាំងពីថ្នាក់បឋមសិក្សារហូតចប់មធ្យមសិក្សាទុតិយភូមិ និងសូមថ្លែងអំណរអរគុណដល់ទៅខាងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលអនុញ្ញាត ឱ្យរូបខ្ញុំបាទបានសិក្សារៀនសូត្រនៅទីនេះ។

សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាត ផ្ដល់ឱកាសឱ្យរូបខ្ញុំបាទបានចូលមកសិក្សារៀនសូត្រនៅក្នុងមហាវិទ្យាល័យនីតិសាស្រ្តទាក់ទងទៅនិងផ្នែកច្បាប់នៅកម្ពុជា រហូតមកដល់ពេលនេះជាឆ្នាំបញ្ចប់ នៃថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត។

លោកសាស្រ្តាចារ្យ **សៅ ស៊ីវត្ថា** ផ្នែកនីតិសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ខ្ញុំបាទកម្លងមក ក្នុងការសិក្សាផ្នែកច្បាប់ និងជាពិសេសលោកសាស្រ្តាចារ្យបានណែតម្រង់ទិសក្នុងការរៀបរាងអត្ថបទសារណានេះមករូបខ្ញុំបាទ ដែលមានប្រធានបទសារណា គឺអំពីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នេះផ្ទាល់តែម្ដង។

ជាចុងក្រោយខ្ញុំបាទ ព្រះករុណាខ្ញុំ សូមក្រាបថ្វាយបង្គំ លោកឪពុក យិន សុផុន អ្នកម្ដាយ ប៊ុត ចាន់នី ប្រមុខថ្នាក់ដឹកនាំ សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងសាស្រ្តាចារ្យ **សៅ ស៊ីវត្ថា** ព្រមទាំងអ្នកមានគុណទាំងអស់ ឱ្យមានសុខភាពល្អ ជួបតែសេចក្ដីសុខចម្រើនពុទ្ធពរ ទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ គប្បីឃ្លាងឃ្លាតឡើយ ។

# **ចារម្ភកថា**

ជាបឋមខ្ញុំបាទឈ្មោះ **ភាំង សេងហៃ** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ។ មានសេចក្តីសោមនស្ស រីករាយយ៉ាងខ្លាំងក្រៃលែង និងក៏សូមស្វាគមន៍យ៉ាង កក់ក្តៅក្នុងការ ចូលមកកាន់សារណាបញ្ចប់ការសិក្សាមួយនេះ ។

កម្រងសារណាមួយនេះនឹងពិពណ៌នាជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី មិត្តនិស្សិត បណ្តា អ្នកស្រាវជ្រាវ និងលោកគ្រូអ្នកគ្រូ អំពីស្ថាប័នយុត្តិធ៌មមួយប្រភេទនៅព្រះរាជាណាចក្រកម្ពុជាយើងគឺ អង្គការ អយ្យការអមសាលាដំបូងរាជធានីខេត្ត។ បណ្តាអ្នកអានទាំងឡាយនឹងទទួលបាននូវចំណេះដឹង ស្តីពីការរៀបចំ អង្គការអយ្យការ រចនាសម្ព័ន្ធ តួនាទីភារកិច្ចក្នុងការការអនុវត្តរបស់តំណាងអយ្យការនៅក្នុងរឿងក្តី ការចូលរួម របស់តំណាងអយ្យការនៅក្នុងដំណើរការនីតិវិធីក្នុងការស្វែងរកអត្តភាពបទល្មើស រហូតដល់ការអនុវត្ត។ ទាំងនេះជាសមទ្ធិផល និងផ្លែផ្កាកើតចេញពីការខិតខំរបស់ខ្ញុំបាទក្នុងការសិក្សា ស្រាវជ្រាវ ចងក្រងឡើងដោយ ផ្អែកទៅលើបែបលើវិទ្យាសាស្ត្រមូលដ្ឋានគតិយុត្តគោលនានា ដូចជារដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យ អនុក្រឹត្យ ច្បាប់ស្តីពី លក្ខន្តិកៈ ប្រកាស និងបទដ្ឋានផ្សេងៗទៀត ដែលពាក់ព័ន្ធ សម្រងសាលក្រម របស់ស្ថាប័នតុលាការ។

ទោះបីជាខ្ញុំបាទ បានធ្វើការខិតខំប្រឹងប្រែងស្រាវជ្រាវ ចងក្រង នូវអត្ថបទនេះដោយយកចិត្តទុកដាក់ និងព្យាយាមអស់ពីកម្លាំងកាយចិត្តយ៉ាងណាក្តី ក៏ខ្ញុំបាទយល់ថា វាពុំទាន់មានភាពពេញលេញគ្រប់ជ្រុងជ្រោយ នូវទិដ្ឋភាពពិតជាក់ស្តែង នៃដំណើរកាអនុវត្តរបស់អង្គការអយ្យការអមសាលាដំបូងរាជធានីខេត្តនេះដែរ ព្រោះ នេះជាស្ថាប័នមួយមានភាពស្មុកស្មាញក្នុងការសិក្សា រួមទាំងការស្រាវជ្រាវរបស់ខ្ញុំបាទក៏មានដែនកំណត់នោះ ទើបខ្ញុំបាទយល់ថាអត្ថបទស្រាវជ្រាវមួយនេះអាចនៅមានចំណុចខ្វះខាតដោយប្រការណាមួយ។ ខ្ញុំបាទរីករាយ និងទទួលស្វាគមន៍យ៉ាងកក់ក្តៅ នូវរាល់មតិការិះគន់ក្នុងន័យស្ថាបនា និងកែប្រែរាល់ចំណុចខ្វះខាត និងរាល់ កំហុសផ្សេងៗដែលកើតមានឡើងនៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ។

ជាចុងបញ្ចប់ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ មិត្តនិស្សិត និង ប្រិយមិត្តទាំងអស់ឱ្យជួបតែសេចក្តីសុខចម្រើនគ្រប់ក្រុមគ្រួសារ និងភាពជោគជ័យគ្រប់ភារកិច្ចទាំងឡាយ

# មាតិកា

ទំព័រ

សេចក្តីផ្តើម ............ ១

## ជំពូកទី១
## អំពីអង្គការអយ្យការ

**ផ្នែកទី១ ការកកើតឡើង នៃអង្គការអយ្យការ** ............ ៣

១.១ ប្រវត្ត នៃការកកើតឡើងអង្គការអយ្យការ ............ ៣

១.១.១ ស្ថាប័នអយ្យការក្នុងអំឡុងឆ្នាំ ១៩៣៧ ដល់ឆ្នាំ១៩៧០ ............ ៤

១.១.២ ស្ថាប័នអយ្យការក្នុងរបបធារណៈរដ្ឋខ្មែរ (ឆ្នាំ ១៩៧០ ដល់ ឆ្នាំ១៩៧៥) ............ ៤

១.១.៣ ស្ថាប័នអយ្យការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៧៩) ............ ៥

១.១.៤ ស្ថាប័នអយ្យការក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា(ឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩៣) ...... ៥

១.១.៥ ស្ថាប័នអយ្យការក្នុង ឆ្នាំ១៩៩៣ មកទល់បច្ចុប្បន្ន ............ ៦

១.២ សមាសភាពអយ្យការអមសាលាជម្រះក្តីនាពេលបច្ចុប្បន្ន ............ ៧

១.២.១ អយ្យការអមសាលាជម្រះក្តីជាន់ទាប ............ ៧

១.២.២ មហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ ............ ៧

១.៣ គោលការណ៍សំខាន់ៗ នៃអង្គការយ្យការ ............ ៩

១.៣.១ គោលការណ៍ឋានានុក្រម ............ ៩

១.៣.២ គោលការណ៍ឯករាជ្យ ............ ១០

១.៣.៣ គោលការណ៍អវិភាគ ............ ១០

១.៣.៤ គោលការណ៍មិនទទួលខុសត្រូវ ............ ១១

១.៣.៥ គោលការណ៍មិនអាចប្តឹងជិតចិត្ត ............ ១១

**ផ្នែកទី២ អំពីតំណាងអយ្យការ** ............ ១១

២.១ ការទទួលបាននីតិសម្បទារជាព្រះរាជអាជ្ញា ............ ១១

២.១.១ ការតាំងស៊ប់ជាព្រះរាជអាជ្ញា ............ ១១

២.១.២ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ........ ១៣

២.២ ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ ........ ១៤

២.២.១ កាតព្វកិច្ចដែលត្រូវអនុវត្ត ........ ១៤

២.២.២ ទណ្ឌកម្មខាងវិន័យ ........ ១៥

**ផ្នែកទី៣ មុខការ របស់អង្គការអយ្យការ** ........ ១៦

៣.១ មុខការ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........ ១៦

៣.១.១ អំណាចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........ ១៦

៣.១.២ សមត្ថកិច្ចដែនដីអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........ ១៧

៣.២ មុខការ មហាអយ្យការអមសាលាឧទ្ធរណ៍ ........ ១៧

៣.៣ មុខការ មហាអយ្យការអមតុលាការកំពូល ........ ១៨

## ជំពូកទី ២

## កាលានុវត្តភាព នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

**ផ្នែកទី ១ ការតម្កល់រឿងទុកឥតចាត់ការ** ........ ២០

១.១ មូលហេតុ នៃការតម្កល់រឿងទុកឥតចាត់ការ ........ ២០

១.១.១ ការផុតរលត់ នៃបណ្តឹងអាជ្ញា ........ ២១

១.១.២ អំពើមិនមែនជាបទល្មើស ........ ២៣

១.១.៣ មូលហេតុគតិយុត្តផ្សេងទៀត ........ ២៤

១.២ នីតិវិធី និងអានុភាព នៃការតម្កល់រឿងទុកឥតចាត់ការ ........ ២៥

១.២.១ នីតិវិធី នៃការតម្កល់រឿងទុកឥតចាត់ការ ........ ២៥

១.២.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........ ២៦

**ផ្នែកទី ២ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា** ........ ២៦

២.១ ការបើកការស៊ើបសួរ ........ ២៦

២.១.១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ២៧

២.១.២ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ ២៧

២.២ ការបញ្ជូនទៅជម្រះផ្ទាល់ .................... ២៩
២.២.១ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ .................... ២៩
២.២.២ ការប្រគល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ .................... ៣០
២.៣. ការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម .................... ៣១
២.៣.១ លក្ខខណ្ឌ នៃការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម .................... ៣១
២.៣.២ នីតិវិធី នៃការបង្ហាញខ្លួនភ្លាម .................... ៣២

**ជំពូកទី៣**

**ការចូលរួមរបស់តំណាងអយ្យការ ក្នុងដំណើរនីតិវិធីព្រហ្មទណ្ឌ**

**ផ្នែកទី១ ការដឹកនាំស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា** .................... ៣៣
១.១ ការស៊ើបអង្កេតជាក់ស្តែង .................... ៣៣
១.១.១ លក្ខខណ្ឌ នៃការស៊ើបអង្កេតករណីជាក់ស្តែង .................... ៣៤
១.១.២ ការឆែកឆេរ ក្នុងការស៊ើបអង្កេតជាក់ស្តែង .................... ៣៥
១.១.៣ ការឃាត់ខ្លួន និងការបញ្ជូនខ្លួន .................... ៣៦
១.២ ការស៊ើបអង្កេតបឋម .................... ៣៨
១.២.១ ការបើកការស៊ើបអង្កេតបឋម .................... ៣៨
១.២.២ ការឆែកឆេក្នុងការស៊ើបអង្កេតបឋម .................... ៣៩
១.២.៣ ការបញ្ជាឱ្យចូលខ្លួន .................... ៣៩
**ផ្នែកទី២ តំណាងអយ្យការក្នុងកិច្ចនីតិវិធីស៊ើបសួរ** .................... ៣៩
២.១ ការស្នើរសុំឱ្យបំពេញកិច្ចរបស់ព្រះរាជអាជ្ញា .................... ៤០
២.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ .................... ៤០
២.៣ គោលការណ៍និរន្តរាយ .................... ៤១
២.៣.១ ការបង្គាប់ឱ្យចូលខ្លួន .................... ៤១
២.៣.២ ការបង្គាប់ឱ្យនាំខ្លួន .................... ៤២
២.៣.៣ ការបង្គាប់ឱ្យចាប់ខ្លួន .................... ៤៤

២.៣.២ ការឃុំខ្លួនបណ្តោះអាសន្ន ...... ៤៤
២.៤ ការបិទ និងមោឃភាព នៃការស៊ើបសួរ ...... ៤៨
២.៤.១ ការបិទការស៊ើបសួរ ...... ៤៨
២.៤.២ ការមោឃភាព នៃការស៊ើបសួរ ...... ៤៩
**ផ្នែកទី៣ អង្គការយុត្តិធម៌ក្នុងដំណើរការជំនុំជម្រះ** ...... ៥០
៣.១ និតិវិធីមុនកិច្ចពិភាក្សាដេញដោល ...... ៥០
៣.២ អំឡុងពេល និងការបញ្ចប់កិច្ចពិភាក្សាដេញដោល ...... ៥០
**ផ្នែកទី៤ អយ្យការនៅដំណាក់កាលអនុវត្តទោស** ...... ៥១
៤.១ ការគ្រប់គ្រងពន្ធនាគារ ...... ៥១
៤.២ ការចុះអធិការកិច្ចនៅពន្ធនាគារ ...... ៥២
៤.៣ ការដោះលែងដោយមានលក្ខខណ្ឌ ...... ៥២
សេចក្តីសន្និដ្ឋាន ...... ៥១
អនុសាសន៍ ...... ៥១
ឯកសារយោង

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា នៃការស្រាវជ្រាវ

ជាការពិតណាស់ នៅក្នុងបរិបទរស់នៅក្នុងសង្គម នៃប្រទេសឬរដ្ឋកំពុងអភិវឌ្ឍ ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍគឺតែងតែមានការប្រព្រឹត្តបទល្មើសណាមួយជាក់ជាពុំខាន បើទោះបីជារដ្ឋនោះមានច្បាប់ក្នុងការយកទៅគ្រប់គ្រងប្រទេសរបស់ល្អឥតខ្ចោះយ៉ាងណានោះទេ ក៏នៅតែមានការប្រព្រឹត្តបទល្មើសណាមួយពីសំណាក់ជនទុច្ចរិតពុំខាន។ ដើម្បីទប់ស្កាត់នូវការប្រព្រឹត្តនូវអំពើអសន្តិសុខមិនឱ្យមានភាពរីកដុះដាលកាន់តែខ្លាំង គ្រប់បណ្ដារដ្ឋទាំងអស់ត្រូវមានកាតព្វកិច្ចក្នុងការគ្រប់គ្រង ទប់ស្កាត់ ការពារ បង្ក្រាប នូវរាល់បទល្មើសទាំងឡាយឱ្យមានរបៀបរៀបរយ សន្តិសុខនិងសុខសុវត្ថិភាព ក្នុងការរស់នៅការប្រកបមុខរបរចិញ្ចឹមជីវិត កិត្តិយស សេចក្ដីថ្លៃថ្នូរ ព្រមទាំងពង្រឹងដល់នីតិរដ្ឋ នៃសង្គមផងដែរ។ ជាក់ស្ដែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ក៏បានបង្កើតចងក្រង នូវច្បាប់ក្នុងការដាក់ទោសទណ្ឌដល់ជនទាំងឡាយណាដែលប្រព្រឹត្តខុសផងដែរ ដូចជាក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងច្បាប់ពិសេសទាំងឡាយផ្សេងទៀត ក្នុងការប្រឆាំងទៅនឹងអំពើល្មើសណាមួយក្នុងការយកទៅអនុវត្តទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គល។ ទន្ទឹមនឹងនោះព្រះរាជាណាចក្រកម្ពុជាក៏បានបង្កើតស្ថាប័នមួយ ជាស្ថាប័នតំណាងឱ្យរដ្ឋដែលមានសិទ្ធិអំណាចក្នុងការស្វែងរក ចោទប្រកាន់ និងច្រានចោលនូវបទល្មើសព្រហ្មទណ្ឌផងដែរ ហៅថាអង្គការអយ្យការ។

## ២. ចំណោទបញ្ហា នៃការស្រាវជ្រាវ

ចំពោះនីតិវិធីក្នុងដំណាក់អយ្យការ គឺជានីតិវិធីដ៏សំខាន់មួយព្រោះថាព្រះរាជអាជ្ញា មានតួនាទីក្នុងការកំណត់នូវអត្តភាពនៃបទល្មើស ដាក់បណ្ដឹងអាជ្ញាមានដំណើរការ ឬការលើកចោល នៃការចោទប្រកាន់ នៃបទល្មើស ដែលបានកើតឡើងក្នុងបរិបទសង្គម ដូចនេះហើយយើងគួរតែសិក្សាស្វែងយល់ថា៖

- អ្វីទៅជាអង្គការអយ្យការ? តើអង្គការអយ្យការ មានមុខងារអ្វីខ្លះ?
- តើព្រះរាជអាជ្ញាទទួលបាននីតិសម្បទាដោយលក្ខខណ្ឌណាខ្លះ?
- តើព្រះរាជអាជ្ញាអាចចោទប្រកាន់ ឬមិនចោទប្រកាន់ នូវបណ្ដឹងអាជ្ញាយ៉ាងដូចម្ដេចខ្លះ?
- តើព្រះរាជអាជ្ញាចូលរួមនៅក្នុងនីតិវិធីព្រហ្មទណ្ឌអ្វីខ្លះ? ហើយយើងនិងសិក្សាផងដែរថាតើ ព្រះរាជអាជ្ញាចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌយ៉ាងដូចម្ដេចខ្លះ?

## ៣. គោលបំណងក្នុងការស្រាវជ្រាវ

ទាក់ទងនឹងគោលបំណង នៃការស្រាវជ្រាវស្ដីពី **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** នេះ គឺចង់រំលេចឱ្យបានច្បាស់អំពីតួនាទីភារកិច្ចដែលដែលអង្គការអយ្យការមានសមត្ថកិច្ចក្នុងនីតិវិធីច្បាប់ ដើម្បីទុកជាឯកសារដល់បណ្ដាអ្នកសិក្សានានា ក្នុងការពង្រឹងនូវចំណេះដឹង និងសម្រាប់ប្អូនៗជំនាន់ក្រោយក្នុងការស្វែង

យល់សិក្សា ក៏ដូចជាកែលម្អនូវចំណុចខ្វះខាតដែលកើតឡើងដោយប្រការណាមួយ ព្រមទាំងពង្រឹងចំណេះដឹងទាក់ទងទៅនឹង នីតិវិធីក្នុងដំណាក់កាលអយ្យការនិងតួនាទីភារកិច្ចពីស្ថាប័នអយ្យការ ឱ្យកាន់តែច្បាស់។

## ៤. ទំហំ និងដែនកំណត់ នៃការសិក្សាស្រាវជ្រាវ

បើទោះបីជានៅក្នុងដំណាក់កាល នៃរឿងក្ដីព្រហ្មទណ្ឌបានបែងចែកជា ០៤ ដំណាក់កាលក៏ដោយ ក៏នៅក្នុងអត្ថបទនៃការស្រាវជ្រាវនេះ គឺត្រឹមតែការស្រាវជ្រាវ និងបកស្រាយ នៅក្នុងដំណាក់កាលស៊ើបអង្កេតតួនាទីភារកិច្ចរបស់ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការប៉ុណ្ណោះ។ ដូចនេះ ការស្រាវជ្រាវនេះនឹងបកស្រាយអំពីសកម្មភាពក្នុងការប្រតិបត្តិច្បាប់របស់អង្គការអយ្យការ រចនាសម្ព័ន្ធនៅក្នុងស្ថាប័នអយ្យការ និងការចូលរួមរបស់ព្រះរាជអាជ្ញាចាប់តាំងពីនីតិវិធីស៊ើបអង្កេត រហូតដល់អនុវត្តទោស។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថបទនៃការស្រាវជ្រាវអំពី **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** នេះ គឺខ្ញុំបាទផ្ដោតសំខាន់ទៅលើអត្ថប្រយោជន៍ទៅលើ ០៣ ផ្នែកសំខាន់ៗ៖

- ចំពោះខ្ញុំបាទ
  - ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - ពង្រឹងចំណេះដឹងឱ្យកាន់តែប្រសើរ
  - យល់ដឹងឱ្យកាន់តែច្បាស់លើផ្នែកព្រហ្មទណ្ឌ ជាពិសេសអំពីស្ថាប័នអយ្យការ តួអង្គ និងតួនាទីភារកិច្ច
- ចំពោះស្ថាប័នអយ្យការ

អាចចូលរួមក្នុងការផ្ដល់អនុសាសន៍សម្រាប់ស្ថាប័នអយ្យការ ដែលជាផ្នែកមួយសម្រាប់ចូលរួមក្នុងដំណើរការ នៃរីកចម្រើនរបស់ស្ថាប័នអយ្យការ ចូលរួមកែលម្អនូវចំណុចខ្វះខាតដោយប្រការណាមួយ។

- ចំពោះមិត្តនិស្សិត និងបណ្ដាអ្នកស្រាវជ្រាវ
  - ជាប្រភពឯកសារមួយក្នុងការសិក្សាស្រាវជ្រាវបន្ថែម
  - ជាពុទ្ធិ នៃចំណេះដឹងក្នុងការសិក្សា
  - បង្កើតនូវគំនិតអ្វីដែលថ្មី

## ៦.រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

នៅក្នុងអត្ថបទនៃការស្រាវជ្រាវ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ខ្ញុំបាទនឹងចងក្រងជា ០៣ ជំពូក សម្រាប់លើកមកបកស្រាយលើប្រធានបទនេះរួមមានដូចខាងក្រោម៖

ជំពូកទី១ អំពីអង្គការអយ្យការ

ជំពូកទី២ កាលានុវត្តភាព នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

ជំពូកទី៣ ការចូលរួមរបស់តំណាងអយ្យការ ក្នុងដំណើរនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី ១

# អំពីអគ្គការអយ្យការ

# ជំពូកទី១
# អំពីអង្គការអយ្យការ

បើយើងឱ្យនិយមន័យពាក្យថា «អង្គការ» គឺសំដៅទៅដល់នីតិបុគ្គលសាធារណៈ ឬនីតិបុគ្គលឯកជន ដែលបង្កើតឡើងក្នុងគោលបំណងបម្រើផលប្រយោជន៍រួម ដោយមិនស្វែងរកប្រាក់ចំណេញណាមួយឡើយ។ តែបើក្នុងន័យច្បាប់វិញ អង្គការអយ្យការ គឺជានីតិបុគ្គលសាធារណៈមួយដែលមានសិទ្ធិអំណាច ក្នុងការចោទប្រកាន់នូវរាល់បទល្មើសទាំងឡាយណាដែលបានល្មើសទៅនឹងច្បាប់ព្រហ្មទណ្ឌ និងមានព្រះរាជអាជ្ញាធ្វើការសម្រេចបេសកម្មរបស់អង្គការ។ ក៏ប៉ុន្តែអង្គការនេះមិនមែនជាស្ថាប័នទទួលបន្ទុកជម្រះក្ដីដូចតុលាការទេ ពោលគឺជាភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌដែលជាអ្នកតំណាងឱ្យរដ្ឋ សិទ្ធិអំណាចធ្វើតំណាងឱ្យប្រជារាស្ត្រទាំងអស់ក្នុងការស្វែងរកផលប្រយោជន៍ទូទៅ ជាអ្នកស្វែងរកអត្តភាពនៃបទល្មើស និងធ្វើបណ្ដឹងអាជ្ញាដាក់ឱ្យបណ្ដឹងអាជ្ញាមានចលនា។ ដូចនេះដើម្បីអាចបំពេញតួនាទីរបស់ខ្លួនជាភាគីក្នុងរឿងក្ដី អយ្យការត្រូវមានអ្នកតំណាងគ្រប់ការជម្រះក្ដី ដែលអ្នកតំណាងនោះគឺជាមន្ត្រីស្ថាប័នអយ្យការ។ ដើម្បីមានភាពការងាយស្រួលក្នុងការយល់អំពីអង្គការអយ្យការ យើងត្រូវស្វែងយល់ពីប្រវត្តរបស់ ស្ថាប័នអយ្យការ ថាមានការប្រែប្រួលយ៉ាងដូចម្ដេចខ្លះ? ទើបយើងអាចឃើញរូបរាងដូចពេលបច្ចុប្បន្ននេះ និងគោលការសំខាន់ៗនានា របស់ស្ថាប័នអយ្យការ (ផ្នែកទី១) និងសិក្សាអំពីតំណាងអយ្យការ រួមមាន ការទទួលបាននីតិសម្បទាគ្រប់គ្រាន់ ការទទួលខុសត្រូវ និងផ្នែកវិជ្ជជីវៈ ជាដើម (ផ្នែកទី២) ព្រមទាំង យើងក៏ស្វែងយល់ផងដែរអំពីបនាសម្ព័ន្ធ និងមុខងាររបស់អង្គការអយ្យការ (ផ្នែកទី៣) ។

## ផ្នែកទី១ ការកកើតឡើង នៃអង្គការអយ្យការ[1]

អង្គការអយ្យការគឺ ត្រូវបានបង្កើតឡើងចាប់តាំងពីសម័យអណានិគមនិយមបារាំងមកម្លេះ ប៉ុន្តែចំណេរកាលក្រោយៗមក បូករួមទាំងបរិបទ នៃរបបដឹកនាំផងនោះធ្វើឱ្យស្ថាប័ននេះមានលក្ខណៈដឹកនាំខុសៗគ្នា។ ដើម្បីសិក្សាកាន់តែច្បាស់យើងនឹងស្វែងយល់អំពី ប្រវិត្ត នៃការកកើតអង្គការអយ្យការ (១.១) និង គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការនាពេលបច្ចុប្បន្ន (១.២)។

### ១.១ ប្រវិត្ត នៃការកកើតឡើងអង្គការអយ្យការ

នៅសម័យមុនៗ ក្នុងសម័យរាជាធិបតេយ្យផ្ដាច់ការ ព្រះមហាក្សត្រ មានអំណាចអធិបតេយ្យ ដោយកាន់កាប់អំណាចទាំងបីគឺអំណាចប្រតិបត្តិ បញ្ញត្តិ និង តុលាការ។ ព្រះរាជអាជ្ញាប្ដឹងសុំឱ្យអនុវត្តច្បាប់ ក្នុងឋានៈជាព្រះរាជតំណាង និងក្នុងនាមព្រះមហាក្សត្រដែលជា ម្ចាស់អំណាចអធិបតេយ្យ ប៉ុន្តែចាប់សម័យក្រោយៗមកព្រះមហាក្សត្យលែងមានអំណាចអធិបតិយ្យបែបនេះទៀតហើយ តួយ៉ាងនៅក្នុងប្រព័ន្ធចោទប្រកាន់របស់ខ្មែរក្នុងសម័យអាណានិគមនៅក្នុងសម័យមុនអាណានិគមបារាំង ការផ្ដើមចោទប្រកាន់នៅក្នុងរឿងព្រហ្មទណ្ឌ គឺជាបន្ទុករបស់បុគ្គលម្នាក់ៗដែលជាជនរងគ្រោះនៃអំពើប្រព្រឹត្តរបស់មនុស្សម្នាក់ទៀត។ ទាំងនេះចខដអាចឱ្យយើង

[1] សៀវភៅអង្គការអយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប របស់ឈ្មោះ កុយ នាម និងឈ្មោះ ឡុង បញ្ញារុង បោះពុម្ពនៅឆ្នាំ ២០០៦ ។

ឃើញថាដើមបណ្ដឹងជាអ្នកមានបន្ទុកបង់ប្រាក់ប្រដាប់ក្ដី និងផ្ដល់ពាក្យរាយការណ៍បណ្ដឹងរបស់ខ្លួនក្នុងការដាក់ឱ្យបណ្ដឹងអាជ្ញាមានចលនា ដែលផ្ទុយពីសម័យឥឡូវយើងនេះ ដែលរដ្ឋទទួលភារៈរឿងទាំងអស់នេះក្នុងការចោទប្រកាន់។ ដើម្បីស្វែងយល់ពីវិវត្តន៍ នៃអង្គការអយ្យការ ឱ្យកាន់តែច្បាស់យើងត្រូវស្វែងយល់ពីដំណាក់កាលនីមួយៗចាប់ពីឆ្នាំ ១៩៣៧ ដល់ ឆ្នាំ ១៩៧០ (១.១.១) នៅក្នុងសម័យសង្គមរាស្ត្រនិយម (១.១.២) នៅក្នុងសម័យសាធារណៈរដ្ឋកម្ពុជា (១.១.៣) នៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១.១.៣) និងនៅក្នុងសម័យបន្ទាប់ពីឆ្នាំ១៩៩២ មកទល់ពេលបច្ចុប្បន្ននេះ (១.១.៤) ។

### ១.១.១ ស្ថាប័នអយ្យការក្នុងអំឡុងឆ្នាំ ១៩៣៧ ដល់ឆ្នាំ១៩៧០

នៅក្នុងឆ្នាំ ១៩៣៧ អង្គការអយ្យការត្រូវបានបង្កើតឡើង និងមានក្រមពិភាក្សាព្រហ្មទណ្ឌ (ភាសាសម័យយើងនេះ គេហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ)។ តាមរយៈក្រមនេះ គឺមានមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៅអមសាលាដំបូង នីមួយៗ ហើយនៅអមសាលាជាន់ខ្ពស់មាន « ព្រះរាជបំរើ » និង « ភូឈួយព្រះរាជបំរើ » ដែលនៅពេលនោះមិនទាន់មាននៅគ្រប់សាលាដំបូងគ្រប់ខេត្តទេ ពោលតំណែងព្រះរាជអាជ្ញា គឺមានតែនៅភ្នំពេញប៉ុណ្ណោះ។ ដោយថវិកានៅក្នុងសម័យនោះខ្វះខាត តំណែងប្រធានសាលាដំបូង គេបានជ្រើសយកឱ្យដើរតួនាទីពីរគឺ ជាព្រះរាជអាជ្ញានៅអមសាលានោះផង ព្រមទាំងជាចៅក្រមជំនុំជំរះផងដែរ។ មិនតែប៉ុណ្ណោះតួនាទីព្រះរាជអាជ្ញានេះមកជំនួស តួនាទីរបស់ចៅក្រមស៊ើបសួរ ឬ សុភាចារបុរស ជាអ្នកបង្កសំណុំរឿងចោទប្រកាន់ទៅសាលាមជ្ឈឹម ឬទៅសាលាក្រុមចោទ (ដែលជាសាខាមួយរបស់សាលាឧទ្ធរណ៍ដែលពិនិត្យរឿងឧក្រិដ្ឋ និងរឿងដែលប្ដឹងជំទាស់នឹងដីកា របស់សុភាចារបុរស)។ មន្ត្រីអយ្យការដែលស្ថិតនៅអមសាលាដំបូងមានឈ្មោះថាព្រះរាជអាជ្ញា ចំណែកឯនៅសាលាឧទ្ធរណ៍ មន្ត្រីនេះមានឈ្មោះថា« ព្រះរាជបំរើ » ។ ចំណែកនៅតុលាការកំពូលវិញ (ជំនាន់នោះហៅថា សាលាវិនិច្ឆ័យាធិតី) ពុំមានព្រះរាជអាជ្ញានៅអមទេ ប៉ុន្តែបន្ទាប់ពីសម័យក្រោយៗទៀត អគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យ បានឃើញមានក្នុងច្បាប់ស្ដីពី លក្ខន្តិកៈស្ដីពីយុត្តាធិការចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី ០៩ ខែ មីនា ១៩៥៤។ តាមច្បាប់លក្ខន្តិកៈនេះ អគ្គព្រះរាជអាជ្ញាអមសាលា វិនិច្ឆ័យគ្មានអំណាចលើសមាជិក នៃក្រសួងអយ្យការទេ ( មាត្រា ៩) ។ អគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យ ចាប់មានអត្ថិភាពចាប់តាំងពីឆ្នាំនោះមក។

### ១.១.២ ស្ថាប័នអយ្យការក្នុងរបបធារណៈរដ្ឋខ្មែរ (ឆ្នាំ ១៩៧០ ដល់ ឆ្នាំ១៩៧៥)

នៅក្នុងចន្លោះឆ្នាំ១៩៧០ និង ១៩៧៥ ប្រទេសខ្មែរបានប្ដូររបបពីរាជានិយមមកសាធារណរដ្ឋនិយម ប៉ុន្តែប្រព័ន្ធច្បាប់នៅប្រទេសខ្មែរពុំផ្លាស់ប្ដូរនោះទេ ។ របបសាធារណរដ្ឋរបស់សេនាប្រមុខ លន់ នល់ បន្តនិរន្តរភាព នៃប្រព័ន្ធតុលាការរហូតដល់ពេល ដែលរបបខ្មែរក្រហមបានផ្ដួលរលំ និងឡើងកាន់អំណាចបន្តនៅថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ។ នៅក្នុងសម័យសាធារណរដ្ឋនេះ រដ្ឋអាជ្ញាដែលសល់បន្តពីសម័យមុនមកមានចំនួន ៣៨ នាក់ ហើយមានតែស្ត្រីម្នាក់ប៉ុណ្ណោះ ដែលជាភរិយារបស់លោក ឆុង មីង ដែលមាននាមដើម យស់ ឡាម៉ែល។

រដ្ឋអាជ្ញាពីរនាក់ក្នុងចំណោមចំនួននេះ មានតំណែងនៅក្នុង ក្រសួងយុត្តិធម៌ ចំណែកឯចៅក្រមវិញ មានចំនួន ៩២ នាក់ ហើយពុំមានស្ត្រីនោះទេ។

**១.១.៣ ស្ថាប័នអយ្យការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៧៩)**

នៅក្នុងរបបនេះជារបបដែលប្រទេសខ្មែរគ្មានប្រព័ន្ធច្បាប់ គ្មានប្រព័ន្ធតុលាការអ្វីទាំងអស់ ប៉ុន្តែមានរដ្ឋធម្មនុញ្ញ ដែលអនុម័តដោយសភាខ្មែរក្រហម។ នៅក្នុងរបបនេះ ប្រទេសខ្មែរគឺគ្មានអត្ថបទច្បាប់អ្វីទាំងអស់ដើម្បីអនុវត្តថ្វីបើរបបកម្ពុជាប្រជាធិបតេយ្យមិនបានប្រកាសនិរាករណ៍ច្បាប់ក្នុងរបបមុនៗក៏ដោយ ខ្មែរក្រហមបានបង្កើតរដ្ឋធម្មនុញ្ញមួយ ដែលមិនទទួលស្គាល់សិទ្ធិ និងសេរីភាពបុគ្គលឡើយ រីឯប្រព័ន្ធតុលាការវិញ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានបង្កើតប្រព័ន្ធតុលាការមួយដែលមានឈ្មោះថា «តុលាការប្រជាជន» ។ គ្មានអ្នកណាម្នាក់យល់ពីសញ្ញាណ នៃតុលាការប្រជាជន នេះលើយ ក្រៅពីអ្នកតាក់តែងធម្មនុញ្ញនេះទ។ ពាក្យថា «តុលាការប្រជាជន» នេះត្រូវបានប្រើដោយកម្មភិបាល ឬប្រជាពលរដ្ឋស្នូលរបស់ខ្មែរក្រហម ដែលអាចប្រៀបធៀបទៅនឹងប្រព័ន្ធយុត្តិធម៌ដែលអនុវត្តតាមទំនើងចិត្ត និងអមនុស្សធម៌ជាទីបំផុត។ ពួកគេពន្យល់ថា ប្រជាជនត្រូវមានសិទ្ធិកាត់សេចក្តី តែជាក់ស្តែងគេមិនឃើញមានការរួមប្រជុំប្រជាជនដើម្បីកាត់សេចក្តីទេ គេតែងតែសង្កេតឃើញកម្មាភិបាល ដូចជា ប្រធាន ភូមិ ប្រធានក្រុម ប្រជាជនមូលដ្ឋាន (ប្រជាជនដែលបានរស់នៅក្នុងតំបន់ត្រួតត្រាដោយខ្មែរ ក្រហមក្នុងពេលច្បាំងជាមួយរបបសាធារណរដ្ឋ ឬឈ្លប ជាអ្នកចោទថាអ្នកនេះធ្វើខុស អ្នកនេះជាអ្នកក្បត់) ។ តាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បទល្មើសមានតែពីរប្រភេទ គឺបទល្មើសប្រឆាំង និងបំផ្លិចបំផ្លាញរដ្ឋ ដែលត្រូវមានទោសធ្ងន់ ហើយបទល្មើសក្រៅពីនេះត្រូវទទួលតែការអប់រំប៉ុណ្ណោះ។

**១.១.៤ ស្ថាប័នអយ្យការក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា(ឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩៣)**

បន្ទាប់ពីប្រទេសខ្មែរបានរួចផុតពីរបបដ៏ខ្មៅងងឹតរយៈ ៣ ឆ្នាំ ក្រោយមក អង្គការអយ្យការត្រូវបានបង្កើតឡើង។ ប៉ុន្តែធនធានមនុស្សរលាយស្ទើរតែទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្នុងចំណោមរដ្ឋអាជ្ញាចំនួន ៣៨នាក់ក្នុងសម័យសាធារណរដ្ឋខ្មែរ ប្រហែលជាមានតែ ៣ នាក់ប៉ុណ្ណោះដែលនៅសល់ជីវិត ក្រោយពីការដួលរលំ នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្នុងចំណោមចៅក្រម ៩២ នាក់ មានចៅក្រម ប្រហែល ៨ នាក់ដែលនៅសល់ជីវិត។

នៅក្នុងថ្ងៃទី ១០ កុម្ភៈ ឆ្នាំ១៩៨២ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានអនុម័តច្បាប់ស្តីពី "ការចាត់តាំងអង្គការ តុលាការ និងអយ្យការ" ។[2] អំណាច និងតួនាទី របស់អយ្យការក្នុងសម័យកាលនេះចេញមកពីមាត្រា ១ នៃច្បាប់នេះ ហើយក៏មានលក្ខណៈដូចគ្នានឹងអំណាច និង តួនាទីរបស់តុលាការផងដែរ អង្គការអយ្យការមានបេសកកម្ម និងទិសដៅ ត្រូវការពារអំណាចប្រជាជន និងនីត្យានុកូលភាពប្រជាធិបតេយ្យ រក្សាសន្តិសុខសាធារណៈនិងរបៀបរៀបរយសង្គម ការពារទ្រព្យសម្បត្តិសាធារណៈ ការពារសិទ្ធិ សេរីភាព ជីវិត និងប្រយោជន៍ស្របច្បាប់របស់ ពលរដ្ឋ ដើម្បីពង្រឹងឯករាជ្យជាតិ និងធានាការកសាងមាតុភូមិឈានជាជំហានៗ

[2] សៀវភៅអង្គការអយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប របស់ឈ្មោះ **កុយ នាម** និងឈ្មោះ **ឡុង បញ្ញារុធ** ទំព័រទី៦០ បោះពុម្ពនៅឆ្នាំ ២០០៦។

ឆ្ពោះទៅឡើងសង្គម និយម។ នៅក្នុងដំណើរការក្តី អយ្យការមានតួនាទីស៊ើបអង្កេត ឬទទួលរបាយការណ៍ស៊ើបអង្កេតពី អង្គការស៊ើបអង្កេត និងធ្វើបណ្តឹងចោទប្រកាន់ រីឯនៅក្នុងសវនាការ រដ្ឋអាជ្ញាប្រើសិទ្ធិអយ្យការ រួមទាំងគាត់ជាអ្នកអនុវត្តសាលក្រមផងដែរ។ កិច្ចការខ្លះរបស់ចៅក្រមស៊ើបអង្កេត ក្នុងសម័យបច្ចុប្បន្នយើងនេះ ដូចជាអំណាចស៊ើបអង្កេត អំណាចសំរេចពីការឃុំខ្លួន ឬការ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នជាដើម ត្រូវបានប្រគល់ឱ្យទៅរដ្ឋអាជ្ញានៅសម័យនោះ។

ការជ្រើសរើសនិងការតែងតាំងរដ្ឋអាជ្ញា-អគ្គរដ្ឋអាជ្ញានិងការអប់រំ ពោលគឺ គណៈកម្មាធិការប្រជាជនបដិវត្តខេត្តក្រុង ជាអ្នកជ្រើសរើសរដ្ឋអាជ្ញាអមតុលាការខេត្តក្រុង រួចស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្រោយពីការយល់ព្រមរបស់រដ្ឋមន្ត្រីហើយ រដ្ឋអាជ្ញានោះនឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ ចំណែកឯរដ្ឋអាជ្ញារងវិញ ការតែង តាំងមានបែបបទខ្លីជាងរដ្ឋអាជ្ញា។ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងជាអ្នកជ្រើសរើសរួចហើយ ស្នើសុំការការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លុះបានការយល់ព្រមហើយរដ្ឋអាជ្ញារងនោះត្រូវបានតែងតាំងដោយគណៈកម្មការនោះតែម្តង (មាត្រា ២២ នៃ ច្បាប់ស្តីពីការចាត់តាំងអង្គការ តុលាការនិងអយ្យការ" ដែលអនុម័តដោយរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ថ្ងៃ ១០ កុម្ភៈ ១៩៨២)។ នៅតុលាការថ្នាក់ខេត្ត-ក្រុងនិមួយៗត្រូវមានរដ្ឋអាជ្ញាម្នាក់ និងរដ្ឋអាជ្ញារងម្នាក់ឬពីរនាក់។ តុលាការប្រជាជនត្រូវបានបង្កើតពិតប្រាកដនៅគ្រប់ខេត្តក្នុងឆ្នាំ១៩៨៣ ប៉ុន្តែមានតែខេត្តដែលធំៗប៉ុណ្ណោះបានតែងតាំងរដ្ឋអាជ្ញា និងរដ្ឋអាជ្ញារង ចំណែកខេត្តតូចៗមានតែរដ្ឋអាជ្ញាម្នាក់។

### **១.១.៥ ស្ថាប័នអយ្យការក្នុង ឆ្នាំ១៩៩៣ មកទល់បច្ចុប្បន្ន**

ចាប់ពីឆ្នាំ ១៩៩៣ មកតុលាការខ្មែរត្រូវបានរៀបចំនិងកែប្រែទៅតាមគំរូថ្មី របង្កើតចៅក្រមស៊ើបអង្កេត ការបង្កើតសាលាឧទ្ធរណ៍ ការអនុម័តនីតិវិធីព្រហ្មទណ្ឌថ្មី ការអនុម័តច្បាប់ព្រហ្មទណ្ឌថ្មីដោយអាជ្ញាធរ អន្តរកាលនៃអង្គការសហប្រជាជាតិនៅកម្ពុជា ការបង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញជាដើម។ វគ្គបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាក៏បានចាប់ផ្តើមចាប់តាំងពីឆ្នាំ ១៩៩៤ មក ហើយវគ្គបណ្តុះបណ្តាលចៅក្រមលើកទីមួយត្រូវបានរៀបចំធ្វើនៅឆ្នាំ ១៩៩៤ ដោយក្រសួង យុត្តិធម៌ក្រោមការដឹកនាំនៃរដ្ឋមន្ត្រីថៃម សួន។ វគ្គបណ្តុះបណ្តាលតម្រូវឱ្យបេក្ខជនមានគុណសម្បត្តិ (១) ចំពោះ បេក្ខជនជាមន្ត្រីរាជការ ត្រូវមានបទពិសោធន៍បំរើការខាងវិស័យយុត្តិធម៌យ៉ាងតិច ១០ ឆ្នាំ និង មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (២) ចំពោះបេក្ខជនរាជការដដែល ត្រូវមានសញ្ញាប័ត មធ្យមនីតិសាស្ត្រនិងបានបំរើការងារក្នុងវិស័យយុត្តិធម៌យ៉ាងតិច ៥ ឆ្នាំ និង (៣) ចំពោះបេក្ខជន ទូទៅ ត្រូវមានសញ្ញាប័ត្របរិញ្ញាប័ត្រច្បាប់។ បន្ទាប់ពីបានជាប់ជាសិស្សចៅក្រមហើយ ព្រមទាំងឆ្លងកាត់ការប្រឡងចេញទទួលបានចោកជ័យ សិស្សចៅក្រមដែលរៀនបានលេខមួយដល់លេខដប់ប្រាំអាចជ្រើស រើសយកសាលាឧទ្ធរណ៍ និងតុលាការភ្នំពេញ អ្នកដែលបានលេខចាប់ពីដប់ប្រាំមួយឡើងទៅ អាចជ្រើសរើសយកតាមលេខរៀងនូវតុលាការដែលខ្លួនចង់បាន។ ចំពោះតុលាការនីមួយៗដែលសិស្សចៅក្រមបានជ្រើសរើស គឺរដ្ឋមន្ត្រីជាអ្នកចង្អុលថាអ្នកណាត្រូវធ្វើជាចៅក្រម ឬ អ្នកណាត្រូវធ្វើជាព្រះរាជអាជ្ញា។

នៅឆ្នាំ ២០០២ : សាលាភូមិន្ទចៅក្រមត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ៥ កុម្ភៈ ២០០២ យោងតាមអនុក្រឹត្យនេះ មានមនុស្សបីប្រភេទអាចចូល រៀនក្នុងសាលានេះតាមរយៈការប្រឡង និងការចាត់តាំង។

## ១.២ សមាសភាពអយ្យការអមសាលាជម្រះក្តីនាពេលបច្ចុប្បន្ន

ស្ថាប័នអយ្យការនាពេលបច្ចុប្បន្ន គឺមាននៅតាមគ្រប់សាលាជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជា។ យោងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ យើងឃើញថាមាន អយ្យការអមសាលាជម្រះក្តីជាន់ទាប (១.២.១) និង មហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ (១.២.២)។

### ១.២.១ អយ្យការអមសាលាជម្រះក្តីជាន់ទាប

អយ្យការអមសាលាជម្រះក្តីជាន់ទាប ដែលយើងស្គាល់ថាជា អយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ បើយោងមាត្រា២៩ នៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ បានបញ្ញត្តិនូវសមាសភាពអយ្យការអមសាសាដំបូងមានដូចជា៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការនៅអយ្យការអមសាលាដំបូង។[3]

ប៉ុន្តែបើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌសមាសភាពអយ្យការអមសាលាដំបូងមានត្រឹមតែ

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង។[4]

### ១.២.២ មហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់

សាលាជម្រះក្តីជាន់ខ្ពស់រួមមាន សាលាឧទ្ធរណ៍ និងតុលាការកំពូល នេះបើយោងតាមមាត្រា៣ នៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ។ ដូចនេះមហាអយ្យការអនសាលាជម្រះក្តីជាន់ខ្ពស់មាន មហាអយ្យការអមសាលាឧទ្ធរណ៍ និងមហាអយ្យការអមតុលាការកំពូល។

ក. មហាអយ្យការអមសាលាឧទ្ធរណ៍

នៅសាលាឧទ្ធរណ៍មិនខុសពីសាលាដំបូងឡើយ គឺមានអង្គការអយ្យការមួយដូចគ្នានៅអមសាលាជម្រះក្តីថ្នាក់ទី២នេះ (សាលាឧទ្ធរណ៍) ដែលហៅថា «អង្គការអមសាលាឧទ្ធរណ៍» ហើយបើតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ តួអង្គនៃអង្គការនេះមានសមាសភាពដូចជា៖

- អគ្គព្រះរាជអាជ្ញា

[3] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/១៥ ប្រកាសអោយប្រើនៅថ្ងៃទិ២២ ខែឧសភា ឆ្នាំ២០១៤, មាត្រា២៩

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣៦

- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការនៅមហាអយ្យការអមសាលាឧទ្ធរណ៍។[5]

បើតាមក្រមព្រហ្មទណ្ឌវិញនោះបានបញ្ញត្តនូវសមាសភាពសមាសភាពអង្គកាមហាអយ្យការអមសាលាឧទ្ធរណ៍ដូចតទៅះ

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា។

ខ. មហាអយ្យការអមតុលាការកំពូល

តុលាការកំពូល ជាតុលាការជាន់ខ្ពស់ផុតលេខដែលមានតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជាយើងមានអង្គការមួយដែលនៅអមជាមួយដែរគឺ មហាអយ្យការអមតុលាការកំពូល។ តាមច្បាប់ស្តីពីការរៀបចំអង្គការតុលារកា រអង្គការនេះមានសមាសភាពដូចជា

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការនៅមហាអយ្យការអមតុលាការកំពូល។6

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ អង្គការមហាអយ្យការមានតំណាងអយ្យការដូចជា

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា។[7]

---

[5] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/១៥ ប្រកាសអោយប្រើនៅថ្ងៃទិ២២ ខែឧសភា ឆ្នាំ២០១៤, មាត្រា៥៩

[6] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នស/រកម/០៧១៤/១៥ ប្រកាសអោយប្រើនៅថ្ងៃទិ២២ ខែឧសភា ឆ្នាំ២០១៤, មាត្រា៦៨

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣១

## ១.៣ គោលការណ៍សំខាន់ៗ នៃអង្គការយ្យការ

នៅក្នុងចំណុចនេះផងដែរយើងនឹងទៅសិក្សាអំពី គោលការណ៍ឋានានុក្រម (១.២.១) នៃតួអង្គនៅក្នុងស្ថាប័ន គោលការណ៍ឯករាជភាព (១.២.២) ក្នុងការវិនិច្ឆ័យសម្រេច គោលការណ៍អវិភាគ (១.២.៣) គោលការណ៍មិនទទួលខុសត្រូវ (១.២.៤) និងគោលការមិនអាចប្តឹងជិតចិត្ត (១.២.៥) លើតំណាងអយ្យការណាម្នាក់។

### ១.៣.១ គោលការណ៍ឋានានុក្រម

នៅក្នុងនៅក្នុងស្ថាប័នអយ្យការ គឺគោលការណ៍ឋានានុក្រមត្រូវបានកំណត់យ៉ាងជាក់លាក់តាមលំដាប់លំដោយ ដែលមានការគ្រប់គ្រង និងការត្រួតពិនិត្យ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធ៌មជានាយឋានានុក្រមខ្ពស់ជាងគេលើកលែងតែមហាអយ្យការអមតុលាការកំពូល។

ឋានានុក្រមនៅក្នុងអង្គការអយ្យការបានបែងចែកដូចតទៅៈ

- មហាអយ្យការអមតុលាការកំពូល
  - អគ្គព្រះរាជអាជ្ញាជានាយឋានានុក្រម នៃមហាអយ្យការអមតុលាការកំពូល
  - អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។
- មហាអយ្យការអមសាលាឧទ្ធរណ៍
  - អគ្គព្រះរាជអាជ្ញាជានាយឋានានុក្រម នៃមហាអយ្យការអមសាលាឧទ្ធរណ៍
  - អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។
- អយ្យការអមសាលាដំបូងរាជធានី-ខេត្ត
  - ព្រះរាជអាជ្ញាជានាយឋានានុក្រម នៃមហាអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
  - ព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

លើសពីនេះទៅទៀតនៅពេលមានរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវស្តាប់បង្គាប់អគ្គព្រះរាជអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធ៌ម។ បើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត បានប្រព្រឹត្តកំហុស គឺរដ្ឋមន្ត្រីក្រសួងយុត្តិអាចប្តឹងបរិហារអំពីកំហុសនោះបាន និងរាល់រឿងក្តីកើតមានឡើង កាលបើរដ្ឋមន្ត្រីបានដឹង ឬបានយល់ឃើញថាយ៉ាងណា គឺអាចធ្វើអធិបញ្ជាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្តនេះ ឱ្យធ្វើការចោទប្រកាន់តាមការយល់ឃើញរបស់ខ្លួន ព្រមទាំងអាចធ្វើអធិបញ្ញាឱ្យធ្វើការសន្និដ្ឋានបានទៀតផង ទោះជាអគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាមិនចង់ដំណើរការពាក្យបណ្តឹងក៏ដោយ។ ទោះជាអធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធ៌មមានអានុភាពយ៉ាងណា

ក្តីក៏មិនអាច ធ្វើអធិបញ្ញាឱ្យតម្កល់រឿងទុកឥតចាត់ការឡើយ ដោយអាចបញ្ជាព្រះរាជអាជ្ញាឱ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសម្រេចតាមការយល់ឃើញរបស់ខ្លួនតែប៉ុណ្ណោះ។

បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៩ កថាខណ្ឌទី១ បានកំណត់ថា « *រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឱ្យតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។*

*អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមខ្លួនយល់ឃើញថាជាការគួរ។*

*ព្រះរាជអាជ្ញាមានអំណាចទៅលើចៅក្រមអយ្យការដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។*

*ព្រះរាអាជ្ញាអាចធ្វើអធោបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមខ្លួនយល់ឃើញថាជាការគួរ។»* នៅពេលដែលព្រះរាជអាជ្ញារងបានទទួលនូវរឿងក្តីមួយ ហើយសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញារង គឺតំណាងអោអយ្យការនោះទាំងមូលដែលហៅថាគោ លការណ៍មិនអាចបំបែកបាន ដែលយើងនឹងបកស្រាយនៅខាងមុខ។ ដូចនេះបើព្រះរាជអាជ្ញារងបានតម្កល់រឿងទុកឥតចាត់ការ នោះព្រះរាជអាជ្ញាមិនអាចបញ្ជាឱ្យចោទប្រកាន់វិញបានឡើយ។
ទោះជាគោលការណ៍ឋានានុក្រមត្រូវស្តាប់បញ្ជាថ្នាក់លើក្តី ក៏មានអញត្តិកម្មនៅពេលឡើងសាវនាការគឺចៅក្រមអយ្យការមានសេរីភាពក្នុងការ ធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់ ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន។

### ១.៣.២ គោលការណ៍ឯករាជ្យ

អង្គការអយ្យការ គឺជាស្ថាប័នឯករាជ្យ ចេញពីតុលាការជម្រះក្តី មានន័យថាស្ថាប័ននេះមិនស្ថិតក្រោមការគ្រប់គ្រងរបស់សាលាជម្រះក្តីឡើយ ដូចនេះសលាជម្រះក្តីមិនអាចត្រួតពិនិត្យកិច្ចការ ឬជ្រៀតជ្រែក កិច្ចការរបស់ស្ថាប័នអយ្យការឡើយ។ ប្រសិនបើក្នុងករណីព្រះរាជអាជ្ញាមានកំហុសឆ្គងនៅក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេច យកការស្តីបន្ទោស ចំពោះព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែបើសាលាជម្រះក្តីបានរកឃើញពីកំហុសរបសើព្រះរាជអាជ្ញា សាលាជម្រះក្តីអាចលើកសំណើរទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។

### ១.៣.៣ គោលការណ៍អវិភាគ

គោលការណ៍អវិភាគ ឬអាចហៅបានថា មិនអាចបំបែកបាន ដែលគោលការណ៍នេះសំដៅទៅលើការកំណត់ឱ្យអង្គការអយ្យការក្លាយជាអង្គការអវិភាគមួយ គឺព្រះរាជអាជ្ញាមានកាតព្វកិច្ចរួមគ្នា នូវមុខងារក្នុងស្ថាប័នរបស់ខ្លួន ព្រោះសកម្មភាពនៃការបំពេញមុខងារនោះធ្វើឡើងក្នុងក្របខណ្ឌ នៃអយ្យការដែលខ្លួនកំពុងឈរជើង។ *អង្គការអយ្យការគឺជាអង្គការអវិភាគ ដែលតម្រូវឱ្យព្រះរាជអាជ្ញាបំពេញមុខងារនៅសាលាជម្រះក្តីណាមួយមាន*

*កាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះតំណាងអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។*

**១.៣.៤ គោលការណ៍មិនទទួលខុសត្រូវ**

ចៅក្រមអយ្យការបំពេញមុខងារជាសមូហភាព និងសម្រេចសេចក្ដីដំណាងឱ្យស្ថាប័នអយ្យការទាំងមូលមិនមែនក្នុងនាមបុគ្គលនោះឡើយទើប ចៅក្រមអយ្យការមិនទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់ខ្លួននោះទេ។ ចៅក្រមអយ្យការជាតំណាងឱ្យអំណាចនីតិប្រតិបត្តិ ដើម្បីការពារផលប្រយោជន៍សាធារណៈ និងសន្តិសុខសណ្ដាប់ធ្នាប់សង្គម និងតាំងខ្លួនជាគូរភាគីនៅក្នុងបណ្ដឹងព្រហ្មទណ្ឌ ប្រឆាំងនឹងជនល្មើសជានិច្ច។ ហេតុដូចនេះនៅពេលដែល ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ចំពោះបុគ្គលណាម្នាក់ ដើម្បីឱ្យស្ថាប័នយុត្តាធិការជំនុំជម្រះ ហើយបុគ្គលនោះត្រូវបានតុលាការប្រកាសថាគ្មានពិរុទ្ធភាព ឬសម្រេចឱ្យរួចផុតពីបទចោទព្រះរាជអាជ្ញាមិនត្រូវដាក់ឱ្យទទួលខុសត្រូវ ឬទណ្ឌកម្មវិន័យណាមួយឡើយ។

**១.៣.៥ គោលការណ៍មិនអាចប្ដឹងជិតចិត្ត**

ចៅក្រមអយ្យការមិនអាចប្ដឹងជិតចិត្តដូចចៅក្រមអសនៈបានទេ។ ចៅក្រមអយ្យការគឺជាភាគីមួយនៅក្នុងបណ្ដឹងព្រហ្មទណ្ឌ ដែលមានសមត្ថកិច្ចស្វែងរកបទល្មើសដាក់បន្ទុកតែប៉ុណ្ណោះ ពោលគឺគ្មានឆន្ទានុសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចនោះទេ។ ចៅក្រមអយ្យការមានសិទ្ធិអំណាចតំណាងឱ្យគ្នាទៅវិញទៅមកគ្រប់កិច្ចនីតិវិធី។

**ផ្នែកទី២ អំពីតំណាងអយ្យការ**

តំណាងអយ្យការ គឺជាមន្ត្រីដែលបំម្រើការនៅក្នុងស្ថាប័នអយ្យការនីមួយៗ ហើយជាមន្ត្រីដែលមានសិទ្ធិអំណាច ក្នុងការសម្រេច និងតំណាងឱ្យស្ថាប័នអយ្យការបាន។ ពោល គឺមានព្រះរាជអាជ្ញាតំណាងឱ្យស្ថាប័នអយ្យការនីមួយៗ ហើយដើម្បីអាចក្លាយខ្លួនជាព្រះរាជអាជ្ញាតាមស្ថាប័ននេះ ពួកគេត្រូវទទួលនីតិសម្បទាគ្រប់គ្រាន់ (២.១) ក្នុងមុខតំណែងនេះ បន្ទាប់ពីពួកគេបានទទួលនិតិសម្បទាគ្រប់គ្រាន់ជាព្រះរាជអាជ្ញាបានចូលបម្រើការហើយ គ្រប់ព្រះរាជអាជ្ញាទាំងអស់ក៏ត្រូវមាន ទំនួលខុសត្រូវរបស់ខ្លួនទៅលើផ្នែកវិជ្ជាជីវៈ (២.២) ផងដែរ។

**២.១ ការទទួលបាននីតិសម្បទាជាព្រះរាជអាជ្ញា**

ការទទួលបាននីតិសម្បទាជាព្រះរាជអាជ្ញា គឺជាការដែលបុគ្គលម្នាក់មានទទួលបានសិទ្ធិពេញលេញតាមផ្លូវច្បាប់ក្នុងការបំពេញមុខងារជាព្រះរាជអាជ្ញា តាមរយៈព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ ក្នុងការតែងតាំងឱ្យក្លាយជាព្រះរាជអាជ្ញា។ ដើម្បីយល់ឱ្យកាន់តែច្បាស់ថាតើសិស្សចៅក្រមព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិដូចម្ដេចខ្លះទើបអាចតាំងស៊ប់ជាព្រះរាជអាជ្ញាបាន? (២.១.១) និងយើងនឹងទៅសិក្សាអំពីការឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញាបន្ទាប់ពីបានតាំងស៊ប់ហើយ (២.១.២)។

**២.១.១ ការតាំងស៊ប់ជាព្រះរាជអាជ្ញា**

មុនពេលដែលអាចក្លាយខ្លួនជាព្រះរាជអាជ្ញាពេញសិទ្ធិ ពោលគឺព្រះរាជអាជ្ញាត្រូវឆ្លងកាត់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយមានការរៀបចំការប្រឡងជ្រើសរើសដោយក្រសួងយុត្តិធម៌។ បើផ្អែកតាមច្បាប់ស្ដីពីលក្ខន្តិកៈ

នៃចៅក្រម និងព្រះរាជអាជ្ញា ការជ្រើសរើសសិស្សចៅក្រមអាចធ្វើឡើងតាមពីររបៀបគឺ តាមមាត្រា២៣ *ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រម អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងមាន បទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ហើយដែលមានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំគិតមកដល់ថ្ងៃប្រឡង ។ មេធាវី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ អាចចុះឈ្មោះចូលរួមប្រឡងប្រជែងតាមបញ្ញត្តិ នៃវាក្យខណ្ឌទី ១ ខាងលើនេះបាន ប្រសិនបើមេធាវីនោះមានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។*[8]

ជំពូកទី៣ ផ្នែកទី៥ មាត្រា៨២ *ការជ្រើសរើស និងបណ្ដុះព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើស និងបណ្ដុះបណ្ដាលចៅក្រមតាមបញ្ញត្តិនៃទី២ (ចៅក្រម) ផ្នែកទី៥ (ការជ្រើសសរើសចៅក្រម) នៃច្បាប់នេះ។*

ការកំណត់ចំនួននៃសិស្សចៅក្រមព្រះរាជអាជ្ញា គឺជាសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធ៌មដែលបានពិគ្រោះគ្នាជាមួយ សមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម។[9] បន្ទាប់ពីធ្វើការប្រកួតប្រជែងតាមរយៈការប្រឡងចូលជាសិស្សចៅក្រម នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា តាមការប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធ៌ម[10] បេក្ខជនដែលបានប្រឡងជាប់ជាសិស្សព្រះរាជអាជ្ញាត្រូវទទួលបានការបណ្ដុះបណ្ដាលវិជ្ជាជីវៈដោយក្រសួងយុត្តិធ៌ម និងស្របតាមការប្រកាសរបស់ក្រសួងយុត្តិធម៌។ ចំពោះបេក្ខជនដែលអាចមានសិទ្ធិប្រឡងចូលជាសិស្សចៅក្រមត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

១. ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២. មានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤. មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥. ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន ។[11]

បន្ទាប់ពីឆ្លងកាត់ការប្រឡងបញ្ចប់ថ្នាក់ដោយជោគជ័យ សិស្សចៅក្រមព្រះរាជអាត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនតាមការកំណត់របស់ក្រសួងយុត្តិធម៌មុនពេលក្លាយជាព្រះរាជអាជ្ញាពេញលេញ គឺជាការចុះកម្មសិក្សា។ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវបានតែងតាំងដោយដោយព្រះរាជក្រឹត្យជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ដែលកម្មសិក្សានេះមានរយៈពេល ១ ឆ្នាំគិតចាប់ពីការចុះកាល

[8] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ មាត្រា២៣

[9] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ មាត្រា២០

[10] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ មាត្រា២២

[11] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ មាត្រា១៩

បរិច្ឆេទនៃការតែងតាំង។[12] មានករណីខ្លះដែលអាចធ្វើការលប់ឈ្មោះចេញគ្រប់ពេលវេលាក្នុងករណីដែលព្រះរាជអាជ្ញាពុំមានសម្បទាគ្រប់គ្រាន់ ឬសុខភាពមិនល្អគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌពេញលេញតាមច្បាប់កំណត់។ ប៉ុន្តែក្នុងករណីព្រះរាជអាជ្ញាកម្មសិក្សាពុំទាន់ទទួលបានជោគជ័យក្នុងការបំពេញកម្មសិក្សា ឬបានអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់៣០ (សាមសិប) ថ្ងៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចឱ្យព្រះរាជាអាជ្ញាកម្មសិក្សារូបនោះបន្តធ្វើកម្មសិក្សាមួយឆ្នាំបន្ថែមទៀត។[13]

### ២.១.២ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ

ដូចដែលបានលើកឡើងខាងលើ គឺនៅពេលដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ គឺទទួលបានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ *ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ។*

*លក្ខខណ្ឌនៃការតំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមវេនអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ។*[14]

ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ គឺធ្វើឡើងដោយមានការរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលតំឡើងថ្នាក់ និងឋានន្តរសក្តិ និងតាមលំដាប់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីត្រួតពិនិត្យនិងផ្តល់យោបល់ ដោយតារាងនេះទៀតសោត រៀបចំដោយគណៈកម្មការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ត្រូវបានរៀបចំតារាងឈ្មោះនេះដាក់ជូនទៅក្រសួងយុត្តិធម៌ ដើម្បីឱ្យក្រសួងយុត្តធម៌ធ្វើសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយជូនព្រះមហាក្សត្រ។[15]

ចំពោះលក្ខខណ្ឌនៃការជ្រើសរើសតំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវផ្អែកតាមមូលដ្ឋានមួយចំនួនក្នុងមាត្រា ២៨ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមបព្រះរាជអាជ្ញា៖ ក្នុងរយៈពេលដែលព្រះរាជអាជ្ញាកំពុងបំពេញការងារ ព្រះរាជអាជ្ញាដែលបានខិតខំបន្ថែម ហើយទទួលបានសញ្ញាបត្រក្រោយឧត្តមសិក្សា ត្រូវបានលើកទឹកចិត្តដោយតម្លើងថ្នាក់ ១ (មួយ) ថ្នាក់ទៀត។

- ការគោរពវិន័យបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធ៌មល្អ មិនប៉ះពាល់កិត្តិយសនៃអង្គចៅក្រម
- ការឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សាតាមគ្រឹស្ថានឧត្តមសិក្សា។[16]

---

[12] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៨៣ កថាខណ្ឌទី១

[13] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៨៤ កថាខណ្ឌទី២

[14] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា២៧

[15] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៨៨

[16] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា២៨

## ២.២ ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ

បើទោះបីជាព្រះរាជអាជ្ញាមិនអាចត្រូវវាបានប៉ឹងដិតចិត្តនៅក្នុងរឿងព្រហ្មទណ្ឌ ក៏នៅក្នុងឱកាសបំពេញមុខងាររបស់ខ្លួន គ្រប់ព្រះរាជអាជ្ញាទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវវិធានច្បាប់ និងកាតព្វកិច្ចដែលបានកំរិតនូវដែនសមត្ថកិច្ច និងក្រមសីលធម៌ដើម្បីធានានូវកិត្តិយសរបស់ស្ថាប័ន។ ព្រះរាជអាជ្ញាត្រូវមានភាកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងគោរពឱ្យបានម៉ឺងមាត់នូវក្រមសីលធម៌របស់ខ្លួន។[17] ដើម្បីសិក្សាអំពីទំនួលខុសត្រូវរបស់តំណាងអយ្យការ យើងត្រូវដឹងថាតើព្រះរាជអាជ្ញាអនុវត្តនូវភាកិច្ចអ្វីខ្លះ(២.២.១) ក្នុងនាមជាតំណាងអយ្យការ និងនៅពេលដែលមានកំហុស តើព្រះរាជអាជ្ញាទទួលទណ្ឌកម្មខាងវិន័យដូចម្តេចខ្លះ? (២.២.២) ហើយបើនៅក្នុងរឿងព្រហ្មទណ្ឌវិញ តើព្រះរាជអាជ្ញាមានទំនួលខុសត្រូវដូចម្តេចខ្លះ? (២.២.៣)។

### ២.២.១ ភាតព្វកិច្ចដែលត្រូវអនុវត្ត

ព្រះរាជអាជ្ញាទាំងអស់ ក្នុងនាមជាតំណាងឱ្យអង្គការអយ្យការត្រូវប្រតិបត្តិនូវភារកិច្ចដែលថ្នាក់លើបានដាក់ជូនប្រកបដោយភាពម៉ឺងម៉ាត់ យ៉ាងរហ័សរហួនដោយស្របច្បាប់ ដោយតម្លាភាព និងប្រកបដោយសេចក្តីថ្លៃថ្នូរជានិច្ចដោយយពុំប្រាកចាកចេញពីច្បាប់លក្ខខន្តិកៈបានឡើយ។

ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ៖

- អនុវត្តតួនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយឡើយ។
- ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរង- គ្រោះដោយមិនលំអៀង និងត្រូវមានការប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធ ទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។
- រក្សារឿងក្តីជាសម្ងាត់ លើកលែងតែក្នុងករណីត្រូវបំពេញភារកិច្ច ឬករណីដើម្បីស្វែង រកយុត្តិធម៌ ។
- ពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះ ពាល់ដល់

ប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដើម្បីឱ្យស្របតាម សេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះ នៅក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច ។

បន្ថែមពីនេះក្នុងនាមជាតំណាងអយ្យការ ត្រូវប្រកាន់ខ្ជាប់នូវទង្វើត្រឹមត្រូវរាល់សកម្មភាពប្រចាំថ្ងៃផងដែរមិនត្រូវប្រព្រឹត្តនូវអំពើណាមួយដែលនាំឱ្យអាប់ឱន កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងកិត្យានុភាពនៃអង្គការអយ្យការរបស់ខ្លួន។ រាល់អត្ថបទ ឬឯកសារនានាដូចជាមតិផ្សេងៗដែលតំណាងអយ្យការនៅតាមអយ្យការសាលាដំបូងគ្រប់ជាន់ថ្នាក់ មានបំណងផ្សព្វផ្សាយដែលអាចប៉ះពាល់ដល់កិត្យានុភាពដល់ស្ថាប័នតុលាការអយ្យការ និងស្ថាប័នតុលាការត្រូវសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុនសិន ប៉ុន្តែលើកលែងតែការធ្វើ

[17] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៨/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៩៦ កថាខណ្ឌទី១

សេចក្តីថ្លែងការណ៍របស់ព្រះរាជអាជ្ញា ដោយអនុទ្បោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងវិស័យនយោបាយព្រះរាជអាជ្ញាត្រូវប្រកាន់ដាច់ខាតនូវអវិយាបទអព្យាក្រឹត្យ។[18]

ចំពោះការអវត្តមានរបស់ខ្លួននៅក្នុងឱកាសបំពេញមុខងារ គឺព្រះរាជអាជ្ញាមិនត្រូវបោះបង់ការងាររបស់ខ្លួនដោយមិនបានសុំការអនុញ្ញាតពីថ្នាក់លើផ្ទាល់បានឡើយ ពោលមុនពេលដែលអវត្តមានរបស់ខ្លួន ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាតុលាការកំពូល ត្រូវមានការសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[19] បើពុំនោះទេ ប្រសិនបើការចាកចេញដោយឥតច្បាប់និងគ្មានមូលហេតុច្បាស់លាស់មានរយៈពេលចាប់ពី ១៥ ថ្ងៃ ឡើងទៅ ព្រះរាជអាជ្ញារូបនោះនឹងត្រូវទទួលពិន័យផ្អាកមិនផ្តល់ជូននូវប្រាក់បៀវត្ស ឬដាក់ឱ្យគ្មានបៀវត្ស ដោយគិតចាប់ពីថ្ងៃដែលអវត្តមាននោះ។ ក្នុងករណីធ្ងន់ធ្ងរគឺត្រូវលប់ឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញារូបនោះបានបោះបង់ការងាររយៈពេលលើស ៣០ ថ្ងៃដោយគ្មានមូលហេតុ ហើយព្រះរាជអាជ្ញារូបនោះនៅតែមុនត្រឡប់ចូលមកបម្រើការងារវិញ ក្រោយដាក់កំហិតពីរដងរួចមកហើយនោះ។

### ២.២.២ ទណ្ឌកម្មខាងវិន័យ

មាត្រា៥៤ បានបញ្ញត្តិថា កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និការប៉ះពាល់ដល់កិត្តិយស សីលធ៌មស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកក្រសមសីលធ៌មរបស់ចៅក្រម និងព្រះរាជអាជ្ញានាំឱ្យមានទណ្ឌកម្មខាងវិន័យនៃច្បាប់នេះ។ ប៉ុន្តែការប្រាសចាកឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់ មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ ម្យ៉ាងវិញទៀតចំពោះបណ្តឹងអាជ្ញាគឺនៅតែដំណើរការទោះបីជាព្រះរាជអាជ្ញាទទួលទណ្ឌកម្មផ្នែលខាងវិន័យក៏ដោយ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយបានប្រព្រឹត្ត។[20] ក្នុងនេះមានន័យថាបើព្រះរាជអាជ្ញារូបណាបានប្រព្រឹត្តអំពីល្មើសដែលមានចែកក្នុងច្បាប់ព្រហ្មទណ្ឌនោះ ព្រះរាជអាជ្ញារូបនោះនៅតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ពោលគឺបណ្តឹងព្រហ្មទណ្ឌនៅតែដំណើរការទោះជាមានការដាក់ទណ្ឌកម្មខាងវិន័យដែលបានអនុវត្តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក៏ដោយក្តី។

ប៉ុន្តែមិនមែននូវរាល់សកម្មភាពខុសឆ្គងទាំងអស់របស់ព្រះរាជអាជ្ញា សុទ្ធតែទទួលនូវទណ្ឌកម្មដូចៗគ្នានោះទេគឺវាអាស្រ័យទៅតាមព្យសន្តកម្មដែលបានប្រព្រឹត្ត។ ដោយអនុទ្បោមតាមមាត្រា៥៥[21] ទណ្ឌកម្មខាងវិន័យមាន ២ (ពីរ) ថ្នាក់គឺ៖

ទណ្ឌកម្មថ្នាក់ទី១(មួយ)

- ការស្តីបន្ទោសដោយផ្ទាល់មាត់

---

[18] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៩៦ កថាខណ្ឌទី៣

[19] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៩៧

[20] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨ មាត្រា៥៤ កថាខណ្ឌទី២

[21] ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា នស/រកម/០៧១៤/០១៦ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៨

- ការស្ដីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឱ្យលើសពី ២ (ពីរ) ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែល មានចុះឈ្មោះរួចហើយ ។ ទណ្ឌកម្មថ្នាក់ទី ២(ពីរ)
- ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្ដុះបណ្ដាលបន្ថែម
- ការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី ១(មួយ) ឆ្នាំ
- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
- ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ
- ការបញ្ឈប់ពីមុខងារដោយបង្ខំ
- ការបណ្ដេញចេញពីក្របខណ្ឌ។

ទណ្ឌកម្មថ្នាក់ទី២(ពីរ) ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ។

**ផ្នែកទី៣ មុខការ របស់អង្គការអយ្យការ**

ឆ្លងតាមការបកស្រាយខាងលើរួចមក រចនាសម្ព័ន្ធរបស់ស្ថាប័នអយ្យការគឺស្ថិតនៅអមគ្រប់សាលាជម្រះក្ដីនានា ដូចនេះនៅក្នុងផ្នែកនេះយើងមកស្វែងយល់ពីមុខការ អយ្យការអមសាលាដំបូងរាជធានីខេត្ត (៣.១) មហាអយ្យការអមសាលាឧទ្ធរណ៍ (៣.២) និងមុខការ មហាអយ្យការអមតុលាការកំពូល (៣.៣)។

**៣.១ មុខការ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

**៣.១.១ អំណាចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

នៅក្នុងអង្គការអយ្យការអមសាលាដំបូងគឺ មានតែព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនោះទេដែលជាតំណាង។

ទោះបីជាព្រះរាជអាជ្ញារង ស្ថិតក្រោមអំណាចនៃការគ្រប់គ្រងរបស់ព្រះរាជអាជ្ញាតែ *ព្រះរាជអាជ្ញារងដែលស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងស់ដែលើព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស។*[22]

នៅក្នុងអង្គការអយ្យការ គឺអយ្យការអមសាលាដំបូង ជាអ្នកដែលបើកការស៊ើបអង្កេតបឋម ឬដំបូងដែលខ្លួនទទួលបាន។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចរបស់ខ្លួនទាំងអស់ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌក្នុងការដឹងនាំ និងសម្របសម្រួលប្រតិបត្តិការការរបស់មន្ត្រីនគរបាលយុត្តិធ៌មដែលនៅក្រោមយុត្តាធិការរបស់ខ្លួន។ ព្រះរាជអាជ្ញាចុះទៅកន្លែងស៊ើបអង្កេតដែលអាចមានប្រយោជន៍របស់មន្ត្រីនគរបាលយុត្តិធម៌ តែបើមានបញ្ហា

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៧

កើតឡើង ឬមិនប្រក្រតីណាមួយ ព្រះរាជអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធ៌មស៊ើបអង្កេតណាមួយដែលនៅក្រោមអំណាចរបស់ខ្លួន ជំនួសដោយមន្ត្រីណាផ្សេងទៀតដែលមានសិទ្ធិស៊ើបអង្កេត។

### ៣.១.២ សមត្ថកិច្ចដែនដីអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ចំណែកឯសមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា[23] វិញ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស។

ឧទាហរណ៍ ទីតាំងប្រព្រឹត្តបទល្មើសនៅទីក្រុងភ្នំពេញ ដូចនេះជាសមត្ថកិច្ចរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ឧទាហរណ៍ ជនល្មើសបានប្រព្រឹត្តបទល្មើសនៅទៅក្រុងភ្នំពេញ តែជនល្មើសមានទីលំនៅក្នុងខេត្តតាកែវ ដូចនេះជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងនៅខេត្តតាកែវបាន។ ករណីនេះអយ្យការអមសាលាដំបូងខេត្តតាកែវក៏មានសមត្ថកិច្ចផងដែរ។

- ព្រះរាជាអាជ្ញា នៃទីន្លែងចាប់ខ្លួនជនដែលត្រូវសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ឧទាហរណ៍ អំពើល្មើសបានប្រព្រឹត្តបទល្មើសនៅខេត្តកំពង់ឆ្នាំង តែត្រូវចាប់ខ្លួនបាននៅខេត្តតាកែវ ដូចនេះអយ្យការអមសាលាដំបូងខេត្តតាកែវ ក៏មានសមត្ថកិច្ចផងដែរ។ ក្នុងករណីនេះអយ្យការទាំងពីរគួរសម្របសម្រួលគ្នា ហើយសមត្ថកិច្ចគួរត្រូវប្រគល់ជូនអយ្យការអមសាលាដំបូងខេត្តតាកែវ ដើម្បីងាយស្រួលក្នុងការដំណើររឿងក្តី។

### ៣.២ មុខការ មហាអយ្យការអមសាលាឧទ្ធរណ៍

នៅមហាអយ្យការអមសាលាឧទ្ធរណ៍គឺមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជាអាជ្ញារង និងព្រះរាជអាជ្ញាជាតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។ តាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា[24]អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃ សាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយ ដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ដូចនេះមហាអយ្យការអមសាលាឧទ្ធរណ៍ មានតួនាទីចាំឃ្លាំមើលទៅលើអយ្យការទាំងឡាយដែលស្ថិតនៅក្រោមអំណាចសមត្ថកិច្ចរបស់ខ្លួន និងប្រើប្រាស់អំណាចទៅតាមគោលការណ៍ឋានានុក្រម។ ដោយការឃ្លាំមើលនោះទៀតសោត អគ្គព្រះរាជអាជ្ញាមានសិទ្ធិក្នុងការធ្វើអធិការកិច្ចទៅតាមអយ្យការរាជធានី-ខេត្ត ក្នុង

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣៩

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣៤

ករណីមានបទល្មើសធ្ងន់ធ្ងរប៉ះពាល់ដល់សន្តិសុខជាតិ គាត់ត្រូវរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជានាយឋានានុក្រមរបស់ខ្លួន។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវ នៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាល ទាំងនេះ និងអាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឱ្យបំពេញកិច្ច ទាំងឡាយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាល យុត្តិធម៌ អគ្គព្រះរាជអាជ្ញានេះអាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ និងអាចចូលរួមស្តាប់សម្លើយ ឬពិនិត្យការគោរពតាមច្បាប់នៃការឃាត់ខ្លួនរបស់នគរបាលយុត្តិធំម ឬការគ្រប់គ្រងកន្លែងឃាត់ខ្លួន។

ក្នុងករណីដែលមានកំហុសធ្ងន់ធ្ងរដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ដែលមានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកសេចក្តីអង្កេត នៃមន្ត្រីនគរបាលយុត្តិធំមនោះ។ បន្ទាប់ពីធ្វើការអង្កេតរួចហើយ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានឆន្ទានុសិទ្ធិចេញសេចក្តីសម្រេចហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ឬហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលជាជាស្ថាពរ។ ហើយធ្វើសេចក្តីសម្រេចបញ្ជូនទៅក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដែលជាក្រសួងសាម៉ីរបស់មន្ត្រីនគរបាលយុត្តិធំមនោះ[25]។

តែប្រសិនបើមន្ត្រីនគរបាលយុត្តិធំមនោះមិនសុខចិត្ត នូវសេចក្តីសម្រេចរបស់អគ្គព្រះរាជអាជ្ញា គឺគាត់អាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានសំអាងហេតុ ក្នុងកំឡុងរយៈពេល១៥ថ្ងៃ គិតចាប់ពីទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់នោះ។[26] បន្ទាប់ពីទទួលបានបណ្តឹងតវ៉ារបស់មន្ត្រីនគរបាលយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវសម្រេចសេចក្តីកនុងបណ្តឹងតវ៉ាខាងលើក្នុងរយៈពេល ១ ខែ បន្ទាប់ពីទទួលបានពាក្យ បណ្តឹងតវ៉ាក្នុងកំឡុងពេលនៃការធ្វើបណ្តឹងតវ៉ានោះ ហើយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចប្តឹងតវ៉ាបានឡើយ។ ក្នុងអំឡុងពេល មន្ត្រីនគរបាលយុត្តិធំមដែលត្រូវបានហាមឃាត់នោះ មិនអាចបំពេញមុខងាររបស់ខ្លួនបានឡើយ រាល់កិច្ចដែលមន្ត្រីនគបាលយុត្តិធំមបានបំពេញត្រូវចាត់ទុកជាមោឃៈ។[27]

### ៣.៣ មុខងារ មហាអយ្យការអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូល គឺជាស្ថាប័នដែលមាន អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាជាតំណាងមហាអយ្យការអមតុលាការកំពូល។[28] អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាសមាសភាព

---

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៦៦

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៦៦ កថាខណ្ឌទី៥

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៦៦ កថាខណ្ឌទី៧ និង៨

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣១

មួយរូបក្នុងចំណោមសមាជិកទាំង១១រូប នៃសមាជិកឧត្តមក្រុម ប្រឹក្សានៃអង្គចៅក្រម[29] ដែលមានព្រះមហាក្សត្រជាព្រះប្រធាន ហើយស្ថាប័ននេះមានតួនាទីចំបងក្នុងការតែងតាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះ និងការដាក់វិន័យទៅលើទាំងចៅក្រមអាសនៈ និងចៅក្រមអយ្យការទាំងអស់។[30] ចំណែកនៅក្នុងតួនាទីជំនុំជម្រះវិញ អយ្យការអមតុលាការកំពូល ជាអ្នកចូលរួមស្នើសុំឱ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសារទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗ ទៀត ដែលបានដាក់ជូនតុលាការកំពូលពិនិត្យ។[31]

---

[29][29] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, នស/រកម/០៧១៤/០១៧, ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៤

[30] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, នស/រកម/០៧១៤/០១៧, ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា១៨ និងមាត្រា២០

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣២

# ជំពូកទី ២
# កាលានុវត្តភាព នៃការចោទប្រកាន់
# របស់ព្រះរាជអាជ្ញា

# ជំពូកទី ២

# កាលានុវត្តភាព នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

យើងដឹងហើយថានៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង គឺមានតែព្រះរាជអាជ្ញាប៉ុណ្ណោះជាអ្នកដែលមានឆន្ទានុសិទ្ធិក្នុងការធ្វើបណ្ដឹងអាជ្ញា។ គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់បានផ្ដល់ឱ្យព្រះរាជអាជ្ញានូវសេរីភាព នៃការពិចារណានិងការថ្លឹងថ្លែង ពីការសម្រេចអំពីបណ្ដឹងអាជ្ញា។ ម៉្យាងវិញទៀតគោលការណ៍នេះក៏បានអនុញ្ញាតឱ្យព្រះរាជអាជ្ញា អាចតម្កល់រឿងទុកឥតចាត់ការ ទោះបីជាអំពើដែលបានប្ដឹង ឬបរិហានោះ ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ។ វិធាននៃគោលការណ៍នេះគឺផ្ទុយគ្នាពីគោលការណ៍នីត្យានុកូលភាពនៃបណ្ដឹង ដែលត្រូវបានអនុវត្តនៅក្នុងច្បាប់ ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវចោទប្រកាន់ នូវរាល់បទល្មើសព្រហ្មទណ្ឌដែល ខ្លួនបានដឹង[32]។ ចំណែកឯគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ គឺបានផ្ដល់ជាជម្រើសដ៏សំខាន់ ដល់ព្រះរាជអាជ្ញា នៅក្នុងការធ្វើចំណាត់ការសំណុំរឿង ដោយផ្អែកទៅលើទម្ងន់ទោសនៃបទល្មើស កាលៈទេសៈ នៃការប្រព្រឹត្ត ព្យសនកម្មដែលបង្កភាពរឹករវដល់សង្គម និងព័ត៌មានផ្សេងទៀតដែលប្រមូលបានពីការស៊ើបអង្កេត។ ដូចនេះនៅក្នុងជំពូកនេះយើងនឹងទៅសិក្សាអំពី ការតម្កល់រឿងទុកឥតចាត់ការ (ផ្នែកទី១) និងសម្រេចកាធ្វើការចោទប្រកាន់ (ផ្នែកទី២)។

## ផ្នែកទី ១ ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជានីតិវិធីមួយដែលកើតចេញគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់ ដែលក្នុងគោលការណ៍នេះបានផ្ដល់នូវអំណាចសម្រាប់ព្រះរាជអាជ្ញាអាចធ្វើការ ថ្លឹងថ្លែងក្នុងនាមជានិយ័តករនៃសង្គម ដើម្បីធ្វើការតម្កល់រឿងទុកឥតចាត់ការ។ យោងតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ តើតំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបានតាមរយៈអ្វីខ្លះ? ក្នុងការអនុវត្តខ្លះ យើងសង្កេតឃើញថា មានវិវាទរដ្ឋប្បវេណីមួយចំនួន ដែលមានលក្ខណៈស្រដៀង ឬប្រហាក់ប្រហែលទៅនឹងបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានគេបក ស្រាយឱ្យមានលក្ខណៈច្រឡំថា វាគឺជាបទល្មើសព្រហ្មទណ្ឌ ក្នុងគោលបំណងដើម្បីដាក់ឱ្យបណ្ដឹងមានចលនា ដូចជាក្នុងករណី អំពើឆបោក (តាមមាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី) និងបទល្មើសឆបោក (មាត្រា៣៧៧ នសក្រមព្រហ្មទណ្ឌ) ។ ដូចនេះដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីនីតិវិធីនេះយើងនឹងទៅយល់ដឹងអំពី មូលហេតុ (១.១) និតិវិធី (១.២) និងផលវិបាក (១.៣) នៃការតម្កល់រឿងទុកឥតចាត់ការ។

### ១.១ មូលហេតុ នៃការតម្កល់រឿងទុកឥតចាត់ការ

មូលហេតុដែលអាចនាំឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការមានច្រើន ដោយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ច្បាស់លាស់ទេ។ ប៉ុន្តែតាមរយៈការធ្វើចំណាំត់ការលើសំណុំរឿង ព្រះរាជអាជ្ញាអាចនឹងតម្កល់រឿងទុកឥតចាត់ការចំពោះស្ថានភាពដូចខាងក្រោម៖

[32] សៀវភៅមេរៀបនីតិវិធីព្រហ្មទណ្ឌ របស់សាស្ត្រាចារ្យ ហ៊ី សោភា

### ១.១.១ ការផុតរលត់ នៃបណ្តឹងអាជ្ញា

ជាទូទៅបណ្តឹងអាជ្ញាជាបណ្តឹងដែលមិនអាចរំលត់បានតាមឆន្ទៈរបស់គូភាគី ឬសម្រុះសម្រួលគ្នាតាមចិត្ត បានឡើយ។ ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏នៅមានបញ្ញត្តិខ្លះទាក់ទងទៅនឹង ការដែលអាចរួចផុតពីបណ្តឹងព្រហ្មទណ្ឌនេះ ដែលជាកម្មវត្ថុសម្រាប់ព្រះរាជអាជ្ញាមិនអាចដាក់បណ្តឹងអាជ្ញានេះឱ្យដំណើរការបាន ឬត្រូវបញ្ឈប់ការធ្វើដំណើរការបណ្តឹងអាជ្ញា។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ[33] បានបញ្ញត្តិថា មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅៈ

- មរណៈភាពនៃជនល្មើស ។
- ការផុតអាជ្ញាយុកាល។
- ការលើកលេងទោសជាទូទៅ។
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ។
- អាជ្ញាអស់ជំនុំ។

ក. **មរណៈភាពនៃជនរងគ្រោះ** នៅពេលដែលមានបទល្មើសមួយបាន គឺត្រូវតែមានជនល្មើសតែបើក្នុងករណីជនល្មើសបានទទួលមរណៈភាពបាត់ នោះវាជាកម្មវត្ថុក្នុងការដែលព្រះរាជអាជ្ញាមិនអាចដំណើរការបណ្តឹងអាជ្ញាបាននោះទេ។ ប៉ុន្តែ *ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹង រដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ។*

ខ. **ការផុតអាជ្ញាយុកាល** អាជ្ញាយុកាល គឺជារយៈពេលមួយដែលកំណត់ដោយច្បាប់ ដោយផុតរយៈពេលនេះជនរងគ្រោះអាចបាត់បងនូវអត្ថប្រយោជន៍ផ្សេងៗ។ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានរយៈពេល ១៥ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ឆ្នាំចំពោះបទមជ្ឈឹម និង១ឆ្នាំចំពោះបទលហុ។ ប៉ុន្តែចំពោះបទល្មើសដែលមិនមានអាជ្ញាយុកាលមានដូចជា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម។ ដូចគ្នានេះដែរ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែលជាអំពើអនីត្យានុកូលគឺ *ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល៣ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ... បានដឹងថាអាចទានទារសំណង ការខូចខាតចំពោះអ្នកព្រឹត្តនូវអំពើបំពាន ឬកំឡុងពេល១០ឆ្នាំបានកន្លងហួសទៅបន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង។*[34]

បទល្មើសមួយចំនួនយើងអាចរាប់អាជ្ញាយុកាលដូចជាៈ

- **បទល្មើសភ្លាមៗ**

---

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៧

[34] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧០/៣០ ប្រកាសឱ្យប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ,មាត្រា៧៦៥

បទល្មើសភ្លាមៗ គឺជាបទល្មើសដែលការប្រព្រឹត្តបានកើតឡើងភ្លាមៗមិនអូសបន្លាយ បានសេចក្តីថាជាបទល្មើសដែលការប្រតិបត្តិស្ថិតនៅក្នុងរយៈពេលយ៉ាងខ្លីដ៏បំផុត។

ឧទាហរណ៍៖ បទឃាតកម្ម (មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ), បទហិង្សាដោយចេតនា (មាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ) និងបទលួច (មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ)។ អាជ្ញាយុកាលនៃបទល្មើសត្រូវគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។

- **បទល្មើសនិរន្តរ៍**

បទល្មើសនិរន្តរ៍ គឺជាបទល្មើសដែលអូសបន្លាយដោយសារតែគំនិតទុច្ចរិតរបស់ជនល្មើស ឬគេអាចនិយាយម្យ៉ាងទៀតបានថា ជាបទល្មើសដែលសំដែងឡើងដោយអំពើនៃការប្រព្រឹត្តបទល្មើសអាចអូសបន្លាយក្នុងកាល ដោយស្ថិតនៅក្នុងអំឡុងពេលយូរ ឬឆាប់អាស្រ័យលើឆន្ទៈប្រព្រឹត្ត បទល្មើសរបស់ចារី។

ឧទាហរណ៍៖ បទប្រើប្រាស់ដោយខុសច្បាប់នូវសំលៀកបំពាក់ជាអាទិ៍សម្រាប់ អាជ្ញាធរសាធារណៈ (មាត្រា៦១២ នៃក្រមព្រហ្មទណ្ឌ), បទផិត (មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព) និងបទរក្សាទុកគ្រឿងផ្ទុះខុសច្បាប់ (មាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ)។ អាជ្ញាយុកាលនៃបទល្មើសនិរន្តរ៍នេះ ត្រូវគិតចាប់ពីថ្ងៃដែលរកឃើញបទល្មើសនោះ។

- **បទល្មើសជាទម្លាប់ ឬដដែល**

បទល្មើសជាទម្លាប់ ឬដដែល គឺជាបទល្មើសមួយ ដែលសំដៅដល់ការប្រព្រឹត្តដដែលៗនូវ អំពើតែមួយដូចគ្នា។ មានន័យថា អំពើទាំងនោះគឺមានលក្ខណៈដូចគ្នាៗ ហើយត្រូវបានប្រព្រឹត្តឡើង ម្តងហើយម្តងទៀតដោយដាច់ដោយឡែកពីគ្នា។ ឧទាហរណ៍៖ បទយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន (មាត្រា ២៩២ នៃក្រមព្រហ្មទណ្ឌ), បទគំរាមកំហែង (មាត្រា២៣១ នៃ ក្រមព្រហ្មទណ្ឌ) និងបទរុកកួនខាងផ្លូវភេទ (មាត្រា២៤៩ នៃក្រមព្រហ្មទណ្ឌ)។ បទល្មើសជាទម្លាប់ នេះ អាជ្ញាយុកាលរាប់ចាប់ពីថ្ងៃប្រព្រឹត្តបទល្មើសចុងក្រោយគេ ។

គ. **ការលើកលែងទោសជាទូទៅ** ត្រូវបានអនុវត្តតាមតាមច្បាប់ស្តីពីការលើកលែងទោស ដែលមានកំណត់នៅក្នុងមាត្រា៩០ នៃរដ្ឋធម្មនុញ្ញ។ ការលើកលែងទោសជាទូទៅអាចកំណត់ពី ដែនអនុវត្តផ្សេងៗដូចជាប្រភេទបទល្មើស រយៈពេលនៃទោស អាយុរបស់ទណ្ឌិតជាដើម។

ឃ. **ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ** ប្រសិនបើច្បាប់ព្រហ្មទណ្ឌ ដែលបានកំណត់បទល្មើសណាមួយត្រូវបាននិរាករណ៍ដោយច្បាប់ថ្មី ដែលបានលុបចោលបទល្មើសនោះ បណ្តឹងអាជ្ញាទាក់ទងនឹងបទល្មើសដែលបានក្នុងកំឡុងពេលនៅជាធរមាន។

ង. **អាជ្ញាអស់ជំនុំ** តាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១២ បានចែងថា *ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ។* តាមស្មារតីនៃបញ្ញត្តិនេះមាន

ន័យថាកាលបើជនណាម្នាក់បានទៅប្រព្រឹត្តបទល្មើសណាមួយ ហើយដោយពុំមានភស្តុតាងគ្រប់គ្រាន់អំពីការចោទប្រកាន់តុលាការ ក៏បានចេញសាលក្រមថាគ្មានទោសនិងបានចូលជាស្ថាពរ ដូចនេះអំពើនោះ គឺមិនអាចចោទប្រកាន់បុគ្គលនោះម្តងទៀតឡើយ នូវអំពើដដែលនោះទោះក្រោមឈ្មោះបទល្មើសផ្សេងក៏ដោយ។

- **ការសម្របសម្រួល** ជាគោលការណ៍ការសម្រុះសម្រួលមិនអាចធ្វើទៅបានឡើយ ចំពោះបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែនៅមានអញ្ញត្តិកម្មស្របតាមច្បាប់ពិសេសអាចអនុញ្ញាតឱ្យរំលត់បណ្តឹងអាជ្ញាបានផងដែរ។

ឧទាហរណ៍ ការពិន័យអន្តរការណ៍ (ចំពោះបទល្មើសចរាចរណ៍) និងមាត្រា២៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

- **ការដកពាក្យប្តឹង** អាចធ្វើទៅបានប្រសិនបើពាក្របណ្តឹងនៃជនរងគ្រោះ គឺជាលក្ខខណ្ឌនៃភាពចាំបាច់ក្នុងការឱ្យបណ្តឹងមានចលនា មានន័យថាបណ្តឹងខ្លះមិនអាចដំណើរការបានឡើយប្រសិនបើជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹង។

ឧទាហរណ៍ បទល្មើសទាក់ទងទៅនឹង បរិហារកេរ្តិ៍ និងជេរប្រមាថ តាមនីតិវិធីនៃបណ្តឹងនៃបទល្មើសនេះមាត្រា៣០៩ នសក្រមព្រហ្មទណ្ឌ គឺនីតិវិធីនៃបណ្តឹងអាចដំណើរការបានលុះត្រាតែមាពាក្យបណ្តឹងពីជនរងគ្រោះ។

### ១.១.២ អំពើមិនមែនជាបទល្មើស

រាល់បទល្មើសកើតឡើងហើយផ្តល់ព្យសនកម្ម មិនមែនសុត្ធតែជាបទល្មើសព្រហ្មទណ្ឌនោះទេ។ ហើយអំពើដែលបានកើតឡើងនោះទៀតសោតក៏មិនប្រកាដថាត្រូវផ្តន្ទាទោសឡើយ បានសេចក្តីថាគ្មានបទល្មើសឡើយ បើគ្មានច្បាប់ចែង។ បើយោងតាមក្រមព្រហ្មទណ្ឌមាត្រា៣ គោលការនីត្យានុកូលភាព បានចែងថា *មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះ មានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន*។ ដូចនេះមានន័យថាអំពើដែលមិនមែនជាបទល្មើសសំដៅដល់អវត្តមាន នៃបទល្មើស និងកង្វះធាតុផ្សំ នៃបទល្មើស។

ក. អវត្តមាន នៃបទល្មើស

នៅពេលដែលព្រះរាជអាជ្ញាកំពុងថ្លឹងថ្លែងពីបទល្មើសដែលបណ្តឹងនោះខ្លួនទទួលបានដោយផ្ទាល់ ឬជាបណ្តឹងដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធ៌មចប់សព្វគ្រប់ ព្រមទាំងបានបើកការស៊ើបអង្កេត ស្រាវជ្រាវរួចហើយ តែបណ្តឹងនោះមិនមានវត្តមាន នៃបណ្តឹងនោះទេ ព្រះរាជអាជ្ញាមានសិទ្ធិសម្រេចមិនធ្វើការចោទប្រកាន់។ អវត្តមាននៃបទល្មើស គឺសំដៅលើបទល្មើសដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ បណ្តឹងទាំងនោះ អាចជាបណ្តឹងរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម ឬវិវាទរដ្ឋបាលដែលតុលាការមិនអាចផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌបាន។

ខ. កង្វះធាតុផ្សំ នៃបទល្មើស

បន្ទាប់ពីបានទទួលពាក្យបណ្តឹង ឬពាក្យប្តឹងបរិហា ហើយព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋម ឬស៊ើបអង្កេតស្រាវជ្រាវបន្ថែមដើម្បីស្វែងរកនូវធាតុផ្សំនៃបទល្មើស។ ធាតុផ្សំនៃបទល្មើសមានបីគឺ៖

- **ធាតុផ្សំនីត្យានុកូល៖** គឺជាធាតុផ្សំទាក់ទងនឹងច្បាប់។ ក្នុងករណីអំពើមួយបានកើតមានឡើយ ហើយយើងអាចចាត់ទុកថានោះគឺជាបទល្មើសព្រហ្មទណ្ឌបាន លុះត្រាតែអំពើនោះ មានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៣ បានចែងថាអំពើលួចគឺជាបទល្មើសព្រហ្មទណ្ឌ។

- **ធាតុផ្សំសត្យានុម័ត៖** ឬធាតុផ្សំសម្ភារៈ គឺជាអង្គហេតុ ឬជាហេតុការណ៍ទាំងឡាយណាដែលបង្កឱ្យកើតមាននូវអាកប្បកិរិយាណាមួយ ដែលត្រូវបានកំណត់នៅក្នុងអត្ថបទច្បាប់ ដែលបញ្ជាក់ថាជាបទល្មើស។ អង្គហេតុទាំងនោះមានច្រើនណាស់ អាចជាអំពើសកម្ម និងជាអំពើអសកម្ម អំពើកើតឡើងភ្លាមៗ ឬអូសបន្លាយ អំពើកើតឡើងម្តងម្កាល់ ឬជាទម្លាប់ជាអាទិ៍។

- **ធាតុផ្សំអត្តនោម័ត៖** ជាផ្នែកខាងក្នុងនៃបទល្មើស។ គឺជាឆន្ទៈជាចេតនាឬអចេតនា ដែលជាអកប្បកិរិយាផ្លូវចិត្តរបស់អ្នកប្រព្រឹត្តចំពោះអំពើបង្កគ្រោះថ្នាក់។

ក្នុងករណីដែលអវត្តមាននៃធាតុផ្សំនៃបទល្មើសណាមួយ ព្រះរាជអាជ្ញាគ្មានអំណាចក្នុងការបើកការចោទប្រកាន់ឡើយ ព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### ១.១.៣ មូលហេតុគតិយុត្តផ្សេងទៀត

ក្រៅពីមូលហេតុខាងលើដែលអាចនាំឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ ក៏នៅមានមូលហេតុផ្សេងទៀត ដែលបានបញ្ញត្តិក្នុងច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជាផងដែរ ជាបច្ច័យក្នុងការដែលព្រះដាក់ឱ្យបណ្តឹងមិនដំណើរការមានដូចជា៖

ក. ការមានអភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិ គឺជាសិទ្ធិពិសេសរបស់បុគ្គលណាមួយដែលមានច្បាប់បញ្ញត្តឱ្យ អំពីលក្ខខណ្ឌពិសេសទាក់ទងនឹងនីតិវិធី ការទទួលខុសត្រូវ ឬការទទួលបាននូវស្ថានសម្រាលចំពោះការប្រព្រឹត្តបទល្មើសណាមួយ។ តាមរយៈបញ្ញត្តពិសេសនេះដែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង បានផ្តល់ឱ្យតែចំពោះបុគ្គលមួយចំនួនតែប៉ុណ្ណោះ។ ជាក់ស្តែង មាត្រា៨០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា តំណាងរាស្ត្រមានអភ័យឯកសិទ្ធិ តំណាងរាស្ត្រណាក៏ដោយក៏មិនត្រូវបានចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬឃុំខ្លួនបាន ឡើយ លុះត្រាមានការយល់ព្រមពីរដ្ឋសភានៅក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា។ នៅមានបុគ្គលមួយចំនួនទៀតដូចជា ព្រះមហាក្សត្រ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា តំណាងទូត និងមានអភ័យឯកសិទ្ធិគ្រួសារចំពោះបទល្មើសលួច។ គួរបញ្ជាក់ផងដែរថា ការមិនចោទប្រកាន់ចំពោះបុគ្គលដែលមានអភ័យឯកសិទ្ធិនេះ មិនមែនជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ គឺគ្រាន់តែជាមូលហេតុគតិយុត្តផ្សេងទៀត ដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការតែប៉ុណ្ណោះ។

ខ. គ្មានពាក្យបណ្តឹងពីជនដែលច្បាប់បានកំណត់

អំពើដែលច្បាប់បានកំណត់ថា ជាបទល្មើសដរាបណាច្បាប់បានកំណត់ដោយជាក់លាក់ ថាវាពិតជាបានធ្វើឱ្យសង្គមល្អក់កករ ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់របស់សង្គម។ ដោយឡែកអំពើមួយចំនួនបានប៉ះពាល់លើកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល ដូចជាបទបរិហាកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩) និងអំពើបរិហាតាមសារព័ត៌មាន (មាត្រា៣០៦) បទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧) និងអំពើជេរប្រមាថតាមសារព័ត៌មាន (មាត្រា៣០៨) អាចធ្វើការចោទប្រកាន់ទៅបាន លុះត្រាតែមានបណ្តឹងពីជនដែលច្បាប់បានកំណត់។ បានសេចក្តីថា ករណីទាំងនោះត្រូវធ្វើឡើងតាមបណ្តឹងនៃសាមីបុគ្គល។ ក្នុងករណីមាន បទបរិហា ឬការជេរប្រមាថលើមន្ត្រីរាជការ សមាជិករាជរដ្ឋាភិបាល ឬពលរដ្ឋទទួលបន្ទុកបេសកកម្មសាធារណៈ បណ្តឹងត្រូវឡើងពីប្រធានស្ថាប័ន។

គ. អនិយ័តភាពក្នុងនីតិវិធី

អនិយ័តភាព សំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធីក្នុងដំណើរប្រតិបត្តិការ របស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ឬក្នុងការស្រាវជ្រាវបន្ថែម របស់នគរបាលយុត្តិធម៌ ដែលវាហាក់មានភាពមិនស្របនឹងនីតិវិធីនៃច្បាប់ និងមិនបានលទ្ធផល ឬគ្មានប្រយោជន៍។ ព្រះរាជអាជ្ញាអាចសំអាងលើមូលហេតុនេះ ដើម្បីចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។

## ១.២ នីតិវិធី និងអានុភាព នៃការតម្កល់រឿងទុកឥតចាត់ការ

នីតិវិធី នៃការតម្កល់រឿងទុកឥតចាត់ការត្រូវធ្វើឡើងតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។ ដោយទម្រង់ នៃដីកាតម្កល់រឿងទុកឥតចាត់ការមានចំណុចសំខាន់ៗចំនួន ០២ គឺ ៖ សំអាងហេតុ និងសំអាងច្បាប់ ដើម្បីមានភាពត្រឹមត្រូវ និងច្បាស់លាស់តាមច្បាប់ ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការចាំបាច់ត្រូវមានធាតុទាំងពីរនេះ។ សំអាងហេតុ សំដៅលើការលើកយកនូវអង្គហេតុទាំងឡាយដែលពាក់ព័ន្ធមក ធ្វើជាសំអាង ព្រមទាំងមានការវិនិច្ឆ័យគ្រប់ជ្រុងជ្រោយរបស់ព្រះរាជអាជ្ញា ដែលនាំឱ្យមានការសម្រេចតម្កល់រឿង ទុកឥតចាត់ការ។ រីឯសំអាងច្បាប់ គឺជាការលើកយកនូវបញ្ញត្តច្បាប់មកធ្វើជាទឡ្ហៈករណ៍ ដើម្បីសម្រេចមិនធ្វើការ ចោទប្រកាន់។

ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងតាមនីតិវិធីមួយយ៉ាងច្បាស់លាស់ ត្រឹមត្រូវតាមទម្រង់នៃដីកា ដើម្បីឱ្យដីកាសម្រេចនោះមានអានុភាពក្នុងការអនុវត្ត។

### ១.២.១ នីតិវិធី នៃការតម្កល់រឿងទុកឥតចាត់ការ

បន្ទាប់ពី ព្រះរាជអាជ្ញាសម្រេចមិនធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវធ្វើចេញនូវសេចក្តីសម្រេចមួយតាមរយៈដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ព្រះរាជអាជ្ញា ត្រូវជូនដំណឹងទៅដល់អ្នកប្តឹងវិញយ៉ាងយូរបំផុត រយៈពេល២ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងនៅក្នុងបញ្ជី១១ ដោយធ្វើឡើងតាមរយៈលិខិតជូនដំណឹង។ របស់ការជូនដំណឹងនេះ ធ្វើឡើងក្នុងគោលបំណងគោរពដល់ដើមបណ្តឹង ដើម្បីឱ្យគេបានទទួលពីសេចក្តីសម្រេច ព្រះរាជអាជ្ញា ដែលបានសម្រេចលើបណ្តឹងរបស់ខ្លួន ហើយដើម្បីធានានូវសិទ្ធិដើមបណ្តឹងក្នុងការតវ៉ា ទៅនឹងសេចក្តីមសម្រេចនេះផងដែរ។ រយៈពេលនៃការឱ្យដំណឹងគឺយ៉ាងយូរបំផុត គឺ២ខែ គិតចាប់ពីថ្ងៃចុះពាក្យ

បណ្តឹងក្នុងបញ្ជី ដែលបញ្ជីនោះជាបញ្ជីអយ្យការសម្រាប់ចុះបណ្តឹងនៅតាមតុលាការជាន់ដំបូងនីមួយៗ ហើយស្ថិតនៅក្រោមការកាន់កាប់របស់លេខាធិការរបស់អយ្យការ និងក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាផ្ទាល់។ ការឱ្យដំណឹងដល់ដើមបណ្តឹងកាន់តែឆាប់គឺកាន់តែល្អ ដើម្បីឱ្យគេមានពេលវេលាគ្រប់គ្រាន់ សម្រាប់ការពិចារណាទៅលើសេចក្តីសម្រេចនេះ ថាតើគួរទទួល ឬក៏ធ្វើការប្តឹងតវ៉ា។

### ១.២.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គ្មានអាជ្ញាអស់ជំនុំទេ។ មានន័យថា ប្រសិនបើព្រះរាជអាជ្ញាសម្រេច មិនធ្វើការប្រកាន់ មិនមែនបានសេចក្តីថាជននោះរួចផុតពីការចោទប្រកាន់ជាស្ថាពរនោះទេ ក្នុងករណីដែលព្រះ រាជអាជ្ញាស្វែងរក ឬទទួលបាននូវភស្តុតាងថ្មីសម្រាប់ធ្វើការដាក់បន្ទុក ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់សារជាថ្មីបានម្តងទៀត លើកលែងតែផុតរលត់បណ្តឹងអាជ្ញា។ ការកំណត់អាជ្ញាអស់ជំនុំមិនអាចស្តែងបានឡើយ ព្រោះវាជាការផ្តោតតែលើការសម្រេចដោយឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា ដែលបានធានាដល់សិទ្ធិរបស់ជនរងគ្រោះនៃអំពើល្មើស ដើម្បីឱ្យមានការសើរើឡើងវិញចំពោះការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាធ្វើការសម្រេចដោយមានការខុសឆ្គង ឬមានចន្លោះប្រហោងត្រង់ចំណុចណាមួយ។

## ផ្នែកទី ២ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

បន្ទាប់ពីទទួលបានពាក្យបណ្តឹង ព្រះរាជអាជ្ញាថ្លឹងថ្លែងបានឃើញថា ពាក្យបណ្តឹងគឺមានលក្ខណៈពេញលេញគ្រប់គ្រាន់ ត្រឹមត្រូវតាមផ្លូវច្បាប់ក្នុងការដាក់ឱ្យដំណើរការហើយ នោះព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បានតាមរយៈ ០៣ រូបភាព បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា មាត្រា៤៣ *ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម៖*

- *ការបើកការស៊ើបសួរ*
- *ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ*
- *តាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ។*

### ២.១ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាជម្រើសរបស់ព្រះរាជអាជ្ញាក្នុងការធ្វើបណ្តឹងអាជ្ញា។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាដាច់ខាតត្រូវតែបើកការស៊ើបសួរ។[35] ហើយការបើកការស៊ើបសួរនេះទៀតសោត ធ្វើឡើងតាមរយៈការបញ្ជូនរឿងឱ្យស៊ើបសួរ រយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរ។ តាមរយៈការបញ្ជូនដីកាស៊ើបសួរនេះត្រូវរួមមាន សេចក្តីសង្ខេបនៃអង្គហេតុ ការកំណត់ឈ្មោះនៃបទល្មើស ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។ ភាពដាច់ខាតចំពោះការបើកការស៊ើបសួរទៅលើបទឧក្រិដ្ឋនេះ មិនបានស្តែងឡើងក្នុងករណី បទល្មើសជាបទមជ្ឈិមមិនជាក់ស្តែង ឬបទលហុទេ មានន័យថាតំណាងអយ្យការអាចធ្វើការចោទប្រកាន់ជម្រើសផ្សេងក្រៅពីការស៊ើបសួរ។ ទោះជាយ៉ាងណា

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៤

តំណាងអយ្យការនៅតែអាចធ្វើការចោទប្រកាន់តាមរយៈការស៊ើបសួរ ក្នុងករណីសំណុំរឿងមិនអាចធ្វើការជំនុំជម្រះបានដោយសារកត្តាផ្សេងៗដូចជា ក្នុងករណីតំណាងអយ្យការយល់ឃើញថា ភស្តុតាងដែលប្រមូលបានពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីជំនុំជម្រះ ឬតំណាងអយ្យការមិនស្គាល់នូវអត្តសញ្ញាណនៃចារី ដែលជាហេតុមិនអាចយកសំណុំរឿងទៅជំនុំជម្រះបាន ព្រោះចារីជាអញ្ញាតជន។ ដូចនេះ ព្រះរាជអាជ្ញាអាចនឹងបើកការស៊ើបសួរ ដើម្បីកំណត់ពីអត្តសញ្ញាណនៃចារីសិន ឬក៏ដើម្បីប្រមូលនូវភស្តុតាងបន្ថែម ទៀតសម្រាប់ដំណើរការនីតិវិធី។ ការបើកការស៊ើបសួរអាចធ្វើឡើងតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (២.១.១) ឬ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (២.១.២)។

### ២.១.១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ គឺជានីតិវិធីធម្មតាមួយនៃការបើកការស៊ើបសួរ។ ចៅក្រមស៊ើបសួរជាអ្នកស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក សម្រាប់ទាំងភាគីរងគ្រោះ និងភាគីត្រូវគេចោទ ដើម្បីស្វែងរកយុត្តិធម៌ពិតប្រាកដ ក្នុងនាមជាអំណាចវិនិច្ឆ័យ ដែលខុសគ្នាពីព្រះរាជអាជ្ញាដែលជាអ្នកតំណាងឱ្យផលប្រយោជន៍សមូហភាព។ ដូចនេះ ចៅក្រមស៊ើបសួរត្រូវតែអព្យាក្រឹតឯករាជ្យ ក្នុងតួនាទីភារកិច្ចរបស់ខ្លួនក្នុងការស្វែងរកភស្តុតាងទាំងឡាយ ណាដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីជាប្រយោជន៍បង្ហាញការពិត។ ជាគោលការណ៍ ចៅក្រមស៊ើបសួរមិនអាចបើកការស៊ើបសួរណាមួយដោយគ្មានដីកាបញ្ជូន រឿងឱ្យស៊ើបសួរពីតំណាងអយ្យការឡើយ។ ចៅក្រមស៊ើបសួរ មានសមត្ថកិច្ចស៊ើបសួរត្រឹមតែអង្គហេតុដែលបានចង្អុលបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដែលបានចង្អុលបង្ហាញក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរឬអាចប្រឆាំងចំពោះជនដែលមិនស្គាល់អត្តសញ្ញាណដែលជាអញ្ញាតជន។ ក្នុងករណីមានលេចឡើងនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅតំណាងអយ្យការដើម្បីពិនិត្យ និងផ្តើមធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។ ការស៊ើបសួរលើអង្គហេតុថ្មីនេះ ពុំអាចប្រព្រឹត្តទៅបានឡើយ ប្រសិនជាគ្មានដីកាបញ្ជូន រឿងឱ្យស៊ើបសួរបន្ថែម។ តែប្រសិនជាអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីមុននោះទេ ចៅក្រមស៊ើបសួរអាចធ្វើ ការស៊ើបសួរតាមផ្លូវច្បាប់ដោយពុំចាំបាច់ជូនដំណឹងទៅតំណាងអយ្យការឡើយ។

### ២.១.២ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ការស៊ើបសួរដែលបើកតាមរយៈជនរងគ្រោះគឺជានីតិវិធីថ្មីមួយ ដែលក្រមនីតិវិធីយើងបានបញ្ជូនហើយមានហេតុផលមួយចំនួនថាមូលហេតុអ្វីបានជាជនរងគ្រោះត្រូវបានផ្តល់សិទ្ធិដើម្បីបើក ការស៊ើបសួរបានផងដែរ។ ការបើកការស៊ើបសួរដោយជនរងគ្រោះនេះ គឺមានតែផ្លូវមួយប៉ុណ្ណោះ គឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ តើហេតុផលដូចម្តេចបានជា ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ព្រោះក្នុងទំនាក់ទំនងបទល្មើស ជនរងគ្រោះ គឺជាអ្នកទទួលរងនូវព្យសនកម្មដោយផ្ទាល់ពីបទល្មើស។

កាលណាបទល្មើសមួយកើតឡើងបុគ្គលឯកជនគឺជាអ្នកទទួលរងព្យសនកម្មដោយផ្ទាល់ហើយសង្គមក៏ជាជនរងគ្រោះប្រយោលដែរ។ ដូចនេះហើយ ទើបសង្គមជាអ្នកដើរតួនាទីសំខាន់ក្នុងការធ្វើបណ្តឹងអាជ្ញា តែពេលខ្លះជនរងគ្រោះ មិនពេញចិត្តនឹងការអនុវត្តណាមួយ ហេតុនេះក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់សិទ្ធិឱ្យគាត់អាច តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យបណ្តឹងអាជ្ញាមានចលនា។

ដូចនេះ ជនរងគ្រោះអាចធ្វើបណ្តឹងបានពីរប្រភេទ គឺបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញា។ តែជាទូទៅគាត់ធ្វើបណ្តឹងតែមួយប៉ុណ្ណោះ គឺបណ្តឹងទាមទារសំណងផ្នែករដ្ឋប្បវេណី ប៉ុន្តែក្នុងករណីពិសេសគាត់អាចធ្វើការចាត់ចែងមួយផ្នែកទៅលើបណ្តឹងអាជ្ញានេះគឺជាយន្តការថ្មីរបស់ក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីពិសេសដូចជាកាលណាជនរងគ្រោះអាចដាក់ពាក្យប្តឹងទៅអយ្យការ តែអយ្យការយល់ថាជារឿងព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែគាត់ក៏យល់ថាមិនគួរធ្វើការចោទប្រកាន់ មានន័យថា ព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះរឿងហេតុដែលបង្កើតបានជាបទល្មើសព្រហ្មទណ្ឌក្នុងកាលៈទេសៈបែបនេះ តើជនរងគ្រោះមានជម្រើសអ្វីខ្លះ ដើម្បីគាត់អាចទទួល បានសំណងពីការខូចខាតបាន និងទាមទារឱ្យមានការផ្តន្ទាទោសទៅលើជនល្មើស។ ក្នុងស្ថានភាពនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ ២ វិធី គឺទី១គាត់អាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចតម្កល់ រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាទៅនាយហានានុក្រមរបស់ព្រះរាជអាជ្ញា គឺ អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែចាប់ពីពេលដែលខ្លួនបានទទួលការជូនដំណឹងពីការសម្រេចតម្កល់រឿងទុកឥតចាត់ការ ពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាមានតួនាទីត្រូវជូនដំណឹងនេះក្នុងរយៈ ពេលដ៏ខ្លីបំផុត និងយ៉ាងយូរ ២ ខែ ចាប់តាំងពីថ្ងៃសម្រេច។ ជាគោលការណ៍សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាមិនមានអាជ្ញាអស់ជំនុំទេ មានន័យថានៅពេលគាត់សម្រេច ហើយ គាត់ក៏នៅតែអាចយករឿងនោះមកសើរើកែប្រែនៅថ្ងៃក្រោយក៏បាន ប្រសិនបើបណ្តឹងអាជ្ញាមិនទាន់ផុតរលត់។

ដូចបានបញ្ជាក់ពីខាងលើក្នុង គោលការណ៍ឋានានុក្រម គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិបញ្ញាជាលាយលក្ខណ៍អក្សរ បញ្ជាឱ្យព្រះរាជអាជ្ញាសើរើរឿងក្តីមកចោទប្រកាន់វិញបាន។ ប៉ុន្តែនៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទទួលបានពាក្យប្តឹង គាត់អាចយល់ស្របនឹងពាក្យប្តឹងរបស់ជនរងគ្រោះគឺគាត់យល់ស្របឱ្យមានការចោទប្រកាន់ក៏ប៉ុន្តែគាត់ក៏អាចយល់ស្របនឹងព្រះរាជអាជ្ញាថា គួរធ្វើការតម្កល់រឿងទុកឥតចាត់ការ។ ដូចនេះក្នុងករណីដែល គាត់យល់ស្របនឹងព្រះរាជអាជ្ញា ជនរងគ្រោះនៅមានផ្លូវមួយទៀត គឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់ឱ្យបណ្តឹងអាជ្ញាអាចដំណើរការបាន។

នៅពេលដែល ចៅក្រមស៊ើបសួរទទួលបានបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវបញ្ជូនសំណុំរឿងនោះទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ ប្រសិនជាព្រះរាជអាជ្ញាយល់ឃើញថាគួរតែចោទប្រកាន់ គាត់អាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ប៉ុន្តែប្រសិនជាព្រះរាជអាជ្ញាមិនឯកភាព គាត់អាចធ្វើការស្នើសុំមកចៅក្រម ដើម្បីកុំឱ្យស៊ើបសួរ។ ដូចនេះចៅក្រមស៊ើបសួរមានជម្រើសក្នុងកាសម្រេចមិនបើកការស៊ើបសួរ ឬបើកការស៊ើបសួរតាមបណ្តឹងជនរងគ្រោះ ព្រោះគាត់ឯករាជ្យដោយមិនស្ថិតនៅក្រោមការបញ្ជារបស់

ព្រះរាជអាជ្ញា។ ក្នុង ករណីនេះ ការស៊ើបសួរត្រូវបានចាប់ផ្តើមហើយ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចបើកការស៊ើបសួរ។ ប៉ុន្តែដើម្បីជាការការពារផលប្រយោជន៍មួយចំនួនដល់បុគ្គលដែលពាក់ព័ន្ធក្នុងសំណុំរឿង និងជៀសវាងការធ្វើបណ្តឹងដោយមានការរំលោភបំពាន ចៅក្រមស៊ើបសួរអាចតម្រូវឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុកក្នុងចំនួនណាមួយតាមការកំណត់របស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរក៏អាចលើកលែងការបង់ប្រាក់តម្កល់ទុកបានដែរ ប្រសិនជាគាត់ពិនិត្យឃើញថាជនរងគ្រោះពុំមានលទ្ធភាព។

ការបង់ប្រាក់តម្កល់ទុក គឺមានអត្ថប្រយោជន៍របស់វាក្នុងកិច្ចស៊ើបសួរនេះ ព្រោះនៅពេល ដែលចៅក្រមស៊ើបសួរទទួលបណ្តឹងហើយ ប្រសិនបើគាត់ធ្វើការស៊ើបសួរទៅ និងសម្រេចបិទការស៊ើបសួរវិញហើយនៅតែមិនឃើញមានបទល្មើសកើតឡើងដូចបណ្តឹងរបស់ជនរងគ្រោះ ដូចនេះ ការធ្វើបណ្តឹងនោះគឺធ្វើឡើងដោយបំពានដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។ ដើម្បីជាការធានា ការពារកុំឱ្យមានការធ្វើបណ្តឹងតាមចិត្ត ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី ដែលមានតម្លៃមិនលើសពីទឹកប្រាក់តម្កល់ទុកនោះ។ ការសម្រេចកាត់យកនេះ គឺជាទណ្ឌកម្មពិន័យស៊ីវិល ។ ចំណែកឯ បុគ្គលដែលមានឈ្មោះនៅក្នុងសំណុំ រឿងដែលត្រូវគេប្តឹង ទទួលរងការប៉ះពាល់ដល់កិត្តិយស មានសិទ្ធិប្តឹងបកដើម្បីទាមទារយកសំណងរដ្ឋប្បវេណីវិញ។ ដូចនេះជនរងគ្រោះត្រូវតែធ្វើការថ្លឹងថ្លែងឱ្យច្បាស់លាស់មុននឹងធ្វើការដាក់ពាក្យ ប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវមានការជឿជាក់ថាបទល្មើសពិតជាបានកើតឡើង
មែន ហើយបើមានភស្តុតាងមកធ្វើជាទឡ្ហីករណ៍កាន់តែល្អ។

**២.២ ការបញ្ជូនទៅជម្រះផ្ទាល់**

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវបានបើកតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ (២.២.១)។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់គឺមានព័ត៌មានចាំបាច់មួយចំនួនអំពីជនជាប់ចោទ និងសវនាការជាដើម។ ចំណែកឯនីតិវិធីក្នុងការប្រគល់ដីកា (២.២.២) គឺអាចធ្វើឡើងតាមរយៈមន្ត្រីមានសមត្ថកិច្ចមួយចំនួនផងដែរ។

**២.២.១ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នៅពេលដែលតំណាងអយ្យការថ្លឹងថ្លែងនិងយល់ថា ក្នុងសំណុំរឿងមានភស្តុតាងគ្រប់គ្រាន់សមល្មមអាចបញ្ជូនទៅជំនុំជម្រះផ្ទាល់ នោះព្រះរាជអាជ្ញានឹងចេញដីកាមួយហៅថា ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយតាមរយៈដីកានេះ គឺបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង[36] តែប៉ុណ្ណោះ ដោយមិនអាចប្រើនៅក្នុងតុលាការដែលជាតុលាការជាន់ខ្ពស់បាននោះឡើយ ព្រោះដោយសារការប្តឹងតវ៉ា គឺសុទ្ធសឹងតែត្រូវការស៊ើបសួរដើម្បីស្វែងរកភស្តុតាងបន្ថែម ដើម្បីបំពេញចំណុចខ្វះចន្លោះ នៃកម្មវត្ថុ នៃបណ្តឹងតវ៉ានោះ ដែលផ្ទុយពីនីតិវិធីជំនុំជម្រះផ្ទាល់ ជានីតិវិធីមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់រួចហើយ។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវមានកំណត់នូវអត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គ

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៦

ហេតុ ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើស ជាពិសេសត្រូវមានការចង្អុលបង្ហាញប្រាប់ពីតុលាការដែលត្រូវជំនុំជម្រះ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងពេលវេលា នៃសវនាការ។ ការជំនុំជម្រះផ្ទាល់ គឺអាចអនុវត្តបានក្នុងករណីបទមជ្ឈិម ឬបទលហុ ដែលជាបទល្មើស មានលក្ខណៈស្រាល ហើយបទល្មើសនោះគឺត្រូវមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់។ នៅក្នុងដីកា សេចក្តីសង្ខេប នៃអង្គហេតុ ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើស ជាពិសេសត្រូវមាន ការចង្អុលបង្ហាញប្រាប់ពីតុលាការដែលត្រូវជំនុំជម្រះ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងពេលវេលា នៃសវនាការ។ ម្យ៉ាងវិញទៀត ដីកានោះត្រូវមានបញ្ជាក់ថាជនជាប់ចោទអាចរកមេធាវីដើម្បីអមខ្លួនបាន។

## ២.២.២ ការប្រគល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ការប្រគល់ដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះទៅជនជាប់ចោទ អាចធ្វើឡើងដោយព្រះរាជអាជ្ញា ឬអាជ្ញាសាលា ដោយការប្រគល់ជូនដោយព្រះរាជអាជ្ញាត្រូវប្រគល់ដីកាជូនទៅជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា និងមានការចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដើមដីកា ព្រមដោយមានការចុះហត្ថលេខានៅលើដើមដីកានេះ[37]។ ចំពោះការប្រគល់ដីកាដោយអាជ្ញាសាលា ត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះ បានទៅដល់ជនជាប់ចោទដោយផ្ទាល់ដៃ[38] ប្រសិនបើអាជ្ញាសាលាបានជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះឬនៅកន្លែងផ្សេងទៀតអជ្ញាសាលាត្រូវប្រគល់ចុងដីកា ដល់សាម៉ីខ្លួនដោយចារលើសេចក្តីដើមដីកាថាបានប្រគល់ដីកាដល់ជនជាប់ចោទដោយផ្ទាល់ដៃ និងមានការចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ចុងដីកា ព្រមទាំងហត្ថលេខាជនជាប់ចោទនៅលើដើមដីកាផងដែរ ហើយដើមដីកាត្រូវបង្វិលត្រឡប់ទៅព្រះរាជអាជ្ញាវិញភ្លាម។[39] ម្យ៉ាងវិញទៀតការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចធ្វើឡើងដោយក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញាផងដែរ[40]។ ក្នុងករណីជនជាប់ចោទវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវអនុវត្តនិតិវិធីការប្រគល់ចុងដីកាដូចទៅនឹង នីតិវិធីជនជាប់ចោទវត្តមានដែរ ប៉ុន្តែត្រូវប្រគល់ឱ្យដល់បុគ្គលទាំងឡាយជានីតិជន ដែលស្ថិតនៅលំនៅឋាននោះ។ ករណីមួយទៀតដែលជនជាប់ចោទរឹងទទឹងមិនព្រមទទួលនូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់ នៅទីលំនៅឋានរបស់ជនជាប់ចោទគ្មានបុគ្គលណាម្នាក់មានវត្តមាន និងពុំមានបុគ្គលណាម្នាក់នៅទីលំនៅឋានរបស់ជនជាប់ចោទយល់ព្រមទទួលដីកា នោះអាជ្ញាសាលាប្រគល់ចុងដីកាឱ្យទៅដល់មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រង ដោយមានការចុះនិទ្ទេស អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលទទួលបានចុងដីកាព្រមទាំងកាលបរិច្ឆេទ នៃការប្រគល់ដីកា និងហត្ថលេខាអ្នកទទួលផងដែរ។ ម្យ៉ាងវិញទៀត ដីកានោះត្រូវមានបញ្ជាក់ថា

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៥៨

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៥៩

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៦០

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៦៣ កថាខណ្ឌទី២

ជនជាប់ចោទអាចរកមេធាវីដើម្បីអមខ្លួនបាន។ ចំរវេលានៃការបញ្ជូនដីកាកោះហៅ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួនជនជាប់ចោទនៅចំពោះ មុខតុលាការះ

- មានរយៈពេល ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់ តុលាការជាន់ដំបូង
- មានរយៈពេល ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀត នៃព្រះរាជាណាចក្រកម្ពុជា
- មានរយៈពេល ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននឹងកម្ពុជាមានរយៈពេល ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងផ្សេង ក្រៅពីករណីខាងលើ។[41]

### ២.៣. ការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម

នៅក្នុងនីតិវិធី នៃបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ដែលអាចដែលងាចនាំខ្លួនជនជាប់ចោទមកបង្ហាញខ្លួនចំពោះមុខតុលាការជាន់ដំបូង និងត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ដោយស្របតាមលក្ខខណ្ឌ (២.៣.១) តាមមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធី នៃការបង្ហាញខ្លួនភ្លាម (២.៣.២ ) តាមមាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

#### ២.៣.១ លក្ខខណ្ឌ នៃការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម

លក្ខខណ្ឌ នៃការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ត្រូវបានកំណត់តាមមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះព្រះរាជអាជ្ញា អាចធ្វើការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការមានជាអាទិ៍ះ

**បទល្មើសត្រូវតែជាបទល្មើសជាក់ស្តែង៖** បានចង្អុលបង្ហាញទៅមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ដែលបានចែងថា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ជាបទល្មើសដែលកំពុងប្រព្រឹត្ត ទើបប្រព្រឹត្តរួចភ្លាម ឬកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យត្រូវបានសាធារណជនស្រែកដេញប្រជាប់ចាប់ប្រកឹង បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើស។ មាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ដែលបានចែងថា គឺចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ ទោះបីជាស្ថិតនៅក្រៅករណីដែលមានចែងក្នុងមាត្រា៨៦(និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះសុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៥៧

**ការផ្តន្ទាទោស៖** បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច មួយឆ្នាំ និងយ៉ាងច្រើនប្រាំឆ្នាំ។ ចិរវេលានៃការផ្តន្ទាទោសនេះ យើងត្រូវមើលទៅលើអតិបរមា នៃទោសដែលបានចែងក្នុងច្បាប់។ បទមជ្ឈិមមានការផ្តន្ទាទោសជាអប្បបរមា ១ ឆ្នាំ និងអតិបរមា ៥ ឆ្នាំ។

**ជនជាប់ចោទជានីតិជន៖** មានន័យថាការដែលជនជាប់ចោទត្រូវដល់នីតិភាពគ្រប់គញ្ញាន់តាមផ្លូវច្បាប់ ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ។ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលការជំនុំជម្រះមានភាពឆាប់រហ័សជាងនីតិវិធីដទៃទៀត ហើយក្នុងនីតិវិធីនេះ តុលាការអាចសម្រេចឱ្យមានការឃុំខ្លួនបណ្តោះអាសន្នចំពោះ ជនជាប់ចោទផងដែរ។ ដូចនេះ ដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិការពារខ្លួនរបស់អនីតិជន ទើបច្បាប់តម្រូវឱ្យ អនុវត្តនីតិវិធីនេះចំពោះតែនីតិជន ។

**រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន៖** តំណាងអយ្យការត្រូវមានភស្តុតាង ឬមូលហេតុធួនល្មមក្នុងការដាក់បន្ទុកដើម្បីធ្វើការចោទប្រកាន់ បើគ្មានបន្ទុកភស្តុតាងគ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានទេ។ បើគ្មានភស្តុតាង ឬហេតុផលរឹងមាំសម្រាប់ដាក់បន្ទុកជនជាប់ចោទទេ នេះអាចជាឱកាសដល់ជនជាប់ចោទក្នុងករណី ដែលមានសេចក្តីសម្រេចស្តាពរឱ្យជនជាប់ចោទរួចខ្លួន ជាហេតុនាំឱ្យព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ជាថ្មីបាន ដោយសារតែគោលការណ៍អាជ្ញាអស់ជំនុំ។

### ២.៣.២ នីតិវិធី នៃការបង្ហាញខ្លួនភ្លាម

នៅពេលដែលព្រះរាជអាជ្ញាពិនិត្យមើល និងយល់ឃើញថាគ្រប់លក្ខខណ្ឌក្នុងការចោទប្រកាន់តាមរយៈការបង្ហាញខ្លួនភ្លាម នោះព្រះរាជ្ញានឹងសម្រេចបទចោទតាមនីតិវិធីនេះ។ ក្នុងនោះព្រះរាជអាជ្ញាត្រូវមានភារកិច្ចមួយចំនួនក្នុងការការពារផលប្រយោជន៍ដល់ជនជាប់ចោទ[42]ដូចជា ការប្រាប់ជានជាប់ចោទអំពីសិទ្ធិសុំពឹងពាក់មេធាវី ការពិនិត្យមើលអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យត្រឹមត្រូវ បន្ទាប់ពីពិនិត្យមើលបុគ្គលរួចរាល់ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងអំពីរឿងរ៉ាវដែលត្រូវបានចោទប្រកាន់ និងប្រាប់ពីបទល្មើសដែលត្រូវចោទ ទៅកាន់ជនជាប់ចោទ។ នៅក្នុងនីតិវិធីនេះប្រសិនបើជនចាប់ចោទចង់និយាយអ្វី គឺព្រះរាជអាជ្ញាត្រូវទទួលចម្លើយទាំងនោះព្រមទាំងធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមនោះផងដែរ ប៉ុន្តែនីតិវិធីនឹងត្រូវចាត់ទុកជាអាសារបង់ប្រសិនបើពុំបានចុះនិទ្ទេសនៃទម្រង់ការក្នុងកំណត់ហេតុនោះ[43]។ ប៉ុន្តែក្នុងករណីបើតុលាការបានទទួលពាក្យបណ្តឹងតាមនីតិវិធីបង្ហាញខ្លួនភ្លាម ហើយយល់ឃើញថាក្ខណ្ឌពុំបានបំពេញ ឬមានភាពសាំញ៉ាំនៃសំណុំរឿង ហើយាមានភាពចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែម នោះតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាឱ្យធ្វើការបើកការស៊ើបសួរ និងបញ្ជូនជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នេះទេ នឹងត្រូវដោះលែងឱ្យមានសេរីភាពដោយឯកឯង។[44]

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៨ កថាខណ្ឌទី១និងទី២

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៨ កថាខណ្ឌទី៤

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៨ កថាខណ្ឌទី១១

# ជំពូកទី៣
# ការចូលរួមរបស់ព្រះរាជអាជ្ញា
# ក្នុងដំណើរនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី៣
# ការចូលរួមរបស់តំណាងអយ្យការ ក្នុងដំណើរនីតិវិធីព្រហ្មទណ្ឌ

ជាទូទៅនៅពេលដែលម្ចាស់បណ្តឹងអាជ្ញា គឺព្រះរាជអាជ្ញា និងជាតំណាងអយ្យការបានទទួលពាក្យបណ្តឹងព្រហ្មទណ្ឌ និងធ្វើការចោទប្រកាន់បញ្ជូនសំណុំរឿងតាមនីតិវិធីក៏ដោយ ក៏តួនាទីរបស់ព្រះរាជអាជ្ញាមិនទាន់ចប់សប់ឡគ្រប់នៅឡើយទេ។ ហេតុនេះក៏ព្រោះតែស្ថាប័នអយ្យការជាស្ថាប័នដែលបម្រើផលប្រយោជន៍រួមនេះបើយោងតាម មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា *បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទីទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។*[45] ដូចនេះ តួអង្គព្រះរាជអាជ្ញា យើងនឹងអាចឃើញមានគ្រប់នីតិវិធី ទាំងការដឹកនាំនីក្នុងនីតិវិធីស៊ើបអង្កេត (ផ្នែកទី១) ការចូលខ្លួននៅក្នុងនីតិស៊ើបសួររបស់ព្រះរាជអាជ្ញា (ផ្នែកទី២) និងនៅពេលដែលចៅក្រមស៊ើបសួរបានបិទការស៊ើបសួរបញ្ជូនសំណុំរឿងទៅជំនុំជម្រះក៏មានការចូលរួមដោយព្រះរាជអាជ្ញាក្នុងនាមជាភាគីនៃបណ្តឹងផងដែរ (ផ្នែកទី៣) ព្រមទាំងការអនុវត្តទោសដោយតំណាងអយ្យការ (ផ្នែកទី៤)។

## ផ្នែកទី១ ការដឹកនាំស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា

ចំពោះនៅក្នុងនីតិវិធីនៃការស៊ើបអង្កេត ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវការគោលការអាថ៌កំបាំង ក្នុងការស៊ើបសង្កេតដោយតម្រូវឱ្យ ព្រះរាជអាជ្ញាត្រូវតែរក្សាការសម្ងាត់វិជ្ជាជីវៈជាដាច់ខាត ប៉ុន្តែមានបដិបញ្ញត្តិដែលព្រះរាជអាជ្ញាត្រូវអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ បានកាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះជារឿងមិនពិត។

តាមរយៈច្បាប់ដដែល មាត្រា៥៨ បានចែងអំពីអំណាចរបស់ព្រះរាជអាជ្ញានៅក្នុងនីតិវិធីស៊ើបអង្កេតដោយព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួល ព្រមទាំងមានអំណាច ទៅលើសកម្មភាពការងាររបស់មន្ត្រីនគបាលយុត្តិធម៌ និងភ្នាក់ងារនគបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចរបស់ខ្លួន។ ដូចនេះមានន័យថាព្រះរាជអាជ្ញាជាអ្នកមានសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីស៊ើបអង្កេតក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកឱ្យបានគ្រប់គ្រាន់តាមរយៈ ការស៊ើបអង្កេតជាក់ស្តែង(១.១) និងការស៊ើបង្កេតបឋម(១.២) ដើម្បីធ្វើការចោទប្រកាន់ទៅលើជនសង្ស័យ ហើយបញ្ជូនសំណុំរឿងទៅតុលាការ។

### ១.១ ការស៊ើបអង្កេតជាក់ស្តែង

ការស៊ើបងង្កេតក្នុងបទល្មើសជាក់ស្តែង គឺត្រូវតែជាបទឧក្រិដ្ឋ ឬបទជ្ឈិមជាក់ស្តែង។[46] ការស៊ើបអង្កេតក្នុងករណីជាក់ស្តែងត្រូវបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា៨៥ ដល់មាត្រា១១០។ការស៊ើប

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៨៥

អង្កេតករណីជាក់ស្តែងត្រូវបានយកមកអនុវត្តដើម្បីប្រមូលភស្តុតាងក្នុងស្ថានភាពបន្ទាន់ចំពោះបទល្មើសដែលទើបប្រព្រឹត្តហើយថ្មីៗ។ ដូចនេះទើបគេបង្កើតឱ្យមានការស៊ើបអង្កេតករណីជាក់ស្តែង ដែលជាវិធានដែលមានលក្ខណៈបែបរហ័ស និងផ្តល់អំណាចទូលំទូលាយដល់អាជ្ញាធរ ដើម្បីងាយស្រួលក្នុងការប្រមូលភស្តុតាងទាំងនោះ។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ក៏អាចត្រូវអនុវត្តដើម្បីធានាការពារបង្ការ និងស្តារឡើងវិញឱ្យបានឆាប់រហ័សនូវការខូចខាតនៃ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ អាយុជីវិតមនុស្ស រូបរាងកាយ ឬទ្រព្យសម្បត្តិដែលបង្ក ឡើងដោយបទល្មើស។

ដូចនេះ កត្តាពេលវេលាជារឿងដែលសំខាន់បំផុតសម្រាប់ការស៊ើបអង្កេតករណីជាក់ស្តែង ព្រោះភស្តុតាងអាចត្រូវបានបាត់ដានតាមភាពចេតនា ឬអចេតនាណាមួយ ដែលនេះតម្រូវឱ្យកម្លាំងនគរបាល យុត្តិធម៌ត្រូវធ្វើការឱ្យលឿនបំផុតតាមដែលអាចធ្វើបាន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាដល់ការប្រមូលភស្តុតាង។

### ១.១.១ លក្ខខណ្ឌ នៃការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតករណីជាក់ស្តែង កើតឡើងនូវស្ថានភាពជាក់ស្តែងណាមួយ ដែលអនុញ្ញាតឱ្យនគរបាលយុត្តិធម៌ ឬតំណាងអយ្យការអាចប្រើប្រាស់អំណាចស៊ើបអង្កេតជាក់ស្តែង។ ដូចនេះ ការស៊ើបអង្កេតករណីជាក់ស្តែងនេះ គឺកើតឡើងតាមរយៈស្ថានភាពជាក់ស្តែងមួយដែល បានកើតឡើងទើបបណ្តាលឱ្យមានការបើកការស៊ើបអង្កេតករណីជាក់ស្តែងនេះ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ គេពុំបានកំណត់អំពីការស៊ើបអង្កេតករណីជាក់ស្តែងណាមួយដែលត្រូវអនុវត្តនៅក្នុងករណីបទលហុឡើយ។

ដូចបានរាប់រៀបពីខាងលើ គឺមានតែស្ថានភាពជាក់ស្តែងប៉ុណ្ណោះ ជាអ្នកធ្វើឱ្យមានការបើក ការស៊ើបអង្កេតករណីជាក់ស្តែង។ ដូចនេះ តើអ្វីទៅជាស្ថានភាពជាក់ស្តែង?

ស្ថានភាពជាក់ស្តែងត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌថាៈ

*«បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺៈ*

- *បទល្មើសដែលកំពុងតែប្រព្រឹត្ត*
- *បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាម។*

*ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទ ល្មើសរួចបន្តិចមក*

- ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យមានគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។[47] ដូចនេះ ការកំណត់ពីស្ថានភាពជាក់ស្តែងត្រូវយោង ទៅលើស្ថានភាពដែលបានរៀបរាប់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៨៦

ការកំណត់ពីអត្ថិភាពនៃស្ថានភាពជាក់ស្តែង អាចត្រូវបានកំណត់តាមរយៈការសម្គាល់វត្ថុវិស័យ ឬការសង្កេតផ្សេងៗ តាមរយៈវិញ្ញាណណាមួយនៃអ្នកស៊ើបអង្កេតដោយភ្នែក ត្រចៀក អណ្តាត រូបរាងកាយ ឬច្រមុះ។ អាជ្ញាធរមានសមត្ថកិច្ចអាចស្វែងយល់បានភ្លាមៗតាមរយៈការគិត ត្រិះរិះពិចារណារបស់ខ្លួនថា តើមានស្ថានភាពជាក់ស្តែងកំពុងកើតឡើងទេ? ដូចនេះស្ថានភាពជាក់ស្តែងមួយ អាចកើតឡើងដោយសារសភាវៈខាងក្រៅស្តែងចេញបង្កើតបានទៅជាកត្តាសត្យានុម័ត ទើបអាជ្ញាថរមានសមត្ថកិច្ចអាចចូលរួមក្នុងការស៊ើបអង្កេតបាន។

ក្នុងស្ថានភាពខ្លះ អាជ្ញាធរអាចធ្វើការបើកការស៊ើបអង្កេតបឋមមុនសិន ដើម្បីអាចឈានទៅ កំណត់ស្ថានភាពជាក់ស្តែង និងបន្ទាប់មកទើបធ្វើការបើកការស៊ើបអង្កេតជាក់ស្តែងក៏បាន។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងមិនអាចអនុវត្តលើសពី ៧ ថ្ងៃនោះទេ គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។ ប្រសិនជាក្រោយការបើកការស៊ើបអង្កេតជាក់ស្តែង ហើយនៅតែពុំអាចស្វែងរកភស្តុតាងដាក់ បន្ទុកគ្រប់គ្រាន់ទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីតំណាងអយ្យការ ក្នុងករណីនេះ តំណាងអយ្យការអាចសម្រេចបិទការធ្វើស៊ើបអង្កេត ឬបើកការស៊ើបអង្កេតបឋមវិញក៏បាន។

### ១.១.២ ការឆែកឆេរ ក្នុងការស៊ើបអង្កេតជាក់ស្តែង

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាននៅគ្រប់ទីកន្លែងរបស់បុគ្គលដែលខ្លួនសង្ស័យថាជាជនសង្ស័យបាន និងកំពុងធ្វើការលាក់ខ្លួន ឬទីកន្លែងដែលខ្លួនកំពុងអាចនឹងធ្វើការស្វែងរក តែត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនោះដោយផ្ទាល់មាត់ក៏ដោយ និងត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកណាកាន់កាប់ទីកន្លែងនោះទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ដែលត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាលយុត្តិធម៌ ឬមួយក៏ជា កងរាជអាវុធហត្ថដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។ ការឆែកឆេរមិនអាចធ្វើទៅ បាននៅមុនម៉ោង ៦ព្រឹក និងនៅក្រោយម៉ោង ១៨ល្ងាច លើកលែងតែបទល្មើសជាក់ស្តែងមានចែងក្នុងមាត ៨៦ និងមាត្រា ៨៨ និងក្នុងករណីផ្សេងទៀតដែលមានចែងក្នុងមាត្រា ៩១ ដូចជាៈ

- ក្នុងករណី មានសម្រែកស្រែកឱ្យជួយក្នុងកន្លែង
- ក្នុងករណី ឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហរដល់សាធារណៈជន
- ក្នុងករណី ឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិតរក្សា ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

រាល់ប្រតិបិត្តការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះមានៈ

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។

មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះដែលអាចធ្វើការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមុី រីឯមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការ

ឆែកឆេរនៅក្នុងការិយាល័យមេធាវីនោះទេ ។ ចំពោះការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានទៀតសោត មន្ត្រីនគរបាលយុត្តិធម៌អាចប្រព្រឹត្តទៅបានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

### ១.១.៣ ការឃាត់ខ្លួន និងការបញ្ជូនខ្លួន

- អំណាចក្នុងការឃាត់ខ្លួន ការឃាត់ខ្លួនជាវិធានបង្ខិតបង្ខំក្នុងការដកហូតសិទ្ធិសេរីភាពបុគ្គលណាម្នាក់ ដូចនេះខ្លួនត្រូវអនុវត្ត ដោយផ្អែកតាមច្បាប់កំណត់។ នៅក្នុងរដ្ឋធម្មនុញ្ញបានទទួលស្គាល់និងការពារនូវសិទ្ធិសេរីភាពនេះ ដោយបានបញ្ញត្តិថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ ខ្លួន ឬការឃុំខ្លួនណាមួយអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមច្បាប់។ ដូចគ្នាផងដែរ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានកំណត់ថា គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនដោយបំពានឡើយ។ ហើយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បានចែងដែរថា ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវ ចាប់ខ្លួន ឬឃុំខ្លួន តាមអំពើចិត្តបានឡើយ ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់។ តាមរយៈក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា "បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាតត្រូវផ្តន្ទាទោស។

មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនគ្រប់បុគ្គលដែលសង្ស័យថាបាន ចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ ការឃាត់ខ្លួននេះគឺ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការ ស៊ើបអង្កេត គឺដើម្បីធានាឱ្យបាននូវការចាប់ខ្លួនជនល្មើសជាដើម។ ក្រៅពីសិទ្ធិអំណាចក្នុងការឃាត់ខ្លួនជនសង្ស័យ នោះមន្ត្រីនគរបាលយុត្តិធម៌ ក៏អាចឃាត់ខ្លួនគ្រប់បុគ្គលដែលអាចផ្តល់ជា ព័ត៌មានអំពីរឿងហេតុសម្រាប់ការបំភ្លឺការពិតផងដែរ តែការឃាត់ខ្លួនបុគ្គលប្រភេទនេះអាចអនុវត្ត បាន លុះត្រាតែបានបំពេញនូវក្នុងលក្ខខណ្ឌចំនួន២គឺ៖

- ទី១ បុគ្គលនោះមិនព្រមផ្តល់ព័ត៌មាន
- ទី២ មន្ត្រីនគរបាលយុត្តិធម៌ទទួលបានការអនុញ្ញាតយល់ព្រមជាលាយលក្ខណ៍អក្សរ ឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

វិធានដែលទាក់ទងនឹងការឃាត់ខ្លួន គឺជាវិធានដែលមានលក្ខណៈដាច់ខាត ព្រោះការមិន គោរពនូវវិធានទាំងនេះនឹងនាំមកនូវការធ្វើមោឃភាពនៃនីតិវិធី។

ការកំណត់ថេរវេលាជាក់លាក់ក្នុងការឃាត់ខ្លួនមានដូចខាងក្រោម៖

| ជនត្រូវបាន ឃាត់ខ្លួន | បទឧក្រិដ្ឋ | បទមជ្ឈិម | ការពន្យាពេលនៃ ការឃាត់ខ្លួន | រយៈពេល អតិបរមា |
|---|---|---|---|---|
| នីតិជន | ៤៨ ម៉ោង | | ២៤ ម៉ោង | ៧២ ម៉ោង |

| ជនត្រូវបាន ឃាត់ខ្លួន | បទឧក្រិដ្ឋ | បទមជ្ឈិម | ការពន្យាពេលនៃ ការឃាត់ខ្លួន | រយៈពេល អតិបរមា |
|---|---|---|---|---|
| អនីតិជន( អាយុ ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ) | ៤៨ ម៉ោង | ៣៦ ម៉ោង | មិនអាចពន្យាពេល | - សម្រាប់បទឧក្រិដ្ឋ ៤៨ ម៉ោង - សម្រាប់បទមជ្ឈិម ៣៦ ម៉ោង |
| អនិតិជន( អាយុ ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ) | ៣៦ ម៉ោង | ២៤ ម៉ោង | មិនអាចពន្យាពេល | - សម្រាប់បទឧក្រិដ្ឋ ៣៦ម៉ោង - សម្រាប់បទមជ្ឈិម ២៤ម៉ោង |

- ថេរវេលានៃការឃាត់ខ្លួនគិតចាប់ពីម៉ោង ដែលបុគ្គលត្រូវបានឃាត់ខ្លួន មកដល់អង្គភាពនគរបាលយុត្តិធម៌។
- អនីតិជនក្រោម១៤ឆ្នាំ ពុំត្រូវបានឃាត់ខ្លួនឡើយ។
- សម្រានប់អនីតិជន បើមានការឃាត់ខ្លួនត្រូវជូនដំណឹងទៅម្តាយ ឪពុក ឬអាណាព្យាបាលរបស់អនីតិជន
- សម្រាប់តារាងខាងលើ គឺយោងតាមក្រមនិតិវិធីព្រហ្មទណ្ឌ មាត្រា៩៦។

➢ **កំណត់ហេតុនៃការឃាត់ខ្លួន** ដើម្បីធានាដល់ការឃាត់ខ្លួន នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវផ្តល់ព័ត៌មានភ្លាមៗទៅព្រះរាជអាជ្ញា និងត្រូវបញ្ជូនព្រមគ្នានូវគ្រប់ភស្តុតាងដែលជាហេតុនាំឱ្យមានការឃាត់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើនូវកំណត់ហេតុមួយទៅតាមលក្ខខណ្ឌដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌមានដូចជា៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន អត្តសញ្ញាណ និងអាយុនៃបុគ្គលដែលត្រូវឃាត់ខ្លួន។
- មូលហេតុនៃការឃាត់ខ្លួន។
- ថ្ងៃខែឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន។
- ការឱ្យដំណឹងអំពីសិទ្ធិរកជំនួយពីមេធាវី
- ឈ្មោះអ្នកបកប្រែ។[48]

បុគ្គលដែលឃាត់ខ្លួនត្រូវអានកំណត់ហេតុនេះ ឬមន្ត្រីនគរបាលយុត្តិធម៌អានឱ្យស្តាប់ បើបុគ្គលដែលឃាត់ខ្លួនមិនចេះអក្សរ ដើម្បីឱ្យបុគ្គលដែលឃាត់ខ្លួននោះចុះហត្ថលេខា ឬផ្តិតស្រាមដៃ តែបើក្នុងករណីគាត់បដិសេធអំពីការចុះហត្ថលេខាឬផ្តិតស្រាមដៃ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះ និទ្ទេសអំពីការបដិសេធនេះ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១០៤ កថាខណ្ឌទី២

- **ជំនួយក្នុងពេលឃាត់ខ្លួន** មុនពេលឃាត់ខ្លួន មន្រ្តីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងភ្លាមៗពីមូលហេតុនៃការឃាត់ខ្លួនទៅជនត្រូវឃាត់ខ្លួន។ ក្នុងការជូនដំណឹងនេះ មន្រ្តីនគរបាល យុត្តិធម៌ត្រូវប្រាប់ពីសិទ្ធិរកជំនួយពីមេធាវីក្នុងអំឡុងពេលនៃការឃាត់ខ្លួន។ សិទ្ធិក្នុងការជួបជាមួយមេធាវី អាចអនុវត្តបានក្រោយពីការឃាត់ខ្លួនបានរយៈពេល ២៤ ម៉ោង។ ការធ្វើដូចនេះដើម្បីអាចឱ្យមន្រ្តីនគរបាល យុត្តិធម៌ ធ្វើការរបស់ខ្លួនជាមុនសិនក្នុងការស្តាប់ចម្លើយរបស់បុគ្គលដែលឃាត់ខ្លួន ក្រោយពីរយៈពេលនេះ បុគ្គលដែលឃាត់ខ្លួនអាចសន្ទនាជាមួយមេធាវី ឬបុគ្គលណាមួយតាមការជ្រើសរើសរបស់ខ្លួន លើកលែងតែបុគ្គលដែលជាប់ទាក់ទិននឹងរឿងក្តី។ ការសន្ទនានេះអាចធ្វើបានតែរយៈពេល ៣០ នាទី ដោយគោរព លក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ។ ការទទួលបាននូវជំនួយពីគ្រូពេទ្យអាចត្រូវបានធ្វើឡើងតាមរយៈ ព្រះរាជអាជ្ញា ឬមន្រ្តីនគរបាលយុត្តិធម៌បានគ្រប់ពេលវេលា។ កម្មវត្ថុនៃការទទួលបានជំនួយនេះគឺដើម្បីផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួនសមស្របនឹងការឃាត់ខ្លួនដែរឬទេ?[49] គ្រូពេទ្យត្រូវចេញវិញ្ញាបនបត្របញ្ជាក់សុខភាពដើម្បីភ្ជាប់ក្នុងសំណុំរឿង ហើយឈ្មោះ គ្រូពេទ្យ ថ្ងៃ ខែ ឆ្នាំនិង ម៉ោងនៃការពិនិត្យសុខភាពត្រូវចុះនិទ្ទេស។

## ១.២ ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម គឺជានីតិវិធីមួយរបស់មន្រ្តីនគរបាលយុត្តិធម៌ ដូចការស៊ើបអង្កេតធម្មតាមួយដែរក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ដោយពុំបានកំណត់ពេលវេលាជាក់លាក់ណាមួយឡើយ ដោយការស៊ើបអង្កេតបឋម មន្រ្តីនគរបាលយុត្តិធម៌ពុំមានសម្ថកិច្ចទូលំទូលាយដូចការស៊ើបអង្កេតក្នុងករណីជាក់ស្តែងឡើយ ដោយនីតិវិធី នៃការអនុវត្តនេះអនុឡោមតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ១១១ ដល់មាត្រា១១៨។

### ១.២.១ ការបើកការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម គឺជាការស៊ើបអង្កេតទៅលើបទល្មើសមិនជាក់ស្តែង តាមក្រមនីតិវិធីព្រហ្មទណ្ឌ *កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្រ្តីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។*[50] ការស៊ើបអង្កេតបឋមនេះអាចត្រូវបើកពេលដែល អ្នកស៊ើបអង្កេតមិនអាចបើកការស៊ើបអង្កេតជាក់ស្តែង ឬបដិសេធការស៊ើបអង្កេតជាក់ស្តែង ដែលយើងអាចសម្គាល់ឃើញថាមន្រ្តីនគរបាលយុត្តិធម៌អាចសម្រេចស៊ើបអង្កេតតាមទម្រង់ស៊ើបអង្កេតបឋមជានិច្ច ទោះបីជាលក្ខខណ្ឌនៃការអនុវត្តនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានបំពេញក៏ដោយ ប៉ុន្តែការសម្រេចនេះមានឥទ្ធិពលអាចដកហូតពីនគរបាលនៃអំណាចដែលអនុវត្តបានក្នុងការស៊ើបអង្កេតជាក់ស្តែង ការស៊ើបអង្កេតបឋមនេះ ត្រូវគោរពតាមវិធានដែលមានចែងក្នុងបទបញ្ញត្តិនៃមាត្រា៩០ (កំណត់ហេតុនៃការស្រាវជ្រាវ និងការពិនិត្រ) មាត្រា ៩៥ (ការត្រួតពីនិត្រខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្រ្ត) មាត្រា១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍) មាត្រា១០៧ (ការបញ្ជូនកំណត់ហេតុទៅកាន់ព្រះរាជអាជ្ញា) និងមាត្រា១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកមណត់ហេតុ) ។

---

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឲាយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៩៩ កថាខណ្ឌទី២

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឲាយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១១១

### ១.២.២ ការឆែកឆេរក្នុងការស៊ើបអង្កេតបឋម

ការឆែកឆេរ និងចាប់យកវត្ថុតាងអាចអនុវត្តបាន ក្នុងការស៊ើបអង្កេតបឋមចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម។[51] ការឆែកឆេរក្នុងការស៊ើបអង្កេតបឋម មានគោលដៅចាប់យកតែវត្ថុតាងដែលមានដូចជាគ្រាប់កាំភ្លើង ឬកាំបិត ជាដើម។ ដោយហេតុថាការឆែរឆេរក្នុងការស៊ើបអង្កេតបឋមមិនបានប្រព្រឹត្តទៅក្រោយរយៈពេលកើតហេតុថ្មីៗទេ។ ក្នុងករណីនេះ ភស្តុតាងដែលមានដូចជា ស្លាកស្នាម ឬឈាម ដែលបន្សល់ទុកនៅកន្លែងកើតហេតុអាចនឹងត្រូវបាត់បង់ដោយ ប្រការណាមួយ។ ផ្ទុយទៅវិញ ការឆែកឆេរក្នុងការស៊ើបអង្កេតករណីជាក់ស្តែង មានគោលដៅ ក្រោយការប្រព្រឹត្តបទល្មើស។ ប្រមូលយកភស្តុតាងទាំងអស់រួមទាំងការចាប់យកវត្ថុតាង ព្រោះការឆែរឆេរនេះត្រូវអនុវត្តភ្លាមៗ។

តាមក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិថា ក្នុងករណីដែលម្ចាស់ទីកន្លែងអវត្តមាន ឬបដិសេធក្នុងការឆែកឆេ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ តាមរយៈនៃការស្នើសុំរបស់ព្រះរាជអាជ្ញា ដីកាដែលប្រធានសាលាដំបូងបានចេញនោះ ជាប្រភេទដីកាសម្រេចដូចនេះត្រូវមានសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្ខអក្សរ។ ក្រោយទទួលបានការអនុញ្ញាតពីប្រធានសាលាដំបូង ព្រះរាជអាជ្ញាត្រូវបានដឹកនាំការឆែកឆែនេះដោយផ្ទាល់ រួមទាំងការការដឹកនាំឆែកឆេរ ការជ្រើសតាំងសាក្សីចំពោះមុខក្នុងការឆែកឆេរ នេះបើយោងតាមមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមមាត្រាដដែលនេះទៀតសោត ថេរវេលាក្នុងការឆែកឆេរ គឺអាចចាប់ផ្តើមចាប់ពីម៉ោង ៦ (ប្រាំមួយ) ព្រឹក និងមិនឱ្យក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច។

### ១.២.៣ ការបញ្ជាឱ្យចូលខ្លួន

ការបញ្ជាឱ្យចូលខ្លួនចំពោះជនដែលសង្ស័យ ឬជនដែលជាប់ពាក់ព័ន្ធទៅនឹងបទល្មើស គឺជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការកោះហៅ ដោយមានការធ្វើកំណត់ហេតុនូវរាល់ការឆ្លើយនោះ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បុគ្គលដែលបានកោះហៅត្រូវតែបង្ហាញខ្លួន[52] ប៉ុន្តែក្នុងករណីបុគ្គលដែលបានកោះហៅ រឹងទទឹងក្នុងការចូលខ្លួន ព្រះរាជអាជ្ញាអាចចេញបញ្ជាតាមការជូនដំណឹងរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយការបញ្ជានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា និងបោះត្រាព្រះរាជអាជ្ញា ដើម្បីបញ្ជាក់អំពីឆន្ទៈក្នុងការអនុញ្ញាត។ ដូចនេះ ការបញ្ជាឱ្យចូលខ្លួនលើកនេះ អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំឱ្យមានការបង្ហាញខ្លួនបុគ្គលដែលបានកោះហៅនោះ។

## ផ្នែកទី២ តំណាងអយ្យការក្នុងកិច្ចនីតិវិធីស៊ើបសួរ

ការស៊ើបសួរ គឺជានីតិវិធីមួយដែលស្ថិតក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ការស៊ើបសួរនេះត្រូវធ្វើឡើងក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ និងស្មុគស្មាញ ដូចជាករណីបទឧក្រិដ្ឋ ដែលត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា ត្រូវតែធ្វើការស៊ើបសួរជាដាច់ខាត។ ចំពោះបទមជ្ឈិម ឬបទលហុ ពុំតម្រូវឱ្យមានការ ស៊ើបសួរជា

---

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១១៣ កថាខណ្ឌទី១

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១១៤

លក្ខណៈដាច់ខាតដូចបទឧក្រិដ្ឋឡើយ។ រាល់ព័ត៌មានដែលចៅក្រមស៊ើបសួរបានទទួលបាន គឺត្រូវលាក់ទុកជាការសម្ងាត់ស្របតាមវិជ្ជាជីវៈ ជៀសវាងការផ្សព្វផ្សាយជាសាធារណៈ។ ប៉ុន្តែនៅក្នុងកិច្ចស៊ើបសួរ ព្រះរាជអាជ្ញាអាចមានវត្តមាននៅគ្រប់កិច្ច ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការតទល់ និងក្នុងការស្តាប់ចម្លើយ។[53] ការចូលរួមនៅក្នុងកិច្ចនីតិវិធីស៊ើបសួរ គឺសម្រាប់ការពារផលប្រយោជន៍រួម និងប្រយោជន៍សាធារណៈ ដូចនេះនៅក្នុងផ្នែកនេះយើងនឹងបកស្រាយនីតិវិធីមួយចំនួនដែលទាក់ទងទៅនឹងតំណាងអយ្យការ ដូចជា ការស្នើសុំឱ្យបំពេញកិច្ចរបស់ព្រះរាជអាជ្ញា (៣.១) ការចូលខ្លួននៅក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ (៣.២) ការចូលខ្លួននៅក្នុងគោលការណ៍និរន្តរាយ (៣.៣) ការបិទ និងការមោឃភាពនៃការស៊ើបសួរ (៣.៤) ។

### ២.១ ការស្នើរសុំឱ្យបំពេញកិច្ចរបស់ព្រះរាជអាជ្ញា

ការស្នើសុំបំពេញកិច្ច អាចត្រូវបានធ្វើគ្រប់ពេលវេលាតាមរយៈការស្នើសុំរបស់ព្រះរាជអាជ្ញា ដែលយល់ឃើញថាការបំពេញកិច្ចនោះមានប្រយោជន៍។ ចំណែកឯជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីវិញក៏អាចស្នើសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយ និងស្តាប់ចម្លើយខ្លួន ឬសាក្សី ព្រមទាំងអាចសុំសួរតទល់ ឬចុះដល់ទីកន្លែងកើតហេតុ ហើយពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។

បើសិនជាការស្នើសុំនេះមិនត្រូវបានយល់ព្រមដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរ ត្រូវចេញសេចក្តីសម្រេចបដិសេធពាក្យសុំនោះនៅក្នុងរយៈពេល ១៥ ថ្ងៃចំពោះព្រះរាជអាជ្ញា និងរយៈពេល១ខែ ចំពោះជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីខ្លួនបានទទួលពាក្យសុំ។ សេចក្តីសម្រេចបដិសេធរបស់ចៅក្រមស៊ើបសួរ ត្រូវមានសំអាងហេតុត្រឹមត្រូវតាមច្បាប់។

បន្ទាប់មកចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួន ទៅអ្នក ប្តឹងសុំដែលមានព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអ្នកប្តឹងសុំអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចសម្រេចជំនួសចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរក្នុងរយៈពេល ១៥ ថ្ងៃ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ ថ្ងៃ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹង ឧទ្ធរណ៍ទៅសភាស៊ើបសួរក្នុងរយៈពេល ១ ខែ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១ ខែ។

### ២.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជាអ្នកទទួលបន្ទុកក្នុងការស៊ើបសួរដោយសេរី និងឯករាជ្យ។ ដូចនេះ ការស៊ើបសួរគឺស្ថិតនៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ នូវសិទ្ធិមួយចំនួនឱ្យព្រះរាជាអាជ្ញាក្នុងចូលរួមកិច្ចស៊ើបសួរដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរផងដែរដូចជា ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងការធ្វើកោសលវិច្ឆ័យជាដើម។ វាស្តែងបង្ហាញឱ្យឃើញពីការសហប្រតិបត្តិការរវាងចៅក្រមស៊ើបសួរ និងព្រះរាជាអាជ្ញាផងដែរ។ បើតាមក្រមនីតិវិធីប្រហ្មទណ្ឌ ក្នុងពេលសួរចម្លើយ ព្រះរាជអាជ្ញាអាចលើកសំណួរមួយចំនួនបានបើចៅក្រមស៊ើបសួរអនុញ្ញាតនោះ ប្រសិនបើមានការបដិសេធពីចៅក្រមស៊ើបសួរក្នុងការស្នើសុំលើកសំណួររបស់ព្រះរាជអាជ្ញា ក្រឡាបញ្ជីត្រូវចុះនិទ្ទេសអំពីចំណុច

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឲ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៣៦

នេះនៅក្នុងកំណត់ហេតុសួរឆ្លើយ។[54] ក្រៅពីការសួរចម្លើយ និងការស្តាប់ចម្លើយខាងលើ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំធ្វើកោសលវិច្ឆ័យអំពីបញ្ហាបច្ចេកទេសដែលចោទឡើង។ ចៅក្រមស៊ើបសួរអាចធ្វើការបដិសេធនូវពាក្យសុំនោះ ដោយដីកាមានសំអាងហេតុក្នុងរយៈពេល ៥ ថ្ងៃ។ ប្រសិនមានការយល់ព្រមពីការធ្វើកោសលវិច្ឆ័យ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ កាលណារបាយការណ៍នៃការធ្វើកោសលវិច្ឆ័យត្រូវបានធ្វើរួចហើយ និងព្រះរាជអាជ្ញាត្រូវដាក់របាយការណ៍នោះ ក្នុងសំណុំរឿងនិងបញ្ជូនទៅ ចៅក្រមស៊ើបសួរវិញ។

## ២.៣ គោលការណ៍និរន្តរាយ

វិធានការនិរន្តរាយ គឺសំដៅទៅលើការចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន ការឃុំខ្លួនបណ្តោះអាសន្ន និងការ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរដោយចៅក្រមស៊ើបសួរ។ យ៉ាងណាមិញដោយផ្អែកលើ មូលដ្ឋានគ្រឹះនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការចាត់ការតាមរយៈវិធានការនិរន្តរាយ ចៅក្រមស៊ើបសួរមានអំណាចប្រាស់ប្រាស់នូវដីកាជាច្រើនទៀតដើម្បីស្តែងឡើងអំពីសកម្មភាពរបស់ខ្លួន។ ទាំងនេះជាគោលការណ៍នៅក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីមានភាពងាយស្រួលក្នុងការស្វែងរកភស្តុតាងពិតប្រាកដសម្រាប់ដាក់បន្ទុក ឬដោះបន្ទុករបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ។

បន្ថែមពីនេះទៅទៀតនោះ វិធានការនិរន្តរាយគឺជាវិធានការមួយដែលចៅក្រមស៊ើបសួរប្រើសម្រាប់ទប់ស្កាត់ពុំឱ្យមានភាពអន្តរាយណាមួយកើតឡើងនៅក្នុងដំណាក់កាលស៊ើបសួរ ដោយវិធានការនេះបានអនុញ្ញាតឱ្យចៅក្រមស៊ើបសួរចេញដីកាសំខាន់ៗ ដើម្បីធ្វើយ៉ាងណាក្នុងការធានាឱ្យមានការស៊ើបសួរដំណើរការទៅមុខរលូនដោយពុំមានឧបសគ្គមករារាំងឡើយ។ ទន្ទឹមនឹងនេះដែរ ដើម្បីស្វែងរកនូវការពិតនៅក្នុងរឿងក្តី ច្បាប់បានប្រគល់សិទ្ធអំណាចដល់ចៅក្រមស៊ើបសួរ ដែលសិទ្ធិអំណាចនេះមានលក្ខណៈចាប់បង្ខំ ព្រមទាំងនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ នៅពេលដែលចៅក្រមស៊ើបសួរបានប្រើប្រាស់នូវវិធានការនិរន្តរាយ។

### ២.៣.១ ការបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ ឬច្រើននាក់ដើម្បីឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។[55] ជាទូទៅដីកាបង្គាប់ឱ្យចូលខ្លួននេះ អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណា ម្នាក់ដែលមានតម្រុយពិរុទ្ធភាព ពីព្រោះក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ជាពិសេសក្នុងការស្តាប់ចម្លើយ ជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាព[56] គឺជាកិច្ចការមួយដែលសំខាន់ដើម្បីទទួលនូវចម្លើយដោយតាមរយៈការសួរចម្លើយជនត្រូវចោទក្នុងការបញ្ជាក់ឱ្យកាន់តែច្បាស់អំពីការពិតនៃអង្គហេតុនីមួយៗ ក៏ដូចជាការស្វែង រកជនដែលពាក់ព័ន្ធដែលជាភស្តុតាងចាំបាច់ដ៏សំខាន់ផងដែរ។ ផ្ទុយមកវិញ ដីកានេះមិនអាចចេញទៅលើសាក្សីបានឡើយ។ បន្ថែមពីនេះទៀត បន្ទាប់ពីពេលចេញដីកានេះហើយ គឺត្រូវជូនដំណឹងដល់ជន

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៤៦

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៦៨ កថាខណ្ឌទី២

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៦៨ កថាខណ្ឌទី៣

ណាដែលពាក់ព័ន្ធតាមរយៈ មន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។[57] ស្របពេលដែលការចេញដីកានេះដែរ ចៅក្រមស៊ើបសួរត្រូវតែគោរព និងអនុវត្តទៅតាមលក្ខខណ្ឌមួយចំនួនផងដែរនៅខាងក្រោមនេះ។

ចំពោះកម្មវត្ថុនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួន គឺដើម្បីបញ្ជាឱ្យបុគ្គលដែលត្រូវចោទចូលមកបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសាកសួរពត៌មាន សួររកចម្លើយ ឬស្តាប់ចម្លើយ អំពីរឿងហេតុដែលត្រូវបានពាក់ព័ន្ធទៅនឹងបទល្មើស ដែលត្រូវបានចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញា។ នៅក្នុងចំណាត់ការវិធានការនិរន្តរាយនេះ ដើម្បីឱ្យការស៊ើបសួរស្វែងរកការពិតនៃរឿងមួយដែលប្រព្រឹត្ត ទៅបានដោយរលូនរបស់ចៅក្រមស៊ើបសួរត្រូវតែមានសហការពីព្រះរាជអាជ្ញា។ ជាទូទៅការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះ គឺធ្វើឡើងស្របពេលដែលចៅក្រមស៊ើបសួរទទួលបានសំណុំរឿងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីសំណាក់ព្រះរាជអាជ្ញា។ កម្មវត្ថុនៃការចេញដីកានេះ គឺដើម្បីបញ្ជាឱ្យបុគ្គលត្រូវចោទចូលមកបង្ហាញ ខ្លួននៅចំពោះមុខចៅកបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរសួរធ្វើការសាកសួរពត៌មានស្វែងរកចម្លើយអំពីរឿង ហេតុពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ក៏ប៉ុន្តែការចេញដីកាបង្គាប់ឱ្យចូលខ្លួនមិនអាចត្រូវអនុវត្តបានដោយភ្លាមៗឡើយ ទោះបីជាមានសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាក៏ដោយ។ ដោយមូលហេតុមកពីនៅក្នុង សេចក្តីសន្និដ្ឋាននោះបានធ្វើការចោទប្រកាន់ទៅលើបុគ្គលដែលមិនស្គាល់អត្តសញ្ញាណ ឬមានសាវតាជាតិ ច្បាស់លាស់។ ហេតុដូច្នេះការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះគ្មានប្រសិទ្ធភាព និងមិនអាចធ្វើទៅបានឡើយ។ ហេតុនេះហើយ ចំពោះចំណាត់ការក្នុងការឆ្លើយតបទៅនឹងករណីនេះ ជាដំបូងនោះចៅក្រមស៊ើបសួរធ្វើការស៊ើប សួរស្វែងរកសាវតាជាតិ និងអត្តសញ្ញាណរបស់បុគ្គលនោះជាមុនសិន តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស មុន នឹងឈានដល់ការចេញដីកាបង្គាប់ឱ្យចូលខ្លួន។ យ៉ាងណាមិញចៅក្រមស៊ើបអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន បានក្នុងករណីដែលមានការស្នើសុំពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌។ ករណីនេះយោងតាមស្ថានភាពជាចាំបាច់នៃវិធានការនិរន្តរាយ។

### ២.៣.២ ការបង្គាប់ឱ្យនាំខ្លួន

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅជួបនៅចំពោះមុខចៅក្រមស៊ើបសួរ។[58] ហើយចៅក្រមស៊ើបសួរមានអំណាចចេញនូវដីកាបង្គាប់ឱ្យនាំខ្លួន។[59] ក្នុងន័យនេះការចេញដីកា គឺជាករណីចាំបាច់ដើម្បីបង្ខំឱ្យជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពឱ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរតាមរយៈការប្រើប្រាស់កម្លាំងសាធារណៈឱ្យចាប់បង្ខំនាំយកបុគ្គលនោះមកបង្ហាញខ្លួន។ ម្យ៉ាងទៀតនោះ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនទៅកាន់សាក្សីបាននោះទេ ទោះបីជាសាក្សីនោះរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួនតាមការកោះហៅពីសំណាក់ចៅក្រមស៊ើបសួរក៏

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៨៨

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៩០

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៨៩

ដោយ។ ក៏ប៉ុន្តែ ទោះបីជាមានការបញ្ញត្តិបែបនេះក៏ដោយ ពុំមានន័យថាចៅក្រមស៊ើបសួរមិនមានអំណាចក្នុងការចាប់បង្ខំសាក្សីឱ្យមកចូលខ្លួននៅពេលដែលសាក្សីរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួននោះឡើយ។ ចៅក្រមស៊ើបសួរអាចចាប់បង្ខំសាក្សីឱ្យមកចូលខ្លួនបានតាមរយៈការស្នើសុំទៅកងកម្លាំងសាធារណៈ ដើម្បីបង្ខំសាក្សីដែលរឹងទទឹងឱ្យមកបង្ហាញខ្លួនបាន។[60]

ដីកាបង្គាប់ឱ្យនាំខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ន ជាទូទៅការចេញដីកាបង្គាប់ឱ្យនាំខ្លួននេះគឺត្រូវបានធ្វើឡើងបន្ទាប់ពីចំណាត់ការនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួនលែងមានប្រសិទ្ធភាពតទៅទៀត ឬលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួនជាលក្ខខណ្ឌជាចាំបាច់ក្នុងការដើរតួនាទីជំនួសឱ្យដីកាបង្គាប់ឱ្យចូលខ្លួន។ ជាធម្មតាដីកាបង្គាប់ឱ្យនាំខ្លួនតែងតែដើរតួនាទីតាមក្រោយដីកាបង្គាប់ឱ្យចូលខ្លួន។ ក៏ប៉ុន្តែ ក៏មានករណីពិសេសដែលធ្វើឱ្យដីកាបង្គាប់ឱ្យនាំខ្លួនអាចដើរតួនាទីជំនួសឱ្យដីកា បង្គាប់ឱ្យចូលខ្លួនបានផងដែរ ជាក់ស្តែងប្រសិនបើត្រូវចោទមិនបានចូលខ្លួនតាមដីកាបង្គាប់ឱ្យចូលខ្លួនទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទបាន ករណីដែលជនត្រូវចោទមិនបានរត់គេចទៅទីណានោះ។ ចំណុចនេះមានន័យថា ជនត្រូវចោទកំពុងតែរស់នៅជាធម្មតានៅមូលដ្ឋានដោយគ្មានការរត់គេចខ្លួននោះចៅក្រមស៊ើបអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទនោះតែម្តង។ ម្យ៉ាងវិញទៀត ប្រសិនបើក្នុងករណីចៅក្រមស៊ើបសួរយល់ឃើញថា ការចេញដីកាបង្គាប់ឱ្យចូលខ្លួនទៅកាន់ជនត្រូវចោទពីបទបង្ឈឺម ឬបទឧក្រិដ្ឋធ្វើឱ្យ ជនត្រូវចោទមានបំណងរត់គេចខ្លួននោះ ចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាបង្គាប់ឱ្យនាំខ្លួនតែម្តង។ ផ្ទុយមក វិញនោះដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចចេញទៅលើបទលហុបាននោះទេ។ មួយវិញទៀតនោះចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យនាំខ្លួនដែលមានអានុភាពដើម្បីធ្វើការនាំខ្លួនជន នោះមកស៊ើបសួរក្នុងការស្វែងរកការពិតដោយសារតែជនត្រូវចោទនៅតែរឹងទទឹងមិនព្រមចូលបកបង្ហាញខ្លួនចំពោះមុខតុលាការជាដាច់ខាតនៅពេលដែលចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនរួចហើយ។ យ៉ាងណាមិញ ក៏នៅមានចំណុចនៃនីតិវិធីដែលគួរឱ្យកត់ចំណាំផងដែរថា ប្រសិនបើចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឱ្យចូលខ្លួនរួចហើយ ស្រាប់តែជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពបានរត់គេចខ្លួន បាត់ដោយពុំព្រមចូលមកបង្ហាញខ្លួន និងដោយមានចំណារពីមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ បានបញ្ជាក់ថាបុគ្គលដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចូលខ្លួននោះបានរត់គេចខ្លួនបាត់នោះ បន្ទាប់ពីបុគ្គលនោះ បានទទួលដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួននោះ ដោយយោងតាមស្ថានភាពចាំបាច់ខាងលើនេះ ចៅក្របស៊ើប សួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជំនួសឱ្យការចេញដីកាបង្គាប់ឱ្យនាំខ្លួនតែម្តង។ ជាងនេះទៅទៀតនោះ តាមរយៈដីកាបង្គាប់ឱ្យនាំខ្លួនក៏ដូចជាដីកាបង្គាប់ឱ្យចាប់ខ្លួនបានបង្ហាញឱ្យយើងឃើញថាដីកាទាំងពីរនេះសុទ្ធសឹង តែបានបញ្ជាឱ្យកងកម្លាំងសាធារណៈឱ្យធ្វើការចាប់ និងនាំខ្លួនជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព បានដូចគ្នា។ ទោះបីជាយ៉ាងណា ស្របតាមស្មារតីនៃមាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថាដីកាបង្គាប់ឱ្យ

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៥៣

ចាប់ខ្លួនគឺជាបញ្ជាដល់កងកម្លាំងសាធាណៈឱ្យស្រាវជ្រាវរកចាប់ខ្លួនបុគ្គលនោះទៅ ក្នុងពន្ធនាគារ ឬបណ្ឌលឃុំខ្លួន។ ត្រង់ចំណុចនៃឃ្លានេះ គឺមិនត្រូវបានចែងនៅក្នុងលក្ខខណ្ឌនៃការអនុវត្តន ដីកាបង្គាប់ឱ្យនាំខ្លួនឡើយ។ ហេតុនេះហើយនាំឱ្យយើងទាញរកលក្ខខណ្ឌខុសគ្នារវាងដីកាទាំងពីរនេះបានគឺថាដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានយកទៅប្រើប្រាស់នៅក្នុងស្ថានភាពដែលចៅក្រមស៊ើបសួរបានដឹងច្បាស់ពីទីកន្លែង ស្នាក់នៅរបស់ជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពច្បាស់លាស់។ ចំណែកឯដីកាបង្គាប់ឱ្យចាប់ខ្លួន គឺត្រូវបានយកទៅប្រើប្រាស់ទៅលើស្ថានភាពដែលជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពបានរត់គេចខ្លួនឬនៅពេលដែលចៅក្រមស៊ើបសួរពុំបានដឹងច្បាស់ពីទីកន្លែងស្នាក់នៅពិតប្រាកដរបស់ជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពនោះៗ។

### ២.៣.៣ ការបង្គាប់ឱ្យចាប់ខ្លួន

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចចេញដីការបង្គាប់ឱ្យចាប់ខ្លួន[61] ដែលជាវិធានមួយក្នុងការបង្ខិតបង្ខំជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ។ មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួនចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងអំពីការចាប់ខ្លួននេះទៅព្រះរាជអាជ្ញាជាមុនសិន ដើម្បីឱ្យព្រះរាជអាជ្ញាពិនិត្យ និងផ្តល់យោបល់តាមការយល់ឃើញរបស់ខ្លួន ហើយចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើយោបល់របស់ព្រះរាជអាជ្ញា។ ជាគោលការណ៍ យោបល់របស់ព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួននោះឡើយ។ ចៅក្រមស៊ើបសួរនៅតែអាចសម្រេចចាប់ខ្លួនជនត្រូវចោទបានដដែល ទោះជាព្រះរាជអាជ្ញាមានយោបល់ជំទាស់ទៅនឹងការចាប់ខ្លួនជនត្រូវចោទនោះក៏ដោយ ដោយហេតុថាយោបល់ទាំងនោះមានតម្លៃត្រឹមតែជាមូលវិចារណ៍ សម្រាប់ចៅក្រមស៊ើបសួរធ្វើការពិចារណាតាមផ្លូវច្បាប់តែប៉ុណ្ណោះ។[62] ដូចនេះចៅក្រមស៊ើបសួរនៅតែអាចចេញដីកាបង្គាប់ឱ្យចាប់ ខ្លួនតាមការយល់ឃើញរបស់ខ្លួន។ ការសម្រេចរបស់ចៅក្រមស៊ើបសួរ ក្នុងការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវធ្វើឡើងដោយផ្អែកទៅលើភាពចាំបាច់ និងប្រយោជន៍ដល់នីតិវិធីនៃការស៊ើបសួរ ដោយ មានបញ្ជាក់ឱ្យច្បាស់លាស់ពីមូលហេតុនៃការចាប់ខ្លួន។

ក្នុងករណីចាប់ខ្លួនជនត្រូវចោទបានសម្រេច ជនត្រូវចោទត្រូវបានបញ្ជូនទៅបង្ហាញមុខចំពោះចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើកិច្ចនីតិវិធីស្ថិតនៅដំណាក់កាលស៊ើបសួរនៅឡើយ ។ ប៉ុន្តែបើសិនជាមិនបាននាំទៅបង្ហាញមុខចំពោះចៅក្រមស៊ើបសួរក្នុងថ្ងៃបន្ទាប់ពីកាចាប់ខ្លួន ព្រះរាជអាជ្ញា នៃកន្លែងឃុំខ្លួនជនត្រូវចោទនោះនឹងធ្វើការស្តាប់ចម្លើយ ហើយធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន បើសិនមានការឃុំខ្លួន ចិរវេលានៃការឃុំខ្លួននេះនឹងត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

### ២.៣.២ ការឃុំខ្លួនបណ្តោះអាសន្ន

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១៩៥

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៨៥

ការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីបទមជ្ឈឹម ឬបទឧក្រិដ្ឋដែលច្បាប់ដាក់ទោសពន្ធនាគារស្មើរ ឬលើស ពីមួយឆ្នាំ ចៅក្រមស៊ើបសួរអាចឃុំខ្លួនជាបណ្តោះអាសន្នតាមការការផ្តើមគំនិតរបស់ខ្លួន ឬតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ មានន័យថា ព្រះរាជអាជ្ញាអាចសរសេរសេចក្តីសន្និដ្ឋានអំពីការឃុំខ្លួន ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចឃុំខ្លួន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាបង្គាប់ឱ្យឃុំខ្លួននេះទៅព្រះរាជអាជ្ញា។

តាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា២០៥ បានបញ្ញត្តិអំពីការឃុំខ្លួនបណ្តោះអាសន្នត្រូវមានលក្ខខណ្ឌដូចតទៅ៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតឡើងជាថ្មី។
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែល បណ្តាលមកពីបទល្មើស។

ថេរវេលានៃការឃុំខ្លួនបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មដូចតទៅៈ

<table>
<tr><th>ជនត្រូវចោទ</th><th>បទឧក្រិដ្ឋ</th><th>បទមជ្ឈឹម</th><th>ការពន្យាពេល</th><th>រយៈពេលអតិបរមា</th></tr>
<tr><td rowspan="2">នីតិជន</td><td rowspan="2">៦ខែ</td><td rowspan="2">៤ខែ</td><td>បទឧក្រិដ្ឋ បាន២ដង ម្តង៦ខែ</td><td>បទឧក្រិដ្ឋ ១៨ ខែ</td></tr>
<tr><td>បទមជ្ឈឹម បាន១ដង ម្តង២ខែ</td><td>បទមជ្ឈឹម ៦ខែ</td></tr>
<tr><td rowspan="2">អនីតិជន( អាយុ ចាប់ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ)</td><td rowspan="2">មិនអាចលើសពី ៦ខែ</td><td rowspan="2">មិនអាចលើសពី ៤ខែ</td><td rowspan="2">គ្មានការបញ្ញាត្តិ</td><td>បទឧក្រិដ្ឋ ៦ខែ</td></tr>
<tr><td>បទឧក្រិដ្ឋ ៤ខែ</td></tr>
<tr><td rowspan="2">អនីតិជន( អាយុ ចាប់ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ)</td><td rowspan="2">មិនអាចលើសពី ៤ខែ</td><td rowspan="2">មិនអាចលើសពី ២ខែ</td><td rowspan="2">គ្មានការបញ្ញាត្តិ</td><td>បទឧក្រិដ្ឋ ៤ខែ</td></tr>
<tr><td>បទឧក្រិដ្ឋ ២ខែ</td></tr>
</table>

- ករណីមានជនត្រូវចោទពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬឧក្រិដ្ឋសង្គ្រាម ចៅក្រមមិនអាចឃុំខ្លួនបណ្តោះអាសន្នលើសពី ១ ឆ្នាំបានទេ ហើយការពន្យារពេលអាចអនុវត្តបាន ២ដង ហើយ ក្នុង ១ដង បាន ១ឆ្នាំ ដោយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។
- តារាងនេះយោងចាប់ពី មាត្រា ២០៨ ដល់ មាត្រា ២១៤។

➢ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គ្រប់បទមជ្ឈិម មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់ឡើយ។

➢ អនីតិជនអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នឡើយ។ ចៅក្រមស៊ើបសួរអាចប្រគល់ឱ្យឪពុកម្តាយ ដើម្បីរង់ចាំសេចក្តីសម្រេចតុលាការ។

❖ **ការមិនឃុំខ្លួនបណ្តោះអាសន្ន** តាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២០៦ ក្នុងកថាខណ្ឌទី១ និងទី២ បានបើកផ្លូវឱ្យព្រះរាជអាជ្ញាមានសិទ្ធិក្នុងការស្នើសុំឱ្យមានការឃុំខ្លួនបណ្តោះអាសន្នបាន។

*«ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការ កត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះមេធាវីត្រូវ បង្ហាញមធ្យោបាយការពារខ្លួន។*

*ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន តាមដីកាដោយមានសំអាង ហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុន ការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានជូនដំណឹង ភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។»*

ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឱ្យមានការឃុំខ្លួនបណ្តោះអាសន្នទេនោះ គឺ ចៅក្រមស៊ើបសួរដែលទទួលដីកាសន្និដ្ឋាន ត្រូវចេញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ក្នុងរយៈពេល ៥ថ្ងៃ។ ប្រសិនបើកិច្ចនេះ ចៅក្រមស៊ើបសួរមិនបានបំពេញទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរបាន ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរបាន។[63]

❖ **ការដោះលែងឱ្យនៅក្រៅឃុំ** ការដោះលែងអាចអនុវត្តបាន ប្រសិនបើការដោះលែងនោះមិនប៉ះពាល់ដល់កិច្ចនីតិវិធីនៃការស៊ើបសួរ។ ជាគោលការណ៍ ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្នមិនមែនមានន័យថាដោះលែងជនត្រូវចោទនោះឱ្យរួចខ្លួនពីការជំនុំជម្រះឡើយ តែជាការដោះលែងបណ្តោះអាសន្នប៉ុណ្ណោះ មិនមែនជាការដោះលែងស្ថាពរឡើយ។ ដូចនេះ ជនត្រូវចោទនេះមានកាតព្វកិច្ចមក បង្ហាញខ្លួន ចំពោះមុខតុលាការទៅតាមការកោះហៅរបស់តុលាការ។ ការដោះលែងឱ្យនៅក្រៅឃុំអាចត្រូវបានធ្វើឡើងតាម៖

- ការបង្គាប់របស់ចៅក្រមស៊ើបសួរ
- បណ្តឹងរបស់ព្រះរាជអាជ្ញា
- បណ្តឹងរបស់ជនត្រូវចោទ។

• ការដោះលែងឱ្យនៅក្រៅឃុំតាមការបង្គាប់របស់ចៅក្រមស៊ើបសួរ អាចធ្វើបានគ្រប់ពេលវេលា ។ តែចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវ ផ្តល់យោបល់ និងពិនិត្យក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរ បំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២០៧

- ព្រះរាជអាជ្ញាអាចធ្វើបណ្តឹងសុំឱ្យមានការដោះលែងឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។ ក្នុងករណីនេះ ចៅក្រមត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ បើក្នុងរយៈពេលនោះចៅក្រមមិនបានសម្រេចទេ ព្រះរាជអាជ្ញាអាចប្តឹងសុំទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់ពីសំអាងហេតុសម្រាប់ការមិនដោះលែង។

- ជនត្រូវចោទអាចដាក់បណ្តឹងសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវបញ្ជូននូវពាក្យសុំនោះភ្លាមទៅតំណាងអយ្យការដើម្បីផ្តល់យោបល់ និង បញ្ជូនសំណុំរឿងទៅតំណាងអយ្យការពិនិត្យ។ តំណាងអយ្យការត្រូវពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតជូនចៅក្រមស៊ើបសួរវិញ ហើយចៅក្រមស៊ើបសួរអាចសម្រេចសេចក្តីយ៉ាងយូរបំផុត៥ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ជូនសំណុំរឿងទៅតំណាងអយ្យការ។

❖ **ការត្រួតពិនិត្យតាមផ្លូវតុលាការ** យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវធ្វើតាមទម្រង់នៃដីកាមួយដែលមានឈ្មោះថា **ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**។ ដីកាសម្រេចនេះ ត្រូវចេញដោយចៅក្រមស៊ើបសួរតាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទដើម្បីប្រើសិទ្ធិតវ៉ាតាមច្បាប់កំណត់។ ដោយឡែក ក្នុងករណីព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំចៅក្រមស៊ើបសួរ ឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តែចៅក្រមស៊ើបសួរមិនព្រមសម្រេចតាមការស្នើសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីទទួលបានការស្នើសុំ។ ហើយប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ថ្ងៃនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។

## ២.៤ ការបិទ និងមោឃភាព នៃការស៊ើបសួរ

### ២.៤.១ ការបិទការស៊ើបសួរ

ច្បាប់មិនបានកំណត់ពីថិរវេលានៃការស៊ើបសួរនោះទេ ការស៊ើបសួរអាចត្រូវចំណាយពេលវេលាខ្លី ឬវែងអាស្រ័យទៅតាមភាពស្មុគស្មាញនៃរឿងក្តី។ ភាគីនៃរឿងក្តីអាចធ្វើ ការស្នើសុំឱ្យបិទការស៊ើបសួរ ហើយការស៊ើបសួរអាចត្រូវបានបញ្ចប់តាមការស្នើសុំរបស់ភាគី នៃរឿងក្តីក្នុងករណីការស៊ើបសួរអូសបន្លាយវេលាយូរពេក ឬប្រសិនបើចៅក្រមស៊ើបសួរយល់ថា ការស៊ើបសួរមានលក្ខណៈគ្រប់គ្រាន់អាចសម្រេចតាមផ្លូវច្បាប់សម្រាប់ការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ ដូចនេះសម្រាប់ការបិទការស៊ើបសួរនេះ ដំបូងចៅក្រមស៊ើបសួរត្រូវចេញសេចក្តី សម្រេចបិទការស៊ើបសួរ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គូភាគី បើមាន។ យ៉ាងយូរ ២ ថ្ងៃក្រោយបន្ទាប់មក ចៅក្រមស៊ើបសួរត្រូវ បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យក្នុងរយៈពេល ១៥ថ្ងៃ ក្នុងករណីជនត្រូវចោទត្រូវជាប់ឃុំ និងព្រះរាជអាជ្ញាពិនិត្យក្នុងរយៈពេល ១ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ។ ថិរវេលា នៃការពិនិត្យសំណុំរឿងដោយព្រះរាជអាជ្ញានេះត្រូវ

រាប់ចាប់ពីពេលព្រះរាជអាជ្ញាបានទទួលសំណុំរឿង បន្ទាប់មកព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញតាមទម្រង់នៃដីកា សន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿងៗក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្ដឹងសុំទៅចៅក្រមស៊ើបសួរឱ្យបញ្ជូនខ្លួនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។

ដីកាដំណោះស្រាយមាន ២ប្រភេទ គឺដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទ ប្រកាន់។ ចៅក្រមស៊ើបសួរអាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ហើយ។ ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់ ប្រសិនបើ៖ អំពើនោះមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈឹម ជនដែលប្រព្រឹត្តនៅតែមិនស្គាល់អត្តសញ្ញាណ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ។ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា មិនចងកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការចេញដីកាដំណោះស្រាយឡើយ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាសំណោះស្រាយ ក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា។

### ២.៤.២ ការមោឃភាព នៃការស៊ើបសួរ

ក្នុងការមោឃភាពនៃការស៊ើបសួរ គឺជាសមត្ថកិច្ចផ្ដាច់មុខរបស់សភាស៊ើបសួរ។ វិធាន និងទម្រង់ការដែលនាំឱ្យមានមោឃភាពមានចែងក្នុងមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានដូចជា ការបើកការស៊ើបសួរ (មាត្រា ១២២) , សមត្ថកិច្ចដែនដី (មាត្រា ១២៣) , ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (កថាខណ្ឌទី៣ នៃមាត្រា ១២៤), វិសាលភាពនៃការប្ដឹង (កថាខណ្ឌទី១ និងទី២ នៃមាត្រា ១២៥) និងជំនួយក្រឡាបញ្ជី (មាត្រា ១២៨)។ វិធានទម្រង់ការទាំងនេះត្រូវតែធានាឱ្យបាននូវការគោរពជាដាច់ខាតដើម្បីធានាដល់ការគោរពសិទ្ធិការពារខ្លួន។ មោឃភាពនឹងកើតមានផងដែរ ប្រសិនបើមានការប៉ះពាល់វិធានទម្រង់ការ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី ដែលទទួលរងការបំពាន។[64] ប្រសិនបើព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថាមានលិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញា ឬសាមីជនទាំងនោះអាចធ្វើពាក្យសុំដោយមានសំអាងហេតុបញ្ជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានទៅចៅក្រមស៊ើបសួរ។ ក្រៅពីនេះ ចៅក្រមស៊ើបសួរក៏អាចធ្វើបណ្ដឹងទៅសភាស៊ើបសួរអំពីលិខិត នៃនីតិវិធីដែលខ្លួនយល់ឃើញថាមានមោឃភាពដែរ។ ចៅក្រមស៊ើបសួរធ្វើបណ្ដឹងតាមដីកាដោយមានសំអាងហេតុ និងត្រូវជូនព័ត៌មានទៅព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ គ្មានមោឃភាពនៃនីតិវិធីមុន អាចលើកឡើងបានទៀតទេចំពោះមុខតុលាការជំនុំជម្រះ។[65] មានន័យថា ក្រោយការដោះស្រាយនូវមោឃភាពពីមុនដោយសភាស៊ើបសួររួចរាល់ហើយ កិច្ចស៊ើបសួរត្រូវបានបិទដោយស្ថាពរ ដោយដីកាដំណោះស្រាយហើយ ដូចនេះកិច្ចស៊ើបសួរត្រូវបានបញ្ចប់សព្វគ្រប់ហើយ គ្មានការលើកឡើងពីមោឃភាពណាមួយ អាចធ្វើបានឡើយ។

---

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៥២ កថាខណ្ឌទី២

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៥៦

## ផ្នែកទី៣ អង្គការយព្រះរាជអាជ្ញាក្នុងដំណើរការជំនុំជម្រះ

អយ្យការមិនមែនត្រឹមតែជាតួអង្គក្នុងការធ្វើបណ្ដឹងអាជ្ញាទេ តែកំឡុងពេលសវនាការក៏ត្រូវ មានវត្តមាន ដែរក្នុងនាមជាតួអង្គតំណាងឱ្យផលប្រយោជន៍សង្គម។ នៅក្នុងនីតិវិធីជំនុំជម្រះ តំណាងអយ្យការគឺជាភាគី នៃបណ្ដឹងដែលយើងនឹងសិក្សាអំពី នីតិវិធីមុនកិច្ចដេញពិភាក្សាដេញដោល (៤.១) អំឡុងពេល និងការបញ្ចប់នៃកិច្ចពិភាក្សាដេញដោល (៤.២) ។

### ៣.១ នីតិវិធីមុនកិច្ចពិភាក្សាដេញដោល

តុលាការនឹងត្រូវបានបើកការជំនុំជម្រះតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដីកាសម្រេច របស់ចៅក្រមស៊ើបសួរឱ្យបញ្ជូនទៅជំនុំជម្រះ។ ហេតុយ៉ាងដូចនេះ នៅមុនពេលរាល់សវនាការ ព្រះរាជអាជ្ញាមានតួនាទីជួយសម្រួលដល់ការបង្ហាញខ្លួនរបស់ជនជាប់ចោទ ភាគីដែលពាក់ព័ន្ធ ព្រមទាំងត្រូវបំពេញលក្ខណៈសម្បត្តិរបស់ខ្លួនផងដែរ។

**ចំនុចទី១៖** នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ជាការបង្ហាញខ្លួនរបស់ជនជាប់ចោទនៅមុខ តុលាការ។ ហេតុនេះហើយ ព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ឱ្យដំណឹងដល់ជននោះ អំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្ដីអំពីការបង្គាប់ឱ្យចូលបង្គាប់ឱ្យចូលខ្លួនភ្លាម។
- ក្រៅពីនេះ ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

➢ **ចំនុចទី២៖** ទាក់ទងទៅនឹងបច្ចេកទេសរបស់តំណាងអយ្យការ ក្នុងដំណាក់កាលមុនពេលសវនាការ ។ ជាក់ស្ដែងក្នុងការអនុវត្តនីតិវិធី ព្រះរាជអាជ្ញាត្រូវបានកំណត់ឱ្យអនុវត្តកិច្ចការមួយចំនួន ដូចជា រៀបចំឯកសារសំណុំរឿង ដើម្បីធ្វើការពិភាក្សាដេញដោលនៅចំពោះមុខតុលាការ។ ការរៀបចំនេះក៏ត្រូវមានឯកសារភស្តុតាងដាក់បន្ទុករបស់ខ្លួន ដែលជាមូលដ្ឋាននៃការចោទប្រកាន់ ឬការពារដល់ការចោទប្រកាន់របស់ខ្លួន។ លើសពីនេះ ព្រះរាជអាជ្ញាត្រូវគោរពផងដែរនូវពេលវេល កំណត់សវនាការ និងគោរពលើឯកសណ្ឋានជាដើម។

### ៣.២ អំឡុងពេល និងការបញ្ចប់កិច្ចពិភាក្សាដេញដោល

ជាការពិតណាស់ ព្រះរាជអាជ្ញាជាភាគីម្ខាងនៅក្នុងសវនាការរឿងក្ដីព្រហ្មទណ្ឌ។

នៅពេលដែលកិច្ចពិភាក្សាដេញដោល ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរ ដល់ជនជាប់ចោទ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែទទួលបានការអនុញ្ញាតពីប្រធានសវនាការ ជាមុនសិន។ សិទ្ធិអំណាចព្រះរាជអាជ្ញាក៏អាចធ្វើចំពោះការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជនរងគ្រោះ សាក្សី និងអ្នកជំនាញផងដែរ។

លើសពីនេះ ព្រះរាជអាជ្ញាអាចជំទាស់នឹងការស្តាប់សាក្សី ដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសំដែងឱ្យឃើញការពិត។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើត្រូវស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីនេះ។

ចំណែកឯ ការបញ្ចប់កិច្ចពិភាក្សាដេញដោល ព្រះរាជអាជ្ញា មានសិទ្ធិក្នុងការនិយាយស្តី ឬក៏ធ្វើការសន្និដ្ឋានសរុបឱ្យចោទប្រកាន់ ឬផ្តន្ទាទោសទៅលើជនជាប់ចោទ ទៅតាមសិទ្ធិអំណាច និងការយល់ឃើញឯករាជ្យរបស់គាត់។ ព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានប្តឹងសុំដោយផ្ទាល់មាត់ ដែលខ្លួន យល់ឃើញថាសមស្របទៅនឹងផលប្រយោជន៍ល្អ នៃយុត្តិធម៌។

## ផ្នែកទី៤ អយ្យការនៅដំណាក់កាលអនុវត្តទោស

ជាទូទៅការអនុវត្តទោសត្រូវធ្វើឡើងតាមគំនិតផ្តើមរបស់អយ្យការ[66] ហើយនៅពេលដែលសេចក្តីសម្រេចបានចូលជាស្ថាពរ អយ្យការជាអ្នកមានសមត្ថកិច្ចក្នុងការអនុវត្តទោស[67] ផងដែរ ។ ចំណែកឯនៅក្នុងការអនុវត្តទោសព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអាចសុំកងកម្លាំងសាធារណៈដើម្បីធានារ៉ាប់រងការនិតិវិធីទាំងនេះ។[68] ម្យ៉ាងវិញទៀតច្បាប់ក៏បានបើកផ្លូវអនុញ្ញាតឱ្យភាគីអាចប្តឹងឧទ្ធរណ៍បានផងដែរ តាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៧៥ *បុគ្គលដែលធ្វើបណ្តឹងឧទ្ធរណ៍បាន៖*

- *ព្រះរាជអាជ្ញា នៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍*
- *ពិរុទ្ធជន*
- *ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី*
- *អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។*

ប៉ុន្តែក្នុងការប្តឹងឧទ្ធរណ៍ គឺមានរយៈពេលជាក់លាក់ ដែលភាគីអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល ១ ខែ ដូចនេះមានន័យថាប្រសិនបើរយៈពេលនេះបានកន្លងផុតទៅ សេចក្តីចម្រេចនឹងចូលជាស្ថាពរ នោះការអនុវត្តទោសនឹងបានចាប់ផ្តើម។

### ៤.១ ការគ្រប់គ្រងពន្ធនាគារ

គោលដៅក្នុងការគ្រប់គ្រងជនជាប់ឃុំ គឺការអប់រំកែប្រែ និងស្តារនីតិសម្បទារបស់ជនជាប់ឃុំដែលជាស្នូលនៃក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ[69] ហើយចំពោះការដាក់ពិន័យ ត្រូវធ្វើឡើងក្នុងអប្បបរមាផងដែរ ដើម្បីការពារសុខសុវត្ថភាព និងរក្សាសណ្តាប់ធ្នាប់ប៉ុណ្ណោះ[70] ។ ពន្ធនាគារនីមួយត្រូវមានបញ្ជីជានជាប់ឃុំ ហើយត្រូវមានចុះទិដ្ឋាការដោយតំណាងអយ្យការនៅគ្រប់ទំព័រ។ មួយវិញទៀតការគ្រប់គ្រងពន្ធនាគារសម្រាប់ជានជាប់ឃុំជាស្ត្រីភេទ និងជនជាប់ចោទជាអនីតិជន ត្រូវមានបញ្ជីដាច់ដោយឡែក និងក៏ត្រូវ

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៩៦
[67] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៩៧
[68] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៤៩៩
[69] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៥០៦
[70] ច្បាប់ស្តីពីពន្ធនាគារ នស/រកម/១២១១/០២១ ប្រកាសអោយប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១, មាត្រា៤២

មានការយកចិត្តទុកដាក់ជាពិសេស។[71] យ៉ាងណាមិញតំណាងអយ្យការក៏ត្រូវត្រួតពិនិត្យទៅលើបញ្ជីជនជាប់ឃុំនេះ ចំពោះចៅក្រមត្រូវជូនឱ្យពិនិត្យតាមការស្នើសុំ និងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចដោយតុលាការ។[72]

### ៤.២ ការចុះអធិការកិច្ចនៅពន្ធនាគារ

ជាទូទៅការចុះអធិការកិច្ចនៅពន្ធនាគារ គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវចុះធ្វើអធិការកិច្ចជាប្រចាំ[73] ចំណែកឯបែបបទ និងការប្រព្រឹត្តទៅនៃការចុះអធិការកិច្ច ច្បាប់មិនបានកំណត់ជាក់លាក់ណាមួយឡើយ ប៉ុន្តែតាមច្បាប់ស្តីពីពន្ធនាគារ មាត្រា៥៤ បានបញ្ញត្តិថា *«ការចុះអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។»* តាមរយៈប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ការត្រួតពិនិត្យពន្ធនាគារ គឺត្រូវមានការអនុញ្ញាតពីប្រធាននាយកដ្ឋានពន្ធនាគារ ហើយត្រូវអនុវត្តតាមលក្ខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតនោះ។[74] ចំពោះបុគ្គលដែលអាចអនុញ្ញាតឱ្យចុះត្រួតពិនិត្រពន្ធនាគារមានដូចជា៖

- តំណាងព្រះមហាក្សត្រ
- សមាជិករដ្ឋសភាជាតិ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ជនទាំងឡាយ ដែលច្បាប់អនុញ្ញាតពីក្រសួងមហាផ្ទៃ
- ចៅក្រម ឬព្រះរាជអាជ្ញា
- អភិបាលខេត្ត-ក្រុង
- ជនណាម្នាក់ ឬអង្គការណាមួយ ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី ប្រធាននាយកដ្ឋានពន្ធដារ។[75]

### ៤.៣ ការដោះលែងដោយមានលក្ខខណ្ឌ

តាមច្បាប់ ប្រសិនបើទណ្ឌិតទាំងអស់ដែលជាប់ឃុំពន្ធនាគារមួយឬច្រើន បង្ហាញឱ្យឃើញថា មានគំនិតមាយាទល្អក្នុងរយៈពេលជាប់ឃុំ និងស្ថានីតិសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ទណ្ឌិតនោះអាចត្រូវបានដោះលែង ដោយមានលក្ខខណ្ឌ នេះបើយោងតាមច្បាប់ស្តីពីពន្ធនាគារមាត្រា ៧៩ កថាខណ្ឌទី១។ ក្នុងករណីខ្លះអ្នកទោសអាំចត្រូវបានដោះលែងបន្ទាន់ដូចជា៖

- នៅពេលផុតកំណត់ទោស។

---

[71] ច្បាប់ស្តីពីពន្ធនាគារ នស/រកម/១២១១/០២១ ប្រកាសអោយប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១, មាត្រា២១

[72] ច្បាប់ស្តីពីពន្ធនាគារ នស/រកម/១២១១/០២១ ប្រកាសអោយប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១, មាត្រា២២

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៥០៩

[74] ប្រកាសស្តពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការ៤ ចំណុចទី២៦-ខ

[75] ប្រកាសស្តពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការ៤ ចំណុចទី២៦-ក

- នៅពេលដែលអនុញ្ញាតឲ្យដាក់ប្រាក់ធានាឱ្យនៅក្រៅឃុំ ដោះលែងដោយមានលក្ខខណ្ឌ ដោះលែងបណ្ដោះអាសន្ន។
- នៅពេលដែលលើកលែងការចោទប្រកាន់។
- នៅពេលនិតទេសខ្លួនឱ្យអាជ្ញាធរមានសមត្ថកិច្ច ដោយមានការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច។
- នៅពេលដែលលើកលែងទោសដោយព្រះមហាក្សត្រចំពោះទោសដែលនៅសេសសល់។[76]

បើយើងក្រឡេកមើលការឱ្យនិយមន័យទៅលើលក្ខណ្ឌទាក់ទងទៅនឹងគំនិតមាយាទល្អ ក្រមព្រហ្មទណ្ឌបានកំណត់ថាលក្ខខណ្ឌទាក់ទងទៅនឹងគំនិតមារយាទ សំដៅលើគ្រប់ទណ្ឌិតដែលត្រូវបានទទួល ទោសមួយឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញ ឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ មិនមានសម្បទាដែលអាចបញ្ចូលខ្លួន ទៅក្នុងសង្គមវិញបាន ។[77]

លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចហើយ សម្រាប់លក្ខខណ្ឌនេះ ការដោះលែងអាចត្រូវបានផ្ដល់ឱ្យដល់ទណ្ឌិត ដែលទទួលរងទោសជាប់ពន្ធនាគារៈ

- ចំនួនពាក់ពាក់កណ្ដាលនៃទោស ប្រសិនបើទោសនេះអាចតិចជាង ឬស្មើ ១ឆ្នាំ
- ចំនួនពីរភាគបីនៃទោសក្នុង ករណីផ្សេងទៀត ។

រីឯទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិតអាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត២០ឆ្នាំរួចមកហើយ។[78] ហេតុដូចនេះ អាជ្ញាធរមានសមត្ថកិច្ច សម្រាប់ផ្ដល់ការដោះលែងដោយមានលក្ខខណ្ឌទាំង ២ ខាង លើនេះត្រូវផ្ដល់ដោយប្រធានតុលាការជាន់ដំបូងនៃទីតាំងឃុំខ្លួន បន្ទាប់ពីប្រធានតុលាការសម្រេច ក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។

[76] ប្រកាសស្ដីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការ៤ ចំណុចទី៤-ក

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៥១២

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ នស/រកម/០៨០៧/០២៤ ប្រកាសអោយប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៥១៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវកន្លងមកនេះ យើងអាចយល់បានថាស្ថាប័នអយ្យការបានបង្កើតឡើងតាំងពីឆ្នាំ ១៩៣៧ មកម្ល៉េះ និងមានក្រមពិភាក្សាព្រហ្មទណ្ឌដែលដូចទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌយើងសព្វថ្ងៃ លុះវិវត្តក្រោយៗមករហូតដល់ពេលបច្ចុប្បន្ន ដែលតម្រូវឱ្យតំណាងអយ្យការដែលជាភាគីរដ្ឋ ត្រូវដើរតួក្នុងការប្រមូលភស្តុតាងដាក់បន្ទុក និងធ្វើបណ្តឹងក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ ជាតួអង្គ ឬស្ថាប័នដ៏សំខាន់មួយក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដែលត្រូវមានវត្តមានគ្រប់ ដែនដីរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ តួនាទីចម្បងរបស់អយ្យការ គឺជាការធ្វើ បណ្តឹងអាជ្ញា និងថ្លឹងថ្លែងអំពីការធ្វើបណ្តឹងនេះ ក្នុងនាមជាអ្នកតំណាងឱ្យប្រយោជន៍សាធារណៈ។ ក្នុងន័យនេះ អយ្យការត្រូវតែប្រកាន់យកនូវភាពត្រឹមត្រូវ ប្រកបដោយមនសិការវិជ្ជាជីវៈក្នុងការ ដើរតួជានិយ័តករនៃសង្គម។

ព្រះរាជអាជ្ញា ត្រូវបានប្រគល់នូវសិទ្ធិអំណាចដ៏ធំធេង ដែលអាចចូលរួមគ្រប់កិច្ចនីតិវិធីន រឿងក្តីព្រហ្មទណ្ឌ តាំងពីដើមរហូតដល់ការអនុវត្តទោស។ ហេតុដូចនេះ ទើបរាជរដ្ឋាភិបាលដែល មានក្រសួងយុត្តិធម៌ជាសេនាធិការ បានខិតខំរៀបចំនូវការប្រលងប្រជែងដើម្បីចម្រាញ់នូវបញ្ញាវន្ត ផ្នែកច្បាប់ដែលមានគុណភាពខ្ពស់សម្រាប់បម្រើការក្នុងវិស័យយុត្តិធម៌។ យើងសង្កេតឃើញថា ពី មួយឆ្នាំទៅមួយឆ្នាំ ដោយសារតម្រូវការនូវធនធានចៅក្រម-ព្រះរាជអាជ្ញានេះ ចេះតែកើនឡើង ទើប ចាប់ពីឆ្នាំ២០១៧នេះ រាជបណ្ឌិតវិជ្ជាជីវៈតុលាការបានរៀបចំឱ្យមានការប្រលងប្រជែង ជារៀងរាល់ ឆ្នាំ ក្នុងគោលដៅបំពេញនូវតម្រូវការសង្គម ក៏ដូចជាជម្រុញនូវវិស័យយុត្តិធម៌នៅកម្ពុជាឱ្យកាន់ត ប្រសើរឡើង។ ក្រោយការប្រលងប្រជែងបានជាប់ជាស្ថាពរ និស្សិតទាំងនោះត្រូវបានដាក់ឱ្យសិក្សា នៅសាលារាជបណ្ឌិតវិជ្ជាជីវៈតុលាការក្នុងរយៈពេល១ឆ្នាំសម្រាប់ផ្នែកទ្រឹស្តីនៃវិជ្ជាជីវៈចៅក្រម-ព្រះរាជអាជ្ញានេះ និងរយៈពេល១ឆ្នាំ សម្រាប់ការអនុវត្តជាក់ស្តែងនៅតាមអង្គការអយ្យការនានាក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ជារួមមក ព្រះរាជអាជ្ញាទាំងអស់ដាច់ខាតត្រូវតែជាបុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ទាំង ផ្នែកវិទ្យាសាស្ត្រសង្គម និងផ្នែកនីតិសាស្ត្រ ដើម្បីធានាដល់ការអនុវត្តនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធិភាព។ បើពុំដូច្នេះទេ ព្រះរាជអាជ្ញាដែលជាម្ចាស់នៃបណ្តឹងអាជ្ញា អាចនឹងមានកំហុស ឆ្គងក្នុងការសម្រេចអ្វីមួយក្នុងនីតិវិធី ដោយសារការថ្លឹងថ្លែងមិនបានត្រឹមត្រូវ មិនប្រកបដោយគុណ- វឌ្ឍន៍ ក៏ដូចជាភាពអវិជ្ជាណាមួយ។

ដូចនេះ ក្នុងនាមខ្ញុំជាបញ្ញវន្តផ្នែកច្បាប់មួយរូប ក៏ដូចជាធនធានមួយក្នុងសង្គម សូមទទួលនូវការគោរព ដើម្បីបញ្ចេញមតិយោបល់មួយចំនួនដល់និស្សិត ឬសិស្សប្អូនដទៃទៀត ដែលមានឆន្ទៈក្នុងការបំពេញវិជ្ជាជីវៈជាតំណាងអយ្យការដូចតទៅ៖

១. ត្រូវសិក្សាស្វែងយល់ឱ្យច្បាស់ និងប្រកាន់ខ្ជាប់ឱ្យបាននូវក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងភាពត្រឹមត្រូវ។

២. តាំងខ្លួនជាអ្នកសិក្សាស្រាវជ្រាវគ្រប់ពេលវេលាទាំងផ្នែកសង្គមវិទ្យា ឬពហុជំនាញផ្សេងៗ។

៣. ត្រូវបន្តក្រេបយកចំណេះដឹងផ្នែកច្បាប់ជាប្រចាំ ដោយត្រូវយល់ថាការសិក្សាស្រាវជ្រាវ គ្មានថ្ងៃបញ្ចប់។

៤. ត្រូវប្រកាន់ខ្ជាប់នូវមនសិការក្នុងការអនុវត្តវិជ្ជាជីវៈឱ្យបានជាដាច់ខាត ព្រោះតំណាង អយ្យការ គឺជាបុគ្គលដែលមានអំណាចធំធេងណាស់។

៥. ត្រូវប្រកាន់គោលការណ៍គិតគូរដល់ផលប្រយោជន៍ប្រទេសជាតិជាធំ។

៦. ត្រូវប្រកាន់ខ្ជាប់ជៀសវៀងនូវអគតិធម៌ទាំង៤៖ ឆន្ទាគតិ ទោសាគតិ មោហាគតិ និងភយាគតិ។

# អនុបាតបទ័

## អនុសាសន៍

ឆ្លងកាត់ការសិក្សាផ្នែកនីតិសាស្ត្រនេះអស់រយៈពេល៤ឆ្នាំមក ទាំងទទួលបានការណែនាំពីសំណាក់សាស្ត្រាចារ្យ ព្រមទាំងបានស្រាវជ្រាវអំពីអត្ថបទនេះកន្លងមក ដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានល្អប្រសើរប្រកបទៅដោយភាពយុត្តិធម៌ ខ្ញុំបាទសូមជូននូវយោបល់ខ្លះៗចំពោះការបំពេញការងាររបស់តំណាងអយ្យការដូចខាងក្រោម៖

ក. នៅគ្រប់ពេលដែលបំពេញភារកិច្ចក្នុងសំណុំរឿងព្រហ្មទណ្ឌ តំណាងអយ្យការគប្បីធ្វើការស៊ើបអង្កេតផ្ទាល់ដល់ទីកន្លែងកើតហេតុភ្លាមៗ ប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់មុននិងធ្វើដីការ សន្និដ្ឋានបញ្ជូនរឿងឱ្យចៅក្រមស៊ើបសួរ ព្រោះជាក់ស្តែងតំណាងអយ្យការពុំសូវបានចុះស៊ើបអង្កេតផ្ទាល់ពេលរឿងហេតុកើត ឡើងភ្លាមៗនោះទេ ដោយលោកច្រើនប្រមូលភស្តុតាង ឬឱ្យមន្ត្រីនគបាលយុត្តិធម៌ជាអ្នកដែលចុះដល់ទី កន្លែងកើតហេតុ

ខ. តំណាងអយ្យការត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍ការពារផលប្រយោជន៍សង្គម

គ. តំណាងអយ្យការគួរពង្រឹងទំនាក់ទំនងល្អជាមួយយុត្តាធិការស៊ើបសួរ នគរបាលយុត្តិធម៌ ឬ មន្ត្រីសាធារណៈដទៃទៀតដែលពាក់ព័ន្ធលើការអនុវត្តមុខងាររបស់ខ្លួន

ឃ. ត្រូវបំពេញមុខងារដោយផ្អែកលើគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់

ង. គ្រប់សេចក្តីសម្រេចផ្អែកលើបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ជាធរមាន និងគួរគប្បីបញ្ជាក់សំអាងហេតុ ត្រឹមត្រូវដើម្បីធ្វើការចោទប្រកាន់ ឬ សេចក្តីសម្រេចណាមួយ ដើម្បីធានាថាភាគីនៃរឿងក្តីដែលខ្លួនកំពុងធ្វើចំណាត់ការនឹងទទួលបានភាពយុត្តិធម៌ និងទទួលយកនូវការអនុវត្តនោះ ។

# ឯកសារយោង

## ១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

## ២. ក្រម

- ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើ ក្រមនីតិវិធីព្រហ្មទណ្ឌ។
- ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើ ក្រមព្រហ្មទណ្ឌ។
- ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើ ក្រមរដ្ឋប្បវេណី។
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ៣. ច្បាប់

- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាស ឱ្យប្រើ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាស ឱ្យប្រើ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

## ៤.ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវតុលាការ។
- ព្រះរាជក្រឹត្យលេខ ២១៧ អនក្រ. ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រងពន្ធនាគារ។

## ៥.បទដ្ឋានគតិយុត្តផ្សេងៗ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តដោយមហាសន្និបាតអង្គការសហ ប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តដោយមហាសន្និបាត អង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។
- អនុសញ្ញាក្រុងវីយែនស្តីពីទំនាក់ទំនងការទូត អនុម័តដោយសន្និសិទអង្គការសហប្រជា ជាតិចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៦១ ស្តីពីការប្រាស្រ័យទាក់ទងការទូត និងអភ័យឯកសិទ្ធិ ការទូត។
- គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហ ប្រជាជាតិលើកទី៨ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩០, ចំនុចទី១៣ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស។

## ៦. សៀវភៅមេរៀន

- លោក **កុយ នាម** និងលោក **ឡុង បញ្ញាវុឌ្ឍ**, អង្គការយុវ្យការ (ប្រវត្ត និងការសិក្សាប្រៀប), ភ្នំពេញ, បោះពុម្ពលើកទី១, ឆ្នាំ២០០៦។
- លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ**, នីតិព្រហ្មទណ្ឌទូទៅ, បោះពុម្ពឆ្នាំ២០១២។
- លោកគ្រូ **មីន សំអុល** សៀវភៅនីតិវិធីព្រហ្មទណ្ឌ។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

✦✦✦✦✦

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខៈ .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឲ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឲ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ

## កំណត់ហេតុទទួលវត្ថុតាង

ឆ្នាំពីរពាន់ដប់បី ខែ ... ថ្ងៃទី ពីរ វេលាម៉ោង ដប់ និង សូន្យ នាទី ។
យើង ...ក្រឡាបញ្ជីនៃអយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។
លោក ... ជាមន្រ្តីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តបន្ទាយមានជ័យ
ជាអ្នកប្រគល់រួមជាមួយនិងឈ្មោះ ....ឈ្មោះ ....ឈ្មោះ ...ពីបទៈជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន

បានពិនិត្យភ័នភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ឃើញដូចខាងក្រោមៈ

១-កញ្ចប់ពណ៌សបិទជិតមានស្នាមមេដៃឈ្មោះ ....ឈ្មោះ ...និងហត្ថលេខាលោក ...លោក ...និងលោក ... ។

២-ទូរស័ព្ទចំនួន ០៦ គ្រឿង មួយគ្រឿងម៉ាក់ SAMSUNG ពណ៌ខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់NOKIA E99I ពណខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់ NOKIA X1 ពណ៌ខ្មៅ(ចិន) .មួយគ្រឿងទៀតម៉ាក់ NOKIA ចុចពិលពណ៌ផ្កាឈូកលាយពណ៌ស (ចាស់) .មួយគ្រឿងម៉ាក់ NOKIA ចុចពិលពណ៌ខ្មៅបិទស្កុតពណ៌ទឹកប្រាក់ និងមួយគ្រឿងទៀតម៉ាក់ HUAWEI ពណ៌ខ្មៅលាយពណ៌ស។

៣-កាបូបលុយចំនួនមួយពណ៌ខៀវ(គ្មានលុយ).ដែកកេះចំនួនពីរ.កាបូបស្ពាយតូចចំនួនមួយពណ៌ប្រផេះ.សំបកប្រអប់ស្រោមអនាម័យOKចំនួនមួយ.ថង់តូចពណ៌សមួយចំនួន.បំពុងទុយយចំនួនពីរ.កំរបដបទឹកចោះដាក់ទុយយមួយ។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនពីរ.មួយមានលេខៈ...របស់ឈ្មោះ...និងមួយទៀតមានលេខៈ... របស់ឈ្មោះ ...។

៥-លុយខ្មែរចំនួន ៥០០០០ រៀល និងលុយដុល្លារចំនួន ១០ ដុល្លារ។

៦-ម៉ូតូមួយគ្រឿងម៉ាក់ VIVA ពណ៌ខ្មៅសេរីឆ្នាំ ២០១០ គ្មានកញ្ចក់ .គ្មានកន្រ្តក ពាក់ផ្លាក់លេខៈ ...លេខម៉ាស៊ីន ...។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់និងសែសិប នាទី នាថ្ងៃ ខែឆ្នាំដដែល ។

| អ្នកប្រគល់ | ក្រឡាបញ្ជី | ជនជាប់សង្ស័យ |
|---|---|---|

បានឃើញ
បន្ទាយមានជ័យ.ថ្ងៃទី ... ខែ ...ឆ្នាំ ២០១៣
**ព្រះរាជអាជ្ញារង**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**

**សាលាដំបូងខេត្តពោធិ៍សាត់**

*សំណុំរឿងព្រហ្មទណ្ឌ*

*លេខ...........*

*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

## កំណត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។

យើងបានស្តាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពរ។

បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាដូចខាងក្រោម:

នាមត្រកូល ៖ ... នាមខ្លួន ៖ ...

ភេទ: ប្រុស

កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ

ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់

អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់

មុខរបរ ៖ ...

សាសនា: ព្រះពុទ្ធ

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ... "រ" ម្តាយឈ្មោះ ៖ ... "រ"

អនីតិជន ☐ ឬ នីតិជន ☐

ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន

ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

**សួរ-ឆ្លើយ៖** នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហុប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូម ហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ.ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ... ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ.ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ.ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ.ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីុរូស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមាត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកគៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូឆ្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ.ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចឆ្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ.ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតម្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតម្រាម ដៃជាមួយយើង ។

| | | |
|---|---|---|
| **អ្នកឆ្លើយ** | **ក្រឡាបញ្ជី** | **ព្រះរាជអាជ្ញារង** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
បន្ទាយមានជ័យ

កំណត់ហេតុស្រុះស្រួល

ឆ្នាំពីរពាន់ដប់ពីរ ខែ មេសា ថ្ងៃទី ពីរ វេលាម៉ោង ពីរ និង ដប់ នាទី នៅអយ្យការអម សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានធ្វើការស្រុះស្រួលរវាងដើមចោទ និងជនជាប់សង្ស័យ ដូចតទៅ:

-ភាគីដើមចោទឈ្មោះ ... ភេទ ប្រុស អាយុ ... នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានប្ដឹងឈ្មោះ ... ភេទ ... ឲ្យប្រគល់ដី ស្រែចំនួន កន្លះហិចតា ឲ្យមកខ្លួនវិញ។

-ជនជាប់សង្ស័យឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ រស់នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានស្រុះស្រួលជាមួយដើមបណ្ដឹងដោយយល់ព្រមប្រគល់ដីស្រែចំនួន កន្លះ ហិចតា នេះស្ថិតនៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ ឲ្យដើមបណ្ដឹងឈ្មោះ ... ដើម្បីគ្រប់គ្រង និងបានយល់ព្រមសងស្រូវទៅដើមបណ្ដឹងវិញចំនួន ០៦ បាវ។

ការស្រុះស្រួលគ្នានេះ ដើមបណ្ដឹងឈ្មោះ ... សុខចិត្តដកពាក្យបណ្ដឹងឈប់ប្ដឹងពីជនជាប់សង្ស័យឈ្មោះ ... វិញហើយ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ពីរ និងហាសិប នាទី នាថ្ងៃ ខែ ឆ្នាំ ដដែល រួច បានអានឲ្យស្ដាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្ដិតមេដៃ និងចុះហត្ថលេខាទុកចំណាំ។

ដើមបណ្ដឹង ជនជាប់សង្ស័យ

បានឃើញ
ថ្ងៃទី ខែ ... ឆ្នាំ ២០១២
ព្រះរាជអាជ្ញា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូង ខេត្តពោធិ៍សាត់**

*សំណុំរឿងព្រហ្មទណ្ឌលេខ ...*

*ចុះថ្ងៃទី ... ខែ ... ឆ្នាំ...*

# ដីកាកោះ

*យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។*

*ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។*

*ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*នៅវេលាម៉ោង២.០០ រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។*

*ដើម្បី* ***សួរយកចម្លើយ***

*ពីដំណើររឿង* ***បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅ***

***ចំណុច...ភូមិ...ខេត្តពោធិ៍សាត់។***

*សាមី*

*ខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។*

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...*

**ព្រះរាជអាជ្ញារង**

*យើង..................................................................បានប្រគល់ដីកាកោះនេះដល់*

*ឈ្មោះ...................................ទីលំនៅបច្ចុប្បន្ននៅភូមិ................... ឃុំ/សង្កាត់ ......................................... ស្រុក/ខណ្ឌ...............ខេត្ត/ក្រុង.........................នៅថ្ងៃទី .........ខែ..................ឆ្នាំ...................................ហើយយើងបានប្រាប់ថា ឱ្យយកចុង ដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលាដំបូងខេត្តពោធិ៍សាត់។*

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាផ្ទេរសមត្ថកិច្ច

✦✦✦✦✦

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឲ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឲ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

អយ្យការអម

*សាលាដំបូងខេត្ត*

**បន្ទាយមានជ័យ**

**********

លេខ: អក.បជ

# **ដីកាបញ្ជាស្វែងរកចាប់ខ្លួន**

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត **បន្ទាយមានជ័យ**

បានឃើញ: មាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ:របាយការណ៍លេខ: ... ព.គ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២ ស្តីពីទណ្ឌិតឈ្មោះ ... ភេទប្រុស អាយុ ... ឆ្នាំ ពុំមានឃុំខ្លួននៅក្នុងពន្ធនាគារ (រត់គេចខ្លួន)។

**<u>យល់ឃើញថា:</u>**

